ទស្សនាវដ្តី

# ព្រៃឈើ



រដ្ឋបាលព្រៃឈើ

តុលា ២០២២

៦៦

# មាតិកាអត្ថបទ

ល.រ ឈ្មោះអត្ថបទ ទំព័រ


១- សមិទ្ធផលការងារឆមាសទី១ ឆ្នាំ២០២២ របស់រដ្ឋបាលព្រៃឈើ ....................១

២- រុក្ខជាតិកម្រដែលមានរូបរាងប្លែកៗស្រដៀងទៅនឹងសត្វ ឬរបស់អ្វីម៉្យាង .................... ២៤

៣- តែស្លឹកឫស្សី ....................៣៣

៤- អត្ថប្រយោជន៍របស់ផ្លែរកាំ ឬសាឡាក់ .................... ៣៦

៥- រុក្ខជាតិឱសថ ដើមក្រពាត់ជ្រូក .................... ៣៨

៦- ការសិក្សាស្រាវជ្រាវវត្តមានឧរង្គសត្វ និងថលជលិកសត្វ នៅក្នុងតំបន់គម្រោងរេដបូកទំរីង ខេត្តកំពង់ធំ....................៣៩

៧- ការវាយតម្លៃលើចំណេះដឹង ឥរិយាបថ និងការអនុវត្តស្ដីពីការការពារជំងឺឆ្លងពីសត្វមកមនុស្ស នៅស្រុកបាណន់ ខេត្តបាត់ដំបង.....៤៤

៨- ស្វែងយល់ពីការសាងសង់ផ្ទះសត្វត្រចៀកកាំ ....................៤៩

៩- កិច្ចសហការរដ្ឋបាលព្រៃឈើ និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃគាំទ្រសហគមន៍ព្រៃឈើប្រាំបីមុំខេត្តកំពង់ស្ពឺ .................... ៥៦

១០- តើអ្នកដឹងអ្វីខ្លះពីសត្វក្រៀល?....................៥៨

១១- ស្វែងយល់ពីប្រភេទសត្វខ្លាជីតាស(Cheetah) .................... ៦៣

១២- កម្សាន្ត ....................៦៨

១៣- កំណាព្យ “ រួមគ្នាស្ដាយស្រណោះ ” (នៅមានត) ....................៦៩


យើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ដែលបានជួយឧបត្ថម្ភ ផ្ដល់នូវអត្ថបទ និងរូបភាពសម្រាប់ចុះផ្សាយក្នុងទស្សនាវដ្ដីរបស់យើងខ្ញុំៗ ទន្ទឹមនឹងនេះ យើងខ្ញុំសូមអំពាវនាវដល់ប្រិយមិត្តអ្នកអានទាំងអស់ សូមមេត្តាជួយជ្រោមជ្រែង ផ្ដល់នូវមតិរិះគន់ស្ថាបនា ផ្ដល់អត្ថបទមានអត្ថប្រយោជន៍ផ្សេងៗដើម្បីចុះផ្សាយក្នុងទស្សនាវដ្ដីជាបន្តបន្ទាប់ទៀតៗ *(ទំនាក់ទំនងព័ត៌មាន-ផ្ដល់អត្ថបទ* **077 98 17 98** *(Telegram))*



*សូមអរគុណ!*

*រដ្ឋបាលព្រៃឈើ*


**អគារលេខ ៤០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ (កម្ពុជា )**

E-mail : tech6777@gmail.com

Website: https://fa.maff.gov.kh




# សមិទ្ធផលការងារ ឆមាសទី១ ឆ្នាំ២០២២ របស់រដ្ឋបាលព្រៃឈើ

យុទ្ធសាស្ត្រក្នុងការកែទម្រង់វិស័យព្រៃឈើ គឺការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព រួមជាមួយប្រព័ន្ធការពារធនធានធម្មជាតិ និងការអនុវត្តកម្មវិធីអភិវឌ្ឍន៍សហគមន៍ព្រៃឈើប្រកបដោយប្រសិទ្ធភាពសំដៅចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គម កាត់បន្ថយភាពក្រីក្រ និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការកើនឡើងកម្ដៅនៃភពផែនដី។

ដើម្បីសម្រេចបាននូវគោលដៅខាងលើ រដ្ឋបាលព្រៃឈើ ដែលជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដី កងកម្លាំងប្រដាប់អាវុធ អង្គភាពពាក់ព័ន្ធ និងអង្គការអន្តរជាតិជាដៃគូអភិវឌ្ឍន៍នានា បំពេញតួនាទីភារកិច្ចទៅតាមអាណត្តិរបស់ខ្លួន ដោយសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់ដូចខាងក្រោម ៖

## សមិទ្ធផលការងារគ្រប់គ្រងព្រៃឈើ និង សហគមន៍ព្រៃឈើ

### ១-ការវាយតម្លៃគម្របព្រៃឈើ

-បានទាញយករូបភាពផ្កាយរណប (SENTINEL-2) ឆ្នាំ២០២២ បានចំនួន ១៩ផ្ទាំង និងបានចាត់ថ្នាក់បឋមសម្រាប់ ចុះពិនិត្យជាក់ស្តែងនៅទីវាល




កិច្ចប្រជុំស្តីពីការចុះផ្ទៀងផ្ទាត់គម្របព្រៃឈើនៅខេត្តព្រះវិហារ

-បានចុះធ្វើការប្រមូលព័ត៌មាននៅទីវាលជាក់ស្តែងតាមចំណុចនិយាមកាមួយចំនួន ដែលបានធ្វើការចាត់ថ្នាក់បឋមតាមរូបភាពផ្កាយរណប SENTINEL-2 ក្នុងកម្មវិធី eCognition ហើយមានភាពមិនច្បាស់លាស់ ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងវាយតម្លៃកម្រិតជឿជាក់ក្នុងខេត្តចំនួន៤ សរុប ១ ១៣៥ចំណុច ក្នុងនោះខេត្តក្រចេះ ចំនួន ៣០៤ចំណុច ខេត្តស្ទឹងត្រែង ចំនួន ៣៩៥ចំណុច ខេត្តមណ្ឌលគិរី ចំនួន ១០៣ចំណុច និងខេត្តព្រះវិហារ ចំនួន ៣៣២ចំណុច។




កិច្ចប្រជុំស្តីពីការចុះផ្ទៀងផ្ទាត់គម្របព្រៃឈើនៅខេត្តស្ទឹងត្រែង



ការចុះផ្ទៀងផ្ទាត់គម្របព្រៃឈើនៅខេត្តព្រះវិហារ



ការចុះផ្ទៀងផ្ទាត់គម្របព្រៃឈើនៅខេត្តមណ្ឌលគិរី

## ២-សហគមន៍ព្រៃឈើ

បានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន ០៤កន្លែង មានផ្ទៃដីព្រៃសរុបទំហំ ៥ ៥៤៧,៤៦ហិកតា រួមមាន ព្រៃសហគមន៍ភ្នំព្រិច មានផ្ទៃដីសរុបទំហំ ៣៥ហិកតា ស្ថិតនៅឃុំស្វាយជ្រះ ស្រុកស្នួល និងព្រៃសហគមន៍ភ្នំត្នោត មានផ្ទៃដីសរុបទំហំ ១៩ហិកតា ស្ថិតនៅឃុំឫស្សីកែវ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ព្រៃសហគមន៍វាលអូរក្តី មានផ្ទៃដីសរុបទំហំ ៤ ២១៨ហិកតា ស្ថិតនៅឃុំក្រយា ស្រុកសន្ទុក និងព្រៃសហគមន៍ក្បាលខ្លា មានផ្ទៃដីសរុបទំហំ ១ ២៧៥,៤៦ ហិកតា ស្ថិតនៅឃុំសណ្ដាន់ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។






ការប្រជុំផ្សព្វផ្សាយស្តីពី
ការគ្រប់គ្រងសហគមន៍ព្រៃឈើ

-បានចុះជួបប្រជុំពិភាក្សា ជាមួយគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើ ដើម្បីពិភាក្សាជ្រើសរើស និងកំណត់ទីតាំងព្រៃសហគមន៍ សម្រាប់អនុវត្តប្រព័ន្ធកសិរុក្ខកម្ម នៃគម្រោងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក្នុងសហគមន៍ព្រៃឈើចំនួន ០៨សហគមន៍ ក្នុងខេត្តចំនួន ០២ រួមមាន៖

• **ខេត្តស្ទឹងត្រែង៖** មានសហគមន៍ព្រៃឈើបុរីអូរស្វាយ ស្ថិតនៅឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ សហគមន៍ព្រៃឈើភ្នំតាគង់ ស្ថិតនៅឃុំក្បាលរមាស ស្រុកសេសាន សហគមន៍ព្រៃឈើអូរឫស្សីកណ្ដាល ស្ថិតនៅឃុំអូរឫស្សីកណ្ដាល និងសហគមន៍ព្រៃឈើសិលាតាព្រហ្ម ស្ថិតនៅឃុំអូរម្រះ ស្រុកសៀមបូក

• **ខេត្តព្រះវិហារ៖** មានសហគមន៍ព្រៃឈើឆែបលិច និងសហគមន៍ព្រៃឈើក្រសាំង ស្ថិតនៅឃុំឆែប១ ស្រុកឆែប សហគមន៍ព្រៃឈើភ្នំដែកចំបក់ហោះ ស្ថិតនៅឃុំរមណី និងសហគមន៍ព្រៃឈើសាមគ្គីត្រពាំងទទឹម ស្ថិតនៅឃុំរមទម ស្រុករវៀង។

-បានចុះផ្សព្វផ្សាយ ស្តីពីការគ្រប់គ្រងព្រៃឈើចំនួន ០៦សហគមន៍ គឺសហគមន៍ព្រៃឈើភូមិអូរសណ្ដាន់ សហគមន៍ព្រៃឈើភូមិពុទ្រាម និងសហគមន៍ព្រៃឈើភូមិជួរដូង ស្ថិតនៅឃុំអូរសណ្ដាន់ សហគមន៍ព្រៃឈើភូមិឈើទាល សហគមន៍ព្រៃឈើភូមិបឹងវាល និងសហគមន៍ព្រៃឈើសាមគ្គីភូមិថ្មីបារមីព្រះអង្គធ្លក ស្ថិតនៅឃុំត្នោតជុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលមានអ្នកចូលរួមសរុបចំនួន ១២០នាក់ ក្នុងនោះមានស្ត្រីចំនួន ២៦នាក់

-បានសហការជាមួយគម្រោងរ៉េដបូកកម្ពុជា-កូរ៉េ គាំទ្រលើការងារល្បាតការពារព្រៃសហគមន៍ចំនួន ១៤កន្លែង នៅស្រុកសណ្ដាន់ ខេត្តកំពង់ធំ បានចុះធ្វើសុវ៉ុឌ្ឍិកម្មព្រៃឈើ ចំនួន ២កន្លែង មានសហគមន៍ព្រៃឈើអូរបុស្សលាវ ចំនួន ២ហិកតា និងសហគមន៍ព្រៃឈើជាំស្នាច់ចំនួន ៣ហិកតា និងបានចូលរួមផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងការដោះស្រាយទំនាស់នៅក្នុងសហគមន៍ព្រៃឈើអូរក្រញាក ឃុំមានរិទ្ធ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។ បានចូលរួមប្រជុំផ្សព្វផ្សាយនីតិវិធី និងយន្តការដកហូតដីព្រៃឈើខុសច្បាប់នៅក្នុងតំបន់គម្រោង និងផែនការអនុវត្តគម្រោងសម្រាប់ឆ្នាំ២០២២-២០២៣ នៅផ្នែករដ្ឋបាលព្រៃឈើកំពង់ថ្ម និងបានចុះសម្របសម្រួលការងារល្បាតព្រៃសហគមន៍ ចំនួន ១៤កន្លែង

រួមមាន ៣កន្លែង នៅឃុំសុចិត្រ ៤កន្លែង នៅឃុំទំរីង និង ៧កន្លែង នៅឃុំមានរិទ្ធ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ។



ការកំណត់ទីតាំងតំបន់កសិ-រុក្ខកម្ម
ក្នុងសហគមន៍ព្រៃឈើ នៅខេត្តព្រះវិហារ



ការកំណត់ទីតាំងតំបន់កសិ-រុក្ខកម្ម
ក្នុងសហគមន៍ព្រៃឈើ នៅខេត្តស្ទឹងត្រែង



ការចុះពិនិត្យផលប៉ះពាល់នៃការសាងសង់បង្គោលអគ្គិសនី
ឆ្លងកាត់សហគមន៍ព្រៃឈើនៅខេត្តកំពង់ធំ





ការចុះលើសំណើសុំដីរបស់សហគមន៍
ជនជាតិដើមភាគតិច នៅខេត្តរតនគិរី

## ៣-ការគ្រប់គ្រងផល អនុផលព្រៃឈើ

### ៣.១-ការចុះបញ្ជិកា និងប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្ត

បានផ្ដល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត សរុបចំនួន ១៤២គ្រឿង និងយានយន្តសរុបចំនួន ២៣៨ គ្រឿង ជូនក្រុមហ៊ុនចំនួន ១២ក្រុមហ៊ុន និងអ្នកស្នើសុំ ចំនួន ២នាក់។

### ៣.២-ការផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ

បានផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ដែលមានឈើហ៊ុបមូលចំនួន ៥ ២៨៩ម៉ែត្រត្រីគុណ កូនឈើចំនួន ៦០ ៤០៤ដើម អុសចម្រុះចំនួន ១៣ ៨២៨ ស្ទែរ ឫស្សីចំនួន ៩៣៣តោន ៥៧០គីឡូក្រាម និងជ័រទឹក ចំនួន ៣០០តោន។

### ៣.៣-ការធ្វើសារពើភណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ

បានធ្វើសារពើភណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើ និងបានរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ៣ក្រុមហ៊ុន គឺក្រុមហ៊ុន ភី អិន ធី

ខូអិលធីឌី ស្ថិតនៅខេត្តព្រះវិហារ ក្រុមហ៊ុន លឹម រ៉ូយ៉ាល់ និងក្រុមហ៊ុន ណេងណា ស្ថិតនៅខេត្តមណ្ឌលគិរី។



ការចុះធ្វើសារពើភណ្ឌប៉ាន់ស្មានធនធានព្រៃឈើ នៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច

### ៤-ការចូលរួមវគ្គបណ្តុះបណ្តាលសិក្ខាសាលា

-មន្ត្រី១រូប បានចូលរួមកិច្ចប្រជុំស្តីពីការអនុវត្តកម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដីឆ្នាំ២០១៨-២០២៧ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-មន្ត្រី១រូប បានចូលរួមសហការជាមួយគម្រោងរបស់អង្គការ JICA បណ្តុះបណ្តាលបច្ចេកទេសប្រមូលទិន្នន័យ និងអនុវត្តវិធានបច្ចេកទេសពាក់ព័ន្ធ នៅខេត្តស្ទឹងត្រែង

-មន្ត្រី ៣រូប បានចូលរួមសិក្ខាសិលាពិគ្រោះយោបល់ស្តីពីមគ្គុទ្ទេសបច្ចេកទេស សម្រាប់បង្កើត និងអភិវឌ្ឍន៍ចម្ការព្រៃឈើដាំនៅកម្ពុជា ខេត្តសៀមរាប

-មន្ត្រី២រូបបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានបរិស្ថាន នៅខេត្តព្រះសីហនុ

-មន្ត្រី ១រូប បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការបង្កើតគណកម្មាធិការគ្រប់គ្រងទន្លេសេកុង និងអាងទន្លេសេសាន-ស្រែពក(2s) និងអាព្រែក៤P នៅខេត្តកំពង់ចាម

-មន្ត្រី១រូប រូបបានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យពិភាក្សាលើលទ្ធផលសិក្សាស្រាវជ្រាវដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចនៅខេត្តមណ្ឌលគិរី

-មន្ត្រី ១រូប បានចូលរួមសិក្ខាសាលាស្តីពីស្ថានភាពសារធាតុសរីរាង្គដី និងការបំភាយឧស្ម័នផ្ទះកញ្ចក់នៅរាជធានីភ្នំពេញ

-មន្ត្រី ៣រូប បានចូលរួម Training event under the CBIT project របស់អង្គការ FAO តាមរយៈ Zoom

-មន្ត្រី៣រូប បានចូលរួមសម្របសម្រួលសិក្ខាសាលាស្តីពីការប៉ាន់ប្រមាណតម្រូវការសមត្ថភាពសម្រាប់ពង្រឹងបណ្តាញស្ត្រីក្នុងសហគមន៍ព្រៃឈើ នៅខេត្តកំពង់ធំ

-មន្ត្រី ២រូប បានចូលរួមសិក្ខាសាលាស្តីពីការបង្កើនប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានព្រៃឈើកម្ពុជា

-មន្ត្រី ២រូប បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកវិទ្យាប្រើប្រាស់ Drone នៅខេត្តស្ទឹងត្រែង

-មន្ត្រី ២រូប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការកាន់កាប់អាស្រ័យផលរបស់សហគមន៍ អាស្រ័យផលលើធនធានធម្មជាតិ និងតួនាទី ភារកិច្ចរបស់អាជ្ញាធរមូលដ្ឋាន ដើម្បីនិរន្តរភាពធនធានធម្មជាតិសម្រាប់វិសោធ-នកម្មច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ នៅខេត្តព្រះវិហារ ខេត្តក្រចេះ និងខេត្តកំពត

-មន្ត្រី ២រូប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានព្រៃឈើកម្ពុជា នៅខេត្តកំពត

-មន្ត្រី ១រូប បានចូលរួមកិច្ចប្រជុំគណៈកម្មការប្រឹក្សាគម្រោងលើកទី២(PaFF3) ដែលរៀបចំដោយអង្គការ RECOFTC នៅខេត្តកំពង់ធំ

-មន្ត្រី ១រូប បានចូលរួមសមាជព្រៃឈើពិភពលោកលើកទី១៥(XV-World Forest Congress) និងព្រឹត្តិការណ៍អមជាមួយផ្សេងទៀត ដែលប្រព្រឹត្តិនៅទីក្រុងសេអ៊ូលនៃសាធារណៈរដ្ឋកូរ៉េ

-មន្ត្រី ១រូប បានចូលរួមកិច្ចប្រជុំស្តីពី The Korea-Mekong Cooperation Committee(KMFoCo) និង XV-World Forest Congress ដែលប្រព្រឹត្តិនៅទីក្រុងសេអ៊ូល សាធារណៈរដ្ឋកូរ៉េ

-មន្ត្រី ៣រូប បានចូលរួមប្រជុំលើកទី១៦ នៃក្រុមការងារសង្គមព្រៃឈើអាស៊ាន (16th AWG-SF) តាមរយៈ Video Conference ដែលប្រទេសឡាវ ជាម្ចាស់ផ្ទះ

-មន្ត្រី ១រូប បានចូលរួមកិច្ចប្រជុំចែករំលែកបទ-ពិសោធន៍ នៃការគ្រប់គ្រង ប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យភ្លើងព្រៃ តាមរយៈកម្មវិធី Zoom។

# សមិទ្ធផលអភិវឌ្ឍចម្ការព្រៃដាំ និងព្រៃឯកជន

## ១-ការគ្រប់គ្រងដីស្ថានីយដាំឈើ និងដីព្រៃសហគមន៍

### ១.១-ការងារចុះសិក្សាទីតាំងដីសម្រាប់បង្កើតស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើ និងសួនរុក្ខជាតិ

បានចុះសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត និង មន្ទីរជំនាញពាក់ព័ន្ធអនុវត្ត ការងារចុះបញ្ជីដីទំហំ ៤៧ហិកតា៦៧៧៥ ដើម្បីបង្កើតជាសួនរុក្ខជាតិស្ថិតក្នុងភូមិសាស្រ្ត ឃុំស្ដេចគង់ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត។

### ១.២-ការងារចុះពិនិត្យតាមដានស្ថានភាពចម្ការឈើដាំដីស្ថានីយដាំឈើ និងទីតាំងស្នើសុំចុះបញ្ជីព្រៃឯកជនៈ

-បានទទួលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន ០៥ប័ណ្ណ នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូង ស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានផ្ទៃដីសរុបទំហំ៣៥៨ហិកតា៦៦០៥



ការស្ថាបនាផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ ឆ្លងកាត់ចម្ការពូជផ្ចៀក

-បានចុះពិនិត្យចម្ការពូជឈើផ្ចៀក (ឆ្នាំ២០១៦) ដែលប៉ះពាល់ដោយសារការស្ថាបនាផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ ស្ថិតនៅភូមិអូរ១ ឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ផ្ទៃដីចម្ការឈើដែលបានប៉ះពាល់មានទំហំ ១៣ ៨១១ម៉ែត្រ២ ហើយផ្ទៃដីដែលនៅសល់មានទំហំ ៨៦ ២៩៥ ម៉ែត្រ២ ក្នុងនោះផ្នែកខាងជើងនៃផ្លូវសល់ទំហំ ១០ ២០០ម៉ែត្រ២ និងផ្នែកខាងត្បូងនៃផ្លូវនៅសល់ទំហំ ៧៦ ០៩៥ម៉ែត្រ២

-បានចុះពិនិត្យវាយតម្លៃការស្នើសុំប្រមូលផលឈើដាំទំហំ២០ហិកតានៅ ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើស្នួលទ្រេតមានភាគផលរដ្ឋ(១០%) ដើមឈើចំនួន ៦ ០២២ ដើម ស្មើនឹងថវិកាចំនួន ១២ ២៧៦៦០០រៀល និងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើតាបែន២ទំហំ១០ហិកតាមានភាគផលរដ្ឋ(១០%) ដើមឈើចំនួន ១ ៤៣១ដើម ស្មើនឹងថវិកាចំនួន ៣ ៦៥៤ ៥០០រៀល។

### ១.៣-ការងារចុះធ្វើសារពើភណ្ឌដំណុះកូនឈើដាំក្នុងចម្ការឈើចាស់តាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ

បានចុះធ្វើសារពើភណ្ឌក្នុងចម្ការឈើដាំសរុបទំហំ ២០០ហិកតា ក្នុងនោះនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើខ្នាររង្វាស់ ស្ថិតនៅក្នុងឃុំឃុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលបានដាំនៅក្នុងឆ្នាំ២០១៤ និង២០១៥ លើទំហំផ្ទៃដី១០០ហិកតា ដោយគិតជាមធ្យមភាគក្នុង ១ហិកតាមានកូនឈើចំនួន២៧២ដើម (តូចជាង៥ស.ម= ៣៨ដើម,ស្មើ៥-៩ស.ម=១៥០ដើម, ធំជាង១០ស.ម=៨៤ដើម) និងចម្ការឈើដាំនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរបឹងរូងស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលបានដាំនៅក្នុងឆ្នាំ២០១៥ លើទំហំផ្ទៃដី១០០ហិកតា ជាប្រភេទឈើគ្រញូង មានកូនឈើចំនួន២៦៨ដើម (តូចជាង៥ស.ម =២០០ដើម,ស្មើ៥-៩ស.ម=២៨ដើម, ធំជាង ១០ស.ម=៤០ដើម)។

## ២-ការអភិវឌ្ឍចម្ការឈើដាំ និងរុក្ខវប្បកម្ម

### ២.១-ការងារដាំឈើជាចម្ការថ្មី

ក្នុងឆ្នាំ២០២២ គម្រោងដាំឈើជាចម្ការថ្មីលើផ្ទៃដីទំហំ១២៥ហិកតា ដោយបានឈូសឆាយសម្អាតដីសម្រាប់ដាំឈើជាចម្ការថ្មីទំហំ១០៥ហិកតា (ខេត្តកំពង់ធំ និង ខេត្តកំពង់ឆ្នាំង) និងដាំឈើជាចម្ការបានទំហំ១០ហិកតានៅខេត្តកំពង់ធំ។





សកម្មភាពឈូសសម្អាតដី និងការងារដាំឈើ

## ២.២-ការងារថែទាំចម្ការឈើចាស់ឆ្នាំទី១ ដល់ឆ្នាំទី៥

បាន និងកំពុងថែទាំចម្ការឈើសរុប៧៤៧ហិកតា ក្នុងនោះចម្ការពូជឈើទំហំ៩៤ហិកតា ឡូត៍បង្ហាញកសិ-រុក្ខកម្មទំហំ៣៩ហិកតា ចម្ការឈើដាំទំហំ ៥៨៤ហិកតា និងចម្ការ រុក្ខទិវា៩កក្កដា សរុបទំហំ ៣០ហិកតា ស្ថិតក្នុងខេត្តកំពត កណ្តាល ព្រះសីហនុ កំពង់ធំ កំពង់ឆ្នាំង និងខេត្តក្រចេះដោយបានភ្ជួរចន្លោះរង និងសម្អាតស្មៅនៅតាមបណ្តាចម្ការឈើចាស់ទាំងអស់ដើម្បីការពារភ្លើងឆេះ។



សកម្មភាពភាពភ្ជួរសម្អាតចម្ការឈើក្នុង ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម

## ២.៣-ការងារបណ្តុះកូនឈើសម្រាប់ចែកចាយដល់កសិករដាំអាស្រ័យផល

បានបណ្តុះកូនឈើគ្រប់ប្រភេទសរុបចំនួន ៣៨២ ០៧៣ដើម(ថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្ត ចំនួន១៦៦ ០៧៣ដើម និងថ្នាលបណ្តុះកូនឈើចំនួន៦ នៃនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជនចំនួន ២១៦ ០០០ដើម និងចែកចាយសម្រាប់ដាំអាស្រ័យផលបានចំនួន ៧៤ ៨៧០ដើម (ថ្នាលបណ្តុះកូនឈើតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្ត ចំនួន ២ ៣៧០ដើម និងថ្នាលបណ្តុះកូនឈើចំនួន៦ចំនួន ៧២ ៥០០ដើម)។



កូនឈើដែលបានចែកចាយដល់កសិករដាំអាស្រ័យផល

## ២.៤ ការងាររៀបចំប្រារព្ធពិធីរុក្ខទិវាថ្នាក់ជាតិ

ការងាររៀបចំទីតាំងប្រារព្ធពិធីរុក្ខទិវា ០៩ កក្កដា ឆ្នាំ២០២២ នៅភូមិសំបួរមាស ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបងបានសម្រេចលទ្ធផល៩០% ដូចខាងក្រោមៈ

-បានឈូសសម្អាតដីសម្រាប់រៀបចំពិធី និងភ្ជួររាស់ដីសម្រាប់ដាំដុះកូនឈើលើ ផ្ទៃដីទំហំ១០ហិកតា

-បានរៀបចំផែនទីបង្ហាញទីតាំងសម្រាប់រៀបចំពិធីរុក្ខទិវា ប្លង់ពិធី និងផែនទីចម្ងាយផ្លូវពីតាមបណ្តាខេត្តផ្សេងៗមកកាន់ទីតាំងពិធី

-បានឈូសពង្រាបដីទំហំ១៣០ម×១៣០ម ក្នុងបរិវេណរៀបចំពិធី និងសាងសង់ប្រព័ន្ធផ្លូវចំនួន៩ខ្សែក្រាលកម្ទេចថ្មម៉ិចកម្រាស់៥ស.ម ក្នុងនោះមានៈ ផ្លូវមេ០១ខ្សែភ្ជាប់ពីផ្លូវកៅស៊ូចូលមកកាន់ទីតាំងពិធី( ៨ម x ២០០ម),

ផ្លូវដឹកជញ្ជូន០១ខ្សែ (៨ម x ១០០ម), ផ្លូវរងចែកប្លុកដាំដុះ ០៥ខ្សែ ក្នុងនោះ២ប្លុកជាផែនប្រជាពលរដ្ឋ និង ២ប្លុក ជាផែនសម្រាប់គណៈអធិបតីដាំដុះកូនឈើជានិមិត្តរូប(៥ម x ៤៥ម) និងផ្លូវរងកាត់ទទឹង០១ខ្សែ (៨ម x ១៣០ម)

-បានរៀបចំកាយប្រព័ន្ធរំដោះទឹកជុំវិញទីតាំងពិធី និងដាក់លូបង្ហូរទឹកបានចំនួន ៥កន្លែង បានរៀបចំទីតាំងទទួលគារវៈកិច្ចទំហំ ៣០ម x ២០ម និងបរិវេណសាងសង់វេទិកាទំហំ ៣០ម x ១៣០ម ក្រាលកម្ទេចថ្មម៉ិច

-បានរៀបចំទីតាំងពំនូកដីសម្រាប់រៀបចំដាំដើមឈើព្រះមហាក្សត្រទំហំ ៨ម x៨មx០,៦ម

-បានដឹកជញ្ជូនកូនឈើមកកាន់ទីតាំង និងដាំដុះជាចម្ការរុក្ខទិវារួចជាស្ថាពរ សរុបចំនួន ៨ ៩៤០ដើម ក្នុងនោះមានធ្នង់៣ ០០០ដើម ច្រេស១ ០០០ដើម គីនីន២ ០០០ដើម គ្រញូង២ ២០០ដើម ឈើទាល១៤០ដើម និងម៉ៃសាក់ ៦០០ដើម និងបានត្រៀមកូនឈើសម្រាប់ដាំជួសមួយចំនួនទៀត

-បានដាំដើមធ្នង់ធំៗ (កម្ពស់ ១,៥ម៉ែត្រឡើង) ចំនួន ៦៨៩ដើម

-បានផ្សាំដើមឈើសម្រាប់ព្រះមហាក្សត្រដាំចំនួន ០៤ដើម (ប្រភេទធ្នង់)

-បាន និងកំពុងរៀបចំសាងសង់ស្លាកបង្ហាញទីតាំងរុក្ខទិវា ធ្វើអំពីថ្ម។



ទីតាំងប្រារព្ធរុក្ខទិវា ៩ កក្កដា ឆ្នាំ២០២២

## ២.៥-រៀបចំ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធថ្នាលបណ្ដុះកូនឈើ

ថ្នាលបណ្ដុះកូនឈើថ្មីចំនួន០១ទីតាំង បាន និងកំពុងសាងសង់នៅក្នុងភូមិសាស្ត្រ ភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដោយទទួលលទ្ធផលសម្រេចបាន៥០% (ការឈូសឆាយដីទំហំ៣០០០ម៉ែត្រការ៉េសម្រាប់ថ្នាលបណ្ដុះកូនឈើ ថ្នាលលំហសម្រាប់ស្ដុកកូនឈើ និងទីធ្លាទំនេរ ដោយព័ទ្ធរបងខ្សែលួសប្រវែង ៤០០ម៉ែត្រ និងសាងសង់ខ្លោងទ្វារ និងទ្វារចំនួន០១ និងរៀបចំប្រព័ន្ធទឹក និងភ្លើង០១ឈុត)។



ការរៀបចំ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ
ថ្នាលបណ្ដុះកូនឈើក្នុងខេត្តបាត់ដំបង

## ២.៦ ការងារបង្កើតចម្ការពូជឈើក្នុងស្រុក

-បានបង្កើតចម្ការពូជឈើក្នុងស្រុក(ធ្នង់ កកោះ) បានឈូសឆាយសម្អាតដីទំហំ១០ហិកតាក្នុងស្ថានីយផ្សព្វផ្សាយ និងចាប់ផ្ដើមភ្ជួរ និងបន្តថែទាំកូនឈើត្រៀមសម្រាប់ដាំដុះក្នុងរដូវវស្សានៅខេត្តកំពង់ធំ

-បានប្រមូលគ្រាប់ពូជឈើក្នុងស្រុកសរុបចំនួន២៥៥ គីឡូក្រាម រួមមានប្រភេទ កកោះ១៤០គ.ក្រ ឈើទាល ៥០គ.ក្រ ផ្ចឹក៦៥គ.ក្រ ពីខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង និងបានចែកជូនអ្នកប្រើប្រាស់។



សកម្មភាពឈូសសម្អាតដី និងដាំឈើសម្រាប់
បង្កើតជាចម្ការឈើពូជក្នុងស្រុក

## ២.៧-ការងារពិសោធន៍ការបណ្ដុះអាកាស្យា (Acacia hybrid) និងប្រេងខ្យល់

ការពិសោធន៍បណ្ដុះអាកាស្យា និងប្រេងខ្យល់តាមរយៈការកាត់ត្រួយពីដើមមេ (Clone bank) ស្ថិតនៅស្ថានីយដាំឈើម្យៅក្រដាស ហ៊ុន សែន មានក ដោយបានកាត់តម្រឹមដើមមេអាកាស្យា និងប្រេងខ្យល់ (ពូជK7) ចំនួន ២០០០០ដើម និងបានបន្តថែទាំ ដោយដាក់ជី បោចស្មៅតាមដានសុខភាព ដើម្បីត្រៀមរៀបចំពិសោធន៍កាត់ត្រួយបណ្ដុះ និងរៀបចំឡូត៍ពិសោធន៍ការកាត់តម្រឹមត្រួយដើមមេប្រភេទប្រេងខ្យល់(K7) ចំនួន៦ឡូត៍ដែលមានទំហំ ៤ម x ៤,២ម មានកូនឈើសរុបចំនួន ៤០៩ដើម។



ការកត់ត្រាទិន្នន័យ វាស់កម្ពស់ អង្កត់ផ្ចិត និងចំនួនត្រួយសម្រាប់តាមដានពិសោធន៍

## ២.៨-ការងារដាំឈើវិស័យឯកជន ក្រុមហ៊ុនដៃគូសហការ និងលក្ខណៈគ្រួសារ



សកម្មភាពចុះត្រួតពិនិត្យក្រុមហ៊ុនដៃគូសហការ និងលក្ខណៈគ្រួសារ

-បានឈូសឆាយដីទំហំ ១ ៧៥០ហិកតា

-បានដាំឈើជាចម្ការថ្មីទំហំ ៥២៤ ហិកតា ៧៤

-បណ្ដុះកូនឈើបានចំនួន ១ ៧៩៨ ២៨៨ដើម។

## ២.៩ ការងារផ្សេងៗ

-ក្រុមការងារបានចុះពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ចនៅខេត្តកំពង់ស្ពឺ ព្រះសីហនុ កំពត បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ

-ចុះពិនិត្យផ្ទៀងផ្ទាត់សំណើរបស់ប្រជាពលរដ្ឋ សុំកាត់ឆ្វៀលដីចេញពីគម្របព្រៃឈើឆ្នាំ២០០២ ដែលមានផលប៉ះពាល់ជាមួយសម្បទានដីសេដ្ឋកិច្ចក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី

-ក្រុមការងារនាយកដ្ឋានបានចូលរួមចុះស្រាវជ្រាវទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងទន្ទ្រានដីព្រៃ ដោយសហការជាមួយរដ្ឋបាលខេត្តមណ្ឌលគិរី និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត មណ្ឌលគិរី បានដកហូតផ្ទៃដីទំហំ៦ ៧៧៩ហិកតា និងដកហូតបង្គោលដាំជារបងប្រវែង៦៤ ១៩២ម៉ែត្រ (បង្គោលឈើចំនួន ១៨២៤៩ដើម បង្គោលថ្មចំនួន៦ ៧១៥ដើម របារថ្មចំនួន ៨១៧ដើម របារឈើប្រវែង ៣ ៤៨៣ម៉ែត្រ លួសបន្លាប្រវែង៧១ ៨៩០ម៉ែត្រ លួសសំណាញ់២ ១០៧ម៉ែត្រ និងប្រមូលបង្គោលរបងឈើដែលគេគរទុកចំនួន ៤៤៧ដើម)

-បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្ដីពី “ មគ្គុទ្ទេសក៍បច្ចេកទេស សម្រាប់ការបង្កើត និងអភិវឌ្ឍន៍ចម្ការឈើដាំនៅកម្ពុជា” នៅខេត្តសៀមរាប

-បានចូលរួមចុះសិក្សាពីប្រភពចម្ការឈើដាំពេលបច្ចុប្បន្ន សិក្សាតំបន់សក្ដានុពលសម្រាប់អនុវត្តគម្រោងរេដបូកនៅខេត្តកំពង់ធំ ព្រះវិហារ និង ខេត្តក្រចេះ និងសិក្សាពីប្រភពចម្ការឈើដាំពេលបច្ចុប្បន្ន រោងសន្និធិកែច្នៃឈើដាំ និងសិក្សាពីខ្សែច្រវាក់ទីផ្សារផលិតផលឈើដាំនៅខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ

-បានរៀបចំទិន្នន័យប្រវត្តិ និងលទ្ធផលការងារដាំឈើរបស់ក្រុមហ៊ុនដៃគូសហការ និងលក្ខណៈគ្រួសារ ព្រមទាំងវាយតម្លៃការអនុវត្តការងារធៀបនឹងផែនការមេរបស់ក្រុមហ៊ុនដើម្បីជំរុញ និងពង្រឹងការងារដាំឈើដៃគូសហការ

-បានបោះពុម្ពសៀវភៅគោលការណ៍ណែនាំស្ដីពីការបង្កើត និងចុះបញ្ជីព្រៃឯកជនចំនួន២០០ក្បាលសម្រាប់ចែកជូនមន្ត្រីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងអ្នកពាក់ព័ន្ធ។

# សមិទ្ធផលការងារផ្សព្វផ្សាយវិស័យព្រៃឈើ-សត្វព្រៃ

-ដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្សព្វផ្សាយព្រៃឈើឲ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ក្រុមការងារបានរៀបចំបោះពុម្ព និងចែកផ្សាយសម្ភារផ្សព្វផ្សាយព្រៃឈើដែលបានផលិតរួចជាបន្តបន្ទាប់ទៅតាមបណ្តាអង្គភាព និងស្ថាប័នមួយចំនួន ព្រមទាំងបានបោះពុម្ព និងចែកផ្សាយទស្សនាវដ្តីព្រៃឈើលេខ៦៥

-បានប្រែសម្រួលអត្ថបទបច្ចេកទេសជាភាសាខ្មែរ ស្តីពី រុក្ខជាតិកម្រដែលមានរូបរាងប្លែកៗស្រដៀងទៅនឹងសត្វ ឬរបស់អ្វីម្យ៉ាង (Exotic Plants That Look Like Animals or Something else) សម្រាប់ដាក់បញ្ចូលក្នុងទស្សនាវដ្តីព្រៃឈើ

-បានរៀបចំរចនារូបភាពដែលប្រមូលបានពាក់ព័ន្ធក្នុងវិស័យព្រៃឈើ សត្វព្រៃសម្រាប់ដាក់តាំងពិព័រណ៍បង្ហាញជាសាធារណៈក្នុងព្រះរាជពិធីរុក្ខទិវា ៩ កក្កដា ឆ្នាំ២០២២ នៅខេត្តបាត់ដំបង

-បានរចនារូបភាពដែលមានខ្លឹមសារក្នុងវិស័យព្រៃឈើដើម្បីបោះពុម្ពលើអាវយឺត និងមួកសម្រាប់ប្រារព្ធក្នុងព្រះរាជពិធីរុក្ខទិវា ៩ កក្កដា ឆ្នាំ២០២២ នៅខេត្តបាត់ដំបង

- បានបិទផ្សាយឡើងវិញជាសាធារណៈនៅរដ្ឋបាលព្រៃឈើ ស្តីពី ពិធីរំលឹកខួបទី១១១ នៃទិវាអន្តរជាតិនារី ៨មីនា និងបានចូលរួមថតរូបបិទផ្សាយជាសាធារណៈនៅរដ្ឋបាលព្រៃឈើ ស្តីពីកិច្ចប្រជុំបូកសរុបលទ្ធផលការងារវិស័យព្រៃឈើឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២២

-បានចុះរៀបចំកម្មវិធីប្រជុំផ្សព្វផ្សាយស្តីពីលើកកម្ពស់ការយល់ដឹងអំពី គុណប្រយោជន៍ទូទៅនៃព្រៃឈើជាសាធារណៈ និងការងារបច្ចេកទេសគ្រប់គ្រងព្រៃឈើឡើងវិញ បានចំនួន០៤វគ្គ ស្ថិតក្នុងខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង

-កំពុងធ្វើបញ្ជីសារពើភណ្ឌឯកសារក្នុងបណ្ណាល័យរដ្ឋបាលព្រៃឈើ ដើម្បីត្រៀមដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ រៀបចំសម្រួលទីតាំងផ្ទុកឯកសារទៅតាមប្រភេទនីមួយៗឱ្យបានត្រឹមត្រូវ និងងាយស្រួលគ្រប់គ្រង

-បានថែរក្សា និងសម្អាតបណ្ណាល័យរដ្ឋបាលព្រៃឈើជាប្រចាំដើម្បីផ្តល់ភាពងាយស្រួល និងជាសុកភាពដល់អ្នកស្រាវជ្រាវ និងអ្នកមានចំណាប់អារម្មណ៍មកសិក្សាស្វែងយល់ និងបានសម្របសម្រួលចែករំលែកព័ត៌មាន និងផ្តល់ឯកសារពាក់ព័ន្ធវិស័យព្រៃឈើបន្ថែមទៀតដល់អ្នកស្រាវជ្រាវនានាទៅតាមតម្រូវការផ្សេងៗ។



វគ្គបណ្តុះបណ្តាលស្តីពីគុណប្រយោជន៍ទូទៅនៃជីវចម្រុះព្រៃឈើជាសាធារណៈ និងការងារគ្រប់គ្រងព្រៃឈើឡើងវិញនៅសហគមន៍ព្រៃឈើតាសាញ់ត្បូង ឃុំអូរតាសាញ់ ស្រុកសំឡូត ខេត្តបាត់ដំបង




ក្រុមការងារចែកឯកសារ និងរូបថ្លុកអប់រំព្រៃឈើបន្ទាប់ពីបានបញ្ចប់វគ្គបណ្តុះបណ្តាល ស្តីពីគុណប្រយោជន៍ទូទៅនៃព្រៃឈើជាសាធារណៈ និងការងារបច្ចេកទេសបង្កើតព្រៃឈើឡើងវិញនៅសហគមន៍មូលដ្ឋាន ឃុំត្នោតជ្រុំ ស្រុកក្រគរ ខេត្តពោធិ៍សាត់

# សមិទ្ធផលការងារស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

## ក. គម្រោងការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវសេនេទិចព្រៃឈើ ដើម្បីស្តារប្រភេទឈើសំខាន់ៗនៅកម្ពុជា

-គម្រោងការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវសេនេទិចព្រៃឈើ ដើម្បីស្តារប្រភេទឈើសំខាន់ៗនៅកម្ពុជា បានសម្អាតស្មៅតាមគល់កូនឈើក្នុងឡូត៍ពិសោធន៍ បានចំនួន ១.២០០ដើម ត្រីមែកកូនគ្រញូងបានទំហំ ០១ហិកតា ភ្ជួរសម្អាតតាមចន្លោះរងកូនឈើគ្រញូងក្នុងតំបន់ដាំស្តារឡើងវិញបានចំនួន ១០ហិកតា និងបានប្តូរថង់កូនឈើក្នុងថ្នាលបណ្តុះបានចំនួន១.៥០០កូន



សកម្មភាពភ្ជួរសម្អាតស្មៅតាមចន្លោះរងកូនឈើ

-បានចុះប្រមូលគ្រាប់ពូជឈើក្រលាញ់ចំនួន ១០ដើម ជ្រៃ ៣ដើម ត្របែកព្រៃ១១ដើម និងស្វាយ១០ដើម

-បន្តការងារសាងសង់អគារមជ្ឈមណ្ឌលអនុវត្តការបង្កាត់ប្រភេទពូជឈើ

-បន្តបានថែទាំ ដាក់ជី ស្រោចទឹក និងបាញ់ថ្នាំកំចាត់សត្វល្អិត នៅក្នុងទីតាំងគម្រោង Eco-Forest Farm នៅខេត្តសៀមរាប

-បន្តសកម្មភាពធ្វើការចាក់ធ្នឹមក្រវាត់គ្រឹះនៃអគារមណ្ឌលពត៌មាន និងធ្វើការសាងសង់ផ្លូវ និងប្រឡាយ នៅក្នុងទីតាំង Eco-Forest Farm

-បានធ្វើការចាក់ធ្នឹមក្រវាត់គ្រឹះនៃអគារមណ្ឌលពត៌មាន និងអប់រំ និងធ្វើការសាងសង់ផ្លូវ និងប្រឡាយនៅក្នុងទីតាំងសួនអភិរក្សសេនេទិក នៃប្រភេទឈើសំខាន់ៗនៅកម្ពុជា

-បានរៀបដីសម្រាប់ស្នូងដីចំនួន១០.០០០ថង់ ត្រៀមបណ្តុះកូនឈើ





សកម្មភាព ប្តូរថង់ និងសម្អាតស្មៅកូនឈើក្នុងថ្នាល



ធ្វើផ្លូវនៅទីតាំងសួនអភិរក្សសេនេទិក នៃប្រភេទឈើសំខាន់ៗ

-បានបញ្ជូនរបាយការណ៍វឌ្ឍនភាពគម្រោងប្រចាំឆ្នាំ២០២១ និងផែនការសកម្មភាពគ្រោងសម្រាប់ឆ្នាំ២០២២ ដល់លេខាធិការដ្ឋានអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AFoCO Secretariat)

-បានឈូសសម្អាតផ្លូវភ្លើងក្នុងឡូត៍ពិសោធន៍នានា សរុបទំហំ១៨ហិកតា

-បានភ្ជួរសម្អាតស្បូវតាមចន្លោះរងគ្រញូង និងផ្លូវភ្លើងព័ទ្ធជុំវិញតំបន់ស្តារព្រៃឈើឡើងវិញបានទំហំ១៥ហិកតា

-បានរៀបចំថង់ដីសម្រាប់បណ្តុះកូនឈើបានចំនួន ២៥៤៨ថង់ និងប្តូរថង់ដីកូនឈើបានចំនួន១២០៦ដើម





ការកាត់សម្អាតផ្លូវភ្លើង និងភ្ជួរសម្អាតតាមចន្លោះរងគ្រញូង



ច្រក់ដីដាក់ថង់សម្រាប់ស្ទូងកូនឈើ

## ខ.ការសិក្សាស្រាវជ្រាវទីជម្រកសត្វព្រៃ និងធ្វើការដោះលែងសត្វព្រៃ ចូលរួមជាមួយអង្គការសម្ព័ន្ធមិត្តសត្វព្រៃនៅខេត្តកោះកុង និងខេត្តសៀមរាប

លទ្ធផលក្នុងការចូលរួមជាមួយអង្គការសម្ព័ន្ធមិត្តសត្វព្រៃគាំទ្រសហគមន៍ព្រៃឈើប្រាំបីមុមខេត្តកំពង់ស្ពឺមាន៖ ជួបប្រជុំ បែងចែកក្រុមល្បាតសហគមន៍ជាពីរក្រុមឆ្លាស់វេនគ្នាស្វែងរកអន្ទាក់ទាំងក្នុង និងក្រៅដែនព្រៃសហគមន៍។ ក្រុមល្បាតព្រៃទាំងពីរបានចុះល្បាតបានចំនួន ២៤លើក ស្មើនឹង១៦៣នាក់ បានរកឃើញអន្ទាក់ចំនួន ៨២ខ្សែនៅតាមចម្ការអំពៅ និងព្រៃមាត់អូរ។ មានការលំបាកចំពោះការបញ្ចៀសហ្វូងទន្សោងចេញមកស៊ីអំពៅនៅចម្ការភាគខាងត្បូងនាពេលយប់ ហើយម្ចាស់កសិដ្ឋានបានព្រមានសម្លាប់សត្វទាំងនោះ។ អង្គការសម្ព័ន្ធមិត្តសត្វព្រៃមានគម្រោងនឹងជួយជាបដិភាគដោះស្រាយបញ្ហានេះ ប្រសិនបើមានសំណើជាផ្លូវការពីរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល និងមានការចូលរួមពីម្ចាស់កសិដ្ឋានផងដែរ។




ហ្វូងទន្សោងមករកទឹកអាងដែលដាក់សម្រាប់សត្វក្នុងព្រៃ

## គ.គម្រោងសមាហរណកម្មផែនការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីព្រៃឈើ និងការធ្វើគម្រោងបង្ហាញស្តីពីការស្តារព្រៃឈើនៅក្នុងមហាអនុតំបន់មេគង្គ

គម្រោងបានអនុវត្តការងារនៅសហគមន៍ព្រៃឈើដំរីចាក់ធ្លូក ភូមិដកពរ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ សកម្មភាពមួយចំនួនបានអនុវត្តមានដូចជាការចុះពិនិត្យ និងថែទាំកូនឈើក្នុងឡូត៍ស្តារព្រៃឈើទំហំ ១៦ហិកតា នៅសហគមន៍ព្រៃឈើដំរីចាក់ធ្លូក ជាលទ្ធផល

សង្កេតឃើញថា កូនឈើនៅក្នុងឡូត៍នេះលូតលាស់ល្អមាន ចំនួន ៦០% កូនឈើលូតលាស់ល្អបង្គួរមានចំនួន ៣០% និងងាប់មានចំនួន ១០%។ ក្រុមការងារល្បាតព្រៃបានបន្ត ចុះទប់ស្កាត់ភ្លើងព្រៃក្នុងសហគមន៍ ដោយទទួលលទ្ធផល ជោគជ័យ។ ក្រុមការងារបានជួបប្រជុំពិភាក្សាជាមួយប្រធាន ក្រុមប្រើប្រាស់ទឹកក្នុងសហគមន៍ ដោយបានលើកជាផែន ការថ្មីរៀបចំចុះបញ្ជីឈ្មោះអ្នកប្រើប្រាស់ទឹកឡើងវិញ ផ្តាច់ បណ្តាញចំពោះសមាជិកណាដែលអាក់ខានក្នុងការបង់ប្រាក់ ឬ មិនបានចុះឈ្មោះប្រើប្រាស់បន្ត និងរៀបចំបញ្ជីបង់ប្រាក់ថ្លៃ ប្រើប្រាស់ទឹកជារៀងរាល់ ១៥ថ្ងៃម្តង។

ជាមួយគ្នានេះ គម្រោងបាន៖

-បានចុះពិនិត្យការងារបណ្តុះកូនឈើសរុបបានចំនួន ៣.១៥០ដើម មានដូចជា គ្រញូង បេង និងនាងនួន





ការចុះពិនិត្យការលូតលាស់កូនឈើក្នុងឡូត៍ Miyawaki

-បាន និងកំពុងរៀបចំកែសម្រួលសៀវភៅស្តីពីបច្ចេក-ទេសការគ្រប់គ្រង និងស្តារព្រៃឈើ ឯកសារទស្សនទាន សង្ខេបនៃការបញ្ជ្រាបផែនការគ្រប់គ្រងព្រៃសហគមន៍ និង សៀវភៅបទពិសោធន៍អំពីការស្តារឡើងវិញការធ្វើសុរុក្ខកម្ម ព្រៃឈើ និងឯកសារស្រាវជ្រាវផ្សព្វផ្សាយជាច្រើនទៀត

-បាន និងកំពុងរៀបចំឯកសារលិខិតស្នើសុំ ដើម្បី រៀបចំសិក្ខាសាលាចំនួន ០៣ មានដូចជា ១/ការចែករំលែក បទពិសោធន៍ពីការអនុវត្តគម្រោងទាក់ទងនឹងការប្រើប្រាស់ Forest Watcher System (Online meeting-Zoom) ២/ការអនុវត្តពាក់កណ្តាលគម្រោង ការចុះទស្សនកិច្ចសិក្សា ទីតាំងគម្រោង និង ៣/សិក្ខាសាលាបញ្ចប់គម្រោង។

-សួនបន្លែលក្ខណៈគ្រួសាររបស់សហគមន៍ព្រៃឈើ ក្រាំងសេរី ៖ ថ្នាក់ដឹកនាំ និងមន្ត្រីអនុវត្តគម្រោង បានចុះ ត្រួតពិនិត្យការងារដាំដុះបន្លែ រួមមាន ត្រកួន សាលាដ ស្ពៃចង្កឹះ ជីវ៉ាន់ស៊ុយ ត្រសក់ សណ្តែកវែង ចេក ជីនាងវង នៅភូមិក្រាំងសិរី ឃុំគិរីវ័ន្ត ខេត្តកំពង់ស្ពឺ។






ទិន្នផលបានពីការអនុវត្តសួនបន្លែជាលក្ខណៈគ្រួសារ

### ឃ.គម្រោងបង្កើតមជ្ឈមណ្ឌលអនុវត្តការបង្កាត់ប្រភេទពូជឈើមានតម្លៃនៅប្រទេសកម្ពុជា

នៅខែមេសា ឆ្នាំ២០២២ គម្រោងបានសម្រេចការ ងារសំខាន់ៗរួមមាន៖ បានចុះសហការជាមួយសហគមន៍

មូលដ្ឋាន និងមន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់ក្រោមជាតិ ប្រមូលគ្រាប់ពូជឈើពីដើមមេផ្តល់ពូជមាន ខ្នុរព្រៃចំនួន ៣ដើម ក្រវាញចំនួន ៣គុម្ព មក្លឿចំនួន ៩ដើម ស្រគំចំនួន ៩ដើម និងក្រឡាញ់ចំនួន ៨ដើម ពីខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង និងខេត្តសៀមរាប។ ទន្ទឹមការងារប្រមូលគ្រាប់ពូជឈើ គម្រោងបាន និងកំពុងសាងសង់អគារមជ្ឈមណ្ឌលបង្កាត់ប្រភេទពូជឈើ សម្រេចបានប្រហែល ៥០ភាគរយ និងបានចាក់គ្រឹះរៀបចំប្រព័ន្ធស្រោចស្រពផ្នែកខាងក្រោមនៃថ្នាលបណ្ដុះកូនឈើទំនើប (Greenhouse) រួចរាល់។ បន្តសាងសង់អគារមជ្ឈមណ្ឌលព័ត៌មាន និងធ្វើការសាងសង់ផ្លូវ និងប្រឡាយទឹក បន្តថែទាំ ដាក់ជី ស្រោចទឹក បាញ់ថ្នាំកំចាត់សត្វល្អិតនៅក្នុងទីតាំងគម្រោង Eco-Forest Farm និងបន្តសកម្មភាពសាងសងអគារមណ្ឌលព័ត៌មាន និងអប់រំ និងធ្វើការសាងសង់ផ្លូវ និងប្រឡាយ នៅក្នុងទីតាំងសួនអភិរក្សសេនេទិក នៃប្រភេទឈើសំខាន់ៗនៅកម្ពុជា។





សកម្មភាពសាងសង់អគារមជ្ឈមណ្ឌលបង្កាត់ប្រភេទពូជឈើ និងថ្នាលបណ្ដុះកូនឈើទំនើប





សកម្មភាពចុះបេះប្រមូលគ្រាប់ពូជឈើពីដើមមេ





ការធ្វើផ្លូវ និងអគារមណ្ឌលព័ត៌មាន និងអប់រំនៅទីតាំងគម្រោង Eco-Forest Farm និងទីតាំងសួនអភិរក្សសេនេទិក នៃប្រភេទឈើសំខាន់ៗនៅកម្ពុជា

# សមិទ្ធផលការងារឧស្សាហកម្មព្រៃឈើ និងសហប្រតិបត្តិការអន្តរជាតិ

## ១-ការងារឧស្សាហកម្មព្រៃឈើ

-បានចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ(ច្រកចេញចូលតែមួយ) ចំនួន ០២កន្លែង ស្ថិតនៅក្នុងខេត្តកំពត និងខេត្តតាកែវ និងពន្យាសុពលភាពចំនួន ១០កន្លែង ស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តកណ្ដាល ស្វាយរៀង បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ ព្រៃវែង កំពង់ធំ និងខេត្តសៀមរាប



ការកែច្នៃគ្រឿងសង្ហារិម ស្ថិតនៅរាជធានីភ្នំពេញ



ការកែច្នៃវីនៀរ ស្ថិតនៅក្នុងខេត្តកំពង់ធំ

-បានពិនិត្យសំណើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើ ចំនួន ០៣កន្លែង ស្ថិតនៅក្នុងខេត្តស្ទឹងត្រែង និងខេត្តព្រះសីហនុ និងពន្យាសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើ និងរោងសិប្បកម្មកែច្នៃចញ្ច្រាំកម្ទេចឈើដាំចំនួន ០៧កន្លែង ស្ថិតនៅក្នុងរាជធានីភ្នំពេញ ខេត្តត្បូងឃ្មុំ កំពង់ធំ សៀមរាប ព្រះសីហនុ និងខេត្តព្រះវិហារ

-បានសិក្សាអត្រាកែច្នៃកូនឈើទំហំគល់១៥-៣០ស.ម ចំនួន ២ក្រុមហ៊ុន

## ២-ការងារពាណិជ្ជកម្មផលិតផលព្រៃឈើ

### ក.ការនាំចេញផល អនុផលព្រៃឈើ

-បាននាំចេញផលិតផលរានទេវតា និងឈើអារកែច្នៃទៅក្រៅប្រទេស មានបរិមាណចំនួន ៦៩៨ម៣ ជ័រទឹកចំនួន ៧៨តោន ធ្យូងអាកាស្យាចំនួន ៨១តោន និងចំណាំងកម្ទេចឈើចំនួន ៤ ៥០០តោន ដោយក្រុមហ៊ុនចំនួន០៨

-បានផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញ ជូនក្រុមហ៊ុនចំនួន០៩ មានបរិមាណឈើកែច្នៃចំនួន ៩៨៤ម៣ ចំណាំងកម្ទេចឈើចំនួន ៤ ៥០០តោន គ្រឿងសង្ហារិម ឬស្សីកែច្នៃចំនួន ៤២តោន ជ័រទឹកចំនួន ៥៦តោន និងធ្យូងអាកាស្យាចំនួន ៨៨តោន។



ផលិតផលរានទេវតាសម្រាប់នាំចេញ



ការចុះពិនិត្យផលិតផលឈើដាំកែច្នៃសម្រាប់នាំចេញ

## ខ.ការនាំចូលផល អនុផលព្រៃឈើ

-បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ១ ០១៦ម៣ ដោយក្រុមហ៊ុនចំនួន០២

-បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូល ជូនក្រុមហ៊ុនចំនួន០២ មានបរិមាណឈើកែច្នៃ (MDF, Wood Panel, Chanfuta) សរុបចំនួន ៩៥២ម៣។



ផលិតផលឈើនាំចូល (MDF និង Wood Panel)

## ៣-ការងារឥណទានកាបូនព្រៃឈើ និងការប្រែប្រួលអាកាសធាតុ

-បានចូលរួមកិច្ចប្រជុំរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តរបាយការណ៍ ការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ នៅលើប្រព័ន្ធត្រួតពិនិត្យក្របខ័ណ្ឌតម្លាភាព (NDC Tracking System) សម្រាប់ឆ្នាំ២០២១។

-បានចូលរួមកិច្ចប្រជុំក្រុមការងារការប្រែប្រួលអាកាសធាតុរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណង (១).បង្ហាញ និងពិនិត្យផ្តល់ធាតុចូលទៅលើផែនការសកម្មភាព ស្តីពីការប្រែប្រួលអាកាសធាតុរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៦-២០២០ (២).ពិភាក្សាលើអនុសាសន៍សម្រាប់ផែនការសកម្មភាព ស្តីពីការប្រែប្រួលអាកាសធាតុរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២១-២០៣០ (៣).ឯកភាពលើវិធីសាស្ត្រក្នុងការសម្របសម្រួលការបង្កើតផែនការសកម្មភាព ស្តីពីការប្រែប្រួលអាកាសធាតុបន្ទាប់ទៀត និង(៤).បង្ហាញពីលទ្ធផលគំរូក្នុងការលើកចរិកាសម្រាប់បង្កើតបច្ចេកវិទ្យាអាកាសធាតុវៃឆ្លាតលើសាកវប្បកម្ម ដំណាំ និងផ្តល់ធាតុចូល។

-បានចូលរួមសិក្ខាសាលាស្តីពី "Post COP26 Synthesis of Key Outcomes for Land Use Sector in Asia-Pacific" ក្នុងគោលបំណង (១).ពិភាក្សាពីបញ្ហាសំខាន់ៗដែលបានលើកឡើងក្នុង COP26 ពាក់ព័ន្ធនឹងទេសភាពព្រៃឈើ កសិកម្ម និងការប្រែប្រួលអាកាសធាតុ (២).ពិភាក្សា និងកំណត់ចំណុចនានាដើម្បីជំរុញដំណើរការក្នុងវិស័យប្រើប្រាស់ដី ដើម្បីរៀបចំសម្រាប់ COP27 នៅប្រទេសអេហ្ស៊ីប និង (៣).ផ្សព្វផ្សាយព័ត៌មានអំពីលទ្ធផលពី COP26 ដល់អ្នកពាក់ព័ន្ធនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

-បានចូលរួមក្នុងកម្មវិធីបរិស្ថានពិភពលោកនៅទីក្រុង Stockholm ប្រទេសស៊ុយអែត ដែលរៀបចំឡើងដោយកម្មវិធីបរិស្ថាននៃអង្គការសហប្រជាជាតិ (UNEP) និងក្រុមហ៊ុន Everland LLC ចាប់ពីថ្ងៃទី០១-០៦ ខែមិថុនា ឆ្នាំ២០២២ ក្នុងគោលបំណងក្នុងការបង្ហាញអំពីសកម្មភាពនានារបស់គម្រោងរេដបូកនានានៅក្នុងពិភពលោក ក្នុងនោះក៏មានគម្រោងរេដបូកទំរីងផងដែរ ដើម្បីចូលរួមក្នុងការបញ្ឈប់ការបាត់បង់ព្រៃឈើត្រឹមឆ្នាំ២០៣០។

-បានចូលរួមអនុវត្តគម្រោងរេដបូកកម្ពុជា-កូរ៉េ ដែលមានទីតាំងនៅខេត្តកំពង់ធំ ដោយផ្តោតទៅលើការងារផលិតឥណទានកាបូនព្រៃឈើ។ ក្រុមការងារគម្រោងត្រូវអនុវត្តការងារនៅទីវាលដើម្បីទទួលបានឥណទានកាបូនព្រៃឈើ និងកាត់បន្ថយការបាត់បង់ព្រៃឈើ និងការងារបង្កើនជីវភាពរបស់សហគមន៍មូលដ្ឋាន។



កិច្ចប្រជុំពិភាក្សាការងាររវាងក្រុមការងារគម្រោងរេដបូកទំរីង និងឯកឧត្តមអភិបាលខេត្តកំពង់ធំ




មន្ត្រីទំនាក់ទំនងនៃគម្រោងរេដបូកទំរីងបានចូលរួមក្នុងកម្មវិធីបរិស្ថានពិភពលោកនៅទីក្រុង Stockholm ប្រទេសស៊ុយអែត

## ៤- ការងារសហប្រតិបត្តិការអន្តរជាតិ

-បានពិនិត្យ និងផ្ដល់មតិលើសំណើសុំ Endorsement Outline of the ASEAN Guiding Principles for Effective Social Forestry/Community Practices និងសំណើអញ្ជើញចូលរួមកិច្ចសន្ទនានយោបាយស្ដីពី "Key highlights of the UNFCC COP26 and implications for sustainable peatland and haze mitigation in Southeast Asia" back-to-back with the launch of the ASEAN Haze Portal ព្រមទាំងសំណើសុំការឯកភាពលើ Draft Study Report on Nature-based solutions (NbS) in ASEAN across forest, bare land and coastal ecosystems របស់លេខាធិការដ្ឋានអាស៊ាន

-បានរៀបចំវគ្គបណ្ដុះបណ្ដាល ស្ដីពីនីត្យានុកូលភាពនៃការប្រមូល ការដឹកជញ្ជូន និងការនាំចេញ-នាំចូលឈើនៅកម្ពុជា

-បានចូលរួមសិក្ខាសាលាពីចម្ងាយ (ZOOM) (Virtual Workshop)ស្ដីពី The Initial Workshop for the Development of a Ten-Year Investment Framework for Haze-Free, Sustainable Land Management in Southeast Asia

-បានពិនិត្យ និងឆ្លើយទៅអង្គការ FAO លើសំណើអញ្ជើញចូលរួមកិច្ចប្រជុំស្ដីពី Asia-Pacific Forestry Commission (APFC)លើកទី២៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២-២៥ ខែកុម្ភៈ ឆ្នាំ២០២២ នៅទីក្រុង Ulaanbaatar ប្រទេសម៉ុងហ្គោលី តាមរយៈប្រព័ន្ធបញ្ជូនសម្លេង និងរូបភាព

-បានចាត់មន្ត្រីចូលរួមសិក្ខាសាលាតាមប្រព័ន្ធអនឡាញស្ដីពី "ASEAN Workshop on Assuring Food Safety and Security"

-បានពិនិត្យ និងឆ្លើយតបទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីសំណើសុំរបាយការណ៍វឌ្ឍនភាពស្ដីពីការអនុវត្តគម្រោងក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងដៃគូអភិវឌ្ឍន៍ និងអំពីសំណើផ្ដល់ធាតុចូល និងមតិយោបល់លើសេចក្ដីព្រាងលេខាធិការដ្ឋានបណ្ដោះអាសន្ន របស់ ACMECS

-បានពិនិត្យ និងឆ្លើយតបអំពីសំណើផ្ដល់ របាយការណ៍វឌ្ឍនភាព ស្ដីពីកិច្ចសហប្រតិបត្តិការជាមួយសហភាពអឺរ៉ុប (ជលផល និងវារីវប្បកម្ម IUU Fishing, ព្រៃឈើ FLEGT និងសម្បទានដីសេដ្ឋកិច្ច ELC និងអំពីសំណើផ្ដល់ធាតុចូលលើសេចក្ដីព្រាងផែនការសកម្មភាពដើម្បីអនុវត្តជាដៃគូយុទ្ធសាស្ត្រអាស៊ាន-សហភាពអឺរ៉ុប

-បានពិនិត្យ និងឆ្លើយតបអំពីសំណើសុំបញ្ជីអនុវត្តគម្រោងនានារបស់កម្ពុជា ដែលភាគីមិត្តចិនបានធ្វើ ដើម្បីអនុវត្តបញ្ជីការងារបន្ទាន់(To-Do-List) និងសំណើសុំផ្ដល់របាយការណ៍វឌ្ឍនភាពការងារក្រោយកិច្ចប្រជុំលើកទី២ គណៈកម្មការសេដ្ឋកិច្ចចម្រុះកម្ពុជា-តួកគី ព្រមទាំងសំណើពិនិត្យ និងផ្ដល់របាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការកម្ពុជា-ឆេក

-បានរៀបចំលិខិតទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីសំណើសុំគោលការណ៍អនុញ្ញាតចាត់មន្ត្រីចូលរួមមហាសន្និបាតព្រៃឈើពិភពលោកលើកទី១៥ នៅសាធារណរដ្ឋកូរ៉េ អំពីសំណើចាត់តំណាងចូលរួមក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍(វ.ប.ន) និងអំពីសំណើចាត់មន្ត្រីបង្គោលចំនួន ០១រូប ដើម្បីចូលរួមរៀបចំក្រុមការងារកម្ពុជា-បេឡារុស

-បានពិនិត្យ និងឆ្លើយតបទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីសំណើពិនិត្យ និងផ្ដល់មតិលើលិខិតស្ដីពី "Introduce our intention to cooperate with the Forest Restoration Project of Cambodia"

-បានរៀបចំលិខិតទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីសំណើចាត់មន្ត្រីបង្គោលចូលរួមកិច្ចប្រជុំ

លើកទី៧ នៃក្រុមការងារអាស៊ាន-ឥណ្ឌាលើវិស័យកសិកម្ម និងព្រៃឈើ តាមរយៈប្រព័ន្ធវីដេអូពីចម្ងាយ និងអំពីសំណើសុំចាត់តំណាងចំនួន០៣រូប ចូលរួមក្នុងក្រុមការងារអន្តរក្រសួងដើម្បីចុះពិនិត្យ សិក្សា និងវាយតម្លៃករណីស្នើសុំប្រើប្រាស់ដីគម្របព្រៃឈើឆ្នាំ២០២២ ព្រមទាំងសំណើសុំចាត់មន្ត្រីចំនួន ០១រូប ដើម្បីចូលរួមជាសមាជិកក្រុមពិភាក្សា (Panelist) ក្នុងទិវាថ្ងៃបរិស្ថានពិភពលោក(World Environment Day)

-បានរៀបចំលិខិតទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អំពីសំណើសុំចាត់មន្ត្រីរដ្ឋបាលព្រៃឈើចំនួន ០៥រូប ដើម្បីចូលរួមកិច្ចពិភាក្សាទ្វេភាគីស្តីពី "ការពង្រឹងកិច្ចសហប្រតិបត្តិការលើលក្ខន្តិកៈពាណិជ្ជកម្មឈើ និងការតាមដានត្រួតពិនិត្យព្រៃឈើនៅតាមតំបន់ព្រំដែនកម្ពុជា-ថៃ" នៅខេត្តអ៊ូប៊ុន រ៉ាឆាថានី ប្រទេសថៃ

-បានពិនិត្យ និងផ្តល់មតិលើសេចក្តីជូនព័ត៌មានការប្រកាសអាហាររូបករណ៍ Landmark Scholarship 2023 របស់អង្គការ AFoCO និងលើករណីការផុតសុពលភាពនៃអនុស្សរណៈយោគយល់គ្នារវាងរដ្ឋបាលព្រៃឈើកម្ពុជា និងវៀតណាម ជូនរដ្ឋបាលព្រៃឈើ

-បានចូលរួមកិច្ចប្រជុំនៃក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ព្រៃឈើលើកទី៥២ (The 52nd Meeting of TWG-FR) និងរាយការណ៍ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នូវលទ្ធផលកិច្ចប្រជុំនេះ

-បានពិនិត្យ និងផ្តល់មតិលើសំណើសុំ Endorsement លើ Draft ASEAN Guidelines on Recognition of Customary Tenure និងDraft ASEAN Guiding Principles for Effective Social Forestry Legal Frameworks ព្រមទាំងDraft Study on Nature-based Solutions in ASEAN Across Forest, Bare Land and Coastal Ecosystems របស់លេខាធិការដ្ឋាន អាស៊ាន

-រដ្ឋបាលព្រៃឈើកំពុងសហការអនុវត្តគម្រោងសហប្រតិបត្តិការអន្តរជាតិចំនួន ១១គម្រោង។






ក្រុមការងាររដ្ឋបាលព្រៃឈើបានចូលរួមសមាជព្រៃឈើពិភពលោកលើកទី១៥ (15th World Forestry Congress) នៅសាធារណរដ្ឋកូរ៉េ






វគ្គបណ្តុះបណ្តាល ស្តីពីនីត្យានុកូលភាពនៃការប្រមូល ការដឹកជញ្ជូន និងការនាំចេញ-នាំចូលឈើនៅកម្ពុជា

# សមិទ្ធផលនៃការអភិរក្សសត្វព្រៃ និងជីវចម្រុះ

## ការអភិរក្សសត្វព្រៃ និងជីវចម្រុះ

### ១-ការសិក្សាស្រាវជ្រាវ និងតាមដានវត្តមានសត្វព្រៃ និងជីវចម្រុះ

#### ១.១-ការចុះសិក្សាស្រាវជ្រាវនិងប្រមូលទិន្នន័យសត្វព្រៃ

-ក្រុមការងារសិក្សាស្រាវជ្រាវ និងអង្កេតតាមដានវត្តមានសត្វព្រៃបានចុះសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ និងដំឡើងម៉ាស៊ីនថតរូបស្វ័យប្រវត្តចំនួន ១៤គ្រឿងដើម្បីថតយករូបភាពសត្វព្រៃគ្រប់ប្រភេទ សិក្សាអំពីកត្តាគំរាមកំហែង និងរៀបចំពង្រាងរបាយការណ៍សិក្សាស្រាវជ្រាវក្នុងតំបន់គម្រោងរេដបូកទំរីង ស្ថិតក្នុងស្រុកសណ្ដាន់ និងស្រុកសន្ទុក ខេត្តកំពង់ធំ



ក្រុមអ្នកដំឡើងម៉ាស៊ីនថតរូបស្វ័យប្រវត្ត

-បានចុះពិនិត្យសាកសពសត្វដំរី១ក្បាលស្ថិតនៅក្នុងដែនជម្រកសត្វព្រៃកែវសីមា ក្រោយពីទទួលបានព័ត៌មានពីប្រជាពលរដ្ឋមូលដ្ឋានកាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ ជាករណីប្រទះឃើញសាកសពសត្វដំរីញីមួយក្បាល ដេកស្លាប់ក្នុងចម្ការដំឡូងប្រជាជនភូមិពូចារ ឃុំស្រែព្រះ ស្រុកកែវសីមាខេត្តមណ្ឌលគីរី សាកសពមានសភាពស្អុយរលួយទៅហើយ។ សត្វដំរីស្លាប់នោះមានប្រវែងដងខ្លួន ៣,៣ម៉ែត្រ កម្ពស់ ១,៩ម៉ែត្រ ទទឹងដងខ្លួន១,១ម៉ែត្រ ទំងន់ប្រហែលជាង១តោន ជាសត្វដំរីជំទង់។ ព័ត៌មាននេះទទួលបានពីកម្មករស៊ីឈ្នួលដកដំឡូងមី ហើយត្រូវបានអ្នកជំនាញសន្និដ្ឋានថា អាចស្លាប់បណ្ដាលមកពីមានជំងឺ ឬក៏អាចមានព្រានព្រៃលួចបាញ់ក្នុងពេលយប់ ព្រោះថាអ្នកចាំចម្ការធ្លាប់ឮស្នូរកាំភ្លើងបាញ់ញឹកញាប់។ អង្គការ WCS បានជួយវិភាគទានក្នុងការដឹកសាកសពដំរីនេះយកមកកប់ដើម្បីរើសយកសំណាករក្សាទុកក្នុងសារមន្ទីរ។



សំណាកឆ្អឹងសត្វដំរីដែលបានស្លាប់ក្នុងចម្ការប្រជាជន

គួររំលឹកថាកន្លងមកដែនជម្រកសត្វព្រៃកែវសីមាក៏ធ្លាប់បានប្រទះឃើញសាកសពសត្វដំរីងាប់ម្ដងដែរ កាលពីខែកុម្ភៈ ឆ្នាំ២០១៩។



សត្វដំរីដែលបានស្លាប់ក្នុងដែនជម្រកសត្វព្រៃកែសីមា

-បានរៀបចំនិងចងក្រងអត្ថបទស្ដីពីវឌ្ឍនភាពនៃការសិក្សាស្រាវជ្រាវតាមដានហានិភ័យនៃជំងឺឆ្លងពីសត្វព្រៃមកមនុស្សតាមរយៈពពួកប៉ារ៉ាស៊ីត(ឈាម និងតឹកពីសត្វព្រៃ) នៅខេត្តរតនគីរី មណ្ឌលគីរី និងខេត្តព្រះវិហារ ដោយសហការ

ជាមួយអង្គការ Vysnova និងមន្ទីរពិសោធន៍ និងវិភាគមេរោគ NAMRU-2 ។

-បានចុះប្រមូលសំណាកសត្វចៃតឹកកែ និងចៃចេញពីសត្វស្រុក និងសត្វព្រៃស្ថិតនៅក្នុងស្រុកកំពង់សីលា ខេត្តកោះកុង សរុបបានចំនួន ១០០ក្បាល ក្នុងនោះមានជ្រូក ១០ក្បាល គោ ២៣ក្បាល ក្របី ៥ក្បាល ឆ្កែ៤៧ក្បាល និងឆ្មា១៥ក្បាល ដើម្បីយកសំណាកមកពិនិត្យ និងវិភាគរករោគវិនិច្ឆ័យដែលអាចឆ្លងពីសត្វព្រៃមកសត្វស្រុក និងពីសត្វស្រុកមកមនុស្ស ដោយសហការជាមួយមន្ទីរពិសោធន៍ និងវិភាគមេរោគ NAMRU II ។



តឹកកែជ្រូកព្រៃ ជាភ្នាក់ងារចម្លងជំងឺពីសត្វព្រៃមកមនុស្ស

-បានចូលរួមសិក្ខាសាលាតាមប្រព័ន្ធអ៊ីនធឺណិត (ZOOM) ស្ដីពីយុទ្ធនាការ “ អន្ទាក់សូន្យ ” ក្រោមអធិបតីភាពឯកឧត្តម នេត្រ ភក្ត្រា រដ្ឋលេខាធិការក្រសួងបរិស្ថាន ដើម្បីបញ្ឈប់ការបរបាញ់សត្វព្រៃគ្រប់ប្រភេទ ជាពិសេសការដាក់អន្ទាក់ គឺជាមធ្យោបាយមួយដែលសម្លាប់សត្វព្រៃស្ទើររាល់ថ្ងៃ និងគ្រប់ប្រភេទ។ តាមរបាយការណ៍ក្នុងអង្គសិក្ខាសាលាបានបញ្ជាក់ថា ជាមធ្យមក្នុងមួយឆ្នាំមានអន្ទាក់សរុបចំនួនប្រមាណជាង ៤០.០០០ បានដកចេញពីតំបន់ការពារធម្មជាតិទាំងនេះ

-ក្រុមការងារសិក្សាស្រាវជ្រាវ និងអង្កេតតាមដានវត្តមានសត្វព្រៃ បានចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យសត្វព្រៃ ក្នុងសហគមន៍ព្រៃឈើប្រាសាទទឹកខ្មៅ ក្នុងស្រុកសំបូរ ខេត្តក្រចេះ ដោយបានដំឡើងម៉ាស៊ីនថតស្វ័យប្រវត្តចំនួន០៥គ្រឿង ដើម្បីធ្វើការពិនិត្យ តាមដាន និងផ្ទៀងផ្ទាត់ពីវត្តមាន និងប្រភេទនៃសត្វព្រៃដែលកំពុងរស់នៅ និងបន្តពូជនៅក្នុងតំបន់សហគមន៍ប្រាសាទទឹកខ្មៅ



-បានសហការជាមួយក្រុមស្រាវជ្រាវសត្វព្រៃនៃអង្គការ WCS បានចុះស្រាវជ្រាវរកសំបុកសត្វស្លាប ដោះអន្ទាក់ និងដំឡើងម៉ាស៊ីនថតស្វ័យប្រវត្ត ក្នុងដែនជម្រកសត្វព្រៃកែវសីមា ដោយរកឃើញសំបុកសត្វត្រយងយក្សពងកូនចំនួន ០២សំបុក សត្វរមាំងចំនួន ០៣ក្បាល និងដោះអន្ទាក់បានប្រហែល ៤០០ខ្សែ។



សត្វត្រយងចង្កំក ស បានថតដោយក្រុមសិក្សាស្រាវជ្រាវ

## ១.២-ផ្នែកជំងឺសត្វ

-បានចូលរួមសិក្ខាសាលាស្ដីពីការ “ពិនិត្យឡើងវិញប្រចាំការអនុវត្តច្បាប់សុខភាពអន្តរជាតិ” ដែលបានប្រារព្ធឡើងចាប់ពីថ្ងៃទី១០-១១ ខែកុម្ភៈ ឆ្នាំ២០២២ នៅសណ្ឋាគារសោម៉ាទេវីអង្គរ ទីរួមខេត្តសៀមរាប រៀបចំឡើងដោយក្រសួងសុខាភិបាល ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត លី សុវណ្ណ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត អេង ហួត រដ្ឋលេខាធិការក្រសួងសុខាភិបាល

-បានចុះប្រមូលសំណាកសត្វប្រចៀវ ជ្រឹង ចំនួន ០២លើក នៅខេត្តស្ទឹងត្រែង និងខេត្តកំពត ដោយក្រុមការងារបានប្រមូលសំណាក(ឈាមទឹកមាត់ លាមក ទឹកនោម និងចោះស្បែក) សត្វប្រចៀវសរុបចំនួន ៤៦៥សំណាក ដែលត្រូវបានយកមករក្សាទុកនៅវិទ្យាស្ថានជាតិអាឡែកហ្ស៊ី និងជំងឺឆ្លងរបស់សហរដ្ឋអាមេរិក សម្រាប់សិក្សាស្រាវជ្រាវស្វែងរកជំងឺដែលអាចបង្កជាហានិភ័យ ជាជំងឺឆ្លងមកដល់សត្វស្រុក និងមនុស្ស។



ក្រុមការងារប្រមូលសំណាកពីសត្វព្រៃដើម្បីសិក្សាជំងឺឆ្លង

## ១.៣-ការប្រមូលសំណាករុក្ខជាតិកេសរកូល (អ័រគីដេព្រៃ)

-បានចុះប្រមូលសំណាករុក្ខជាតិកេសរកូល(អ័រគីដេព្រៃ) ចំនួន០២លើក នៅខេត្តសៀមរាបដោយប្រមូលសំណាករុក្ខជាតិកេសរកូលរស់បាន ចំនួន៣៤៦ សំណាក និងបានកំណត់អត្តសញ្ញាណ ចំនួន០៩ អំបូរផ្សេងគ្នា។



សកម្មភាពនៃការប្រមូលសំណាករុក្ខជាតិកេសកូល

## ១.៤- ការពង្រឹងការថែរក្សាសត្វព្រៃ

បានចុះពង្រឹងការថែរក្សាសត្វព្រៃចំនួន០១លើក នៅសហគមន៍ព្រៃឈើប្រាំបីមុម ខេត្តកំពង់ស្ពឺ ពីថ្ងៃទី០៩ ដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ដោះអន្ទាក់ខ្សែនីឡុងចំនួន ២៦ខ្សែចេញពីផ្លូវសត្វព្រៃឆ្លងកាត់។

## ១.៥-ការកំណត់តំបន់សក្តានុពលទេសចរណ៍ធម្មជាតិ

បានចុះសិក្សាកំណត់តំបន់សក្តានុពលទេសចរណ៍ធម្មជាតិចំនួន០១លើក នៅខេត្តមណ្ឌលគិរីក្នុងឆ្នាំ២០២២ ដោយបានពិភាក្សាជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តមណ្ឌលគិរី និងសង្កាត់រដ្ឋបាលព្រៃឈើអូររាំង សហគមន៍ព្រៃឈើក្នុងខេត្តមណ្ឌលគិរីមានចំនួន០៨កន្លែង។ តាមការសិក្សាបង្ហាញថា មានតែសហគមន៍ព្រៃឈើ ០១ កន្លែងប៉ុណ្ណោះ ដែលអាចមានសក្តានុពលសម្រាប់គោលបំណងបង្កើតជាតំបន់ទេសចរណ៍ធម្មជាតិ។

**សហគមន៍ពីងប្រង់ភ្លង់ពេសចូ** ជាតំបន់ធម្មជាតិដ៏ស្រស់ត្រកាល អមដោយទេសភាពព្រៃឈើ សត្វព្រៃ ទឹកធ្លាក់ ព្រៃឫស្សី...។ សហគមន៍ព្រៃឈើនេះធ្លាប់ទទួលបានការគាំទ្រពីអង្គការដៃគូរនានា ដូចជា NTFP-EP និង RECOFTC ដោយបានចងក្រងជាសមាជិក និងបានផ្គត់ផ្គង់ការចិញ្ចឹមឃ្មុំដល់ប្រជាពលរដ្ឋដោយបានផ្តល់ពូជ ដើម្បីជួយសម្រួលដល់កម្រិតជីវភាពផងដែរ។





ការចុះសិក្សាស្រាវជ្រាវតំបន់សក្តានុពលទេសចរណ៍ធម្មជាតិ

### ២-ពង្រឹងការត្រួតពិនិត្យ ការចិញ្ចឹមសត្វព្រៃតាមគ្រួសារ កសិដ្ឋាន និងសួនសត្វ

បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៤៣ច្បាប់ ក្នុងនោះ ៣០ច្បាប់សម្រាប់ការថែរក្សាសត្វត្រចៀកកាំ និង១៣ច្បាប់ សម្រាប់ការថែរក្សាសត្វព្រៃប្រភេទផ្សេង ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ កំពង់ស្ពឺ កំពង់ធំ សៀមរាប បន្ទាយមានជ័យ ក្រចេះ កំពង់ធំ ពោធិ៍សាត់ កណ្តាល កំពត និងខេត្តបាត់ដំបង។







ក្រុមការងារចុះពិនិត្យ និងផ្តល់លិខិតអនុញ្ញាត ការថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារ

## សមិទ្ធផលនៃការគ្រប់គ្រងឧទ្យានសួនសត្វ និងសង្គ្រោះ ថែរក្សាសត្វព្រៃ

### ១-ការសង្គ្រោះ ព្យាបាល និងថែរក្សាសត្វព្រៃ

សង្គ្រោះសត្វថ្មីចំនួន៤២៧ក្បាល ព្យាបាលសត្វព្រៃបានចំនួន២១៦ក្បាល។ សម្រាប់ឆមាសទី១ ឆ្នាំ២០២២ ឧទ្យាន សួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ មានសត្វព្រៃក្នុងស្តុកចំនួន ១ ៧៥៧ក្បាល(បក្សី ៥៩ប្រភេទ ថនិកសត្វ ៤៤ប្រភេទ និងល្មូន១៦ប្រភេទ)។

### ២-ការស្តារសត្វព្រៃឡើងវិញ

បានស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃចំនួន ៧៧ក្បាល។ ដោយឡែកគម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិមាន៖

-ក្រុមល្បាតសហគមន៍ចំនួន២៦នាក់បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន០៥ គឺនៅអារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ ខេត្តកោះកុង និងអូរសោម ខេត្តពោធិ៍សាត់

-ការងារតាមដានដានក្រពើប្រចាំឆ្នាំបានរកឃើញលាមកក្រពើចំនួន៦៦ដុំ ឃើញក្រពើផ្ទាល់២ក្បាល និងស្លាកស្នាមដានជើង៤កន្លែង

- លែងក្រពើភ្នំពូជសុទ្ធចំនួន២៥ក្បាលទៅក្នុងស្ទឹងធម្មជាតិក្នុងតំបន់ភូមិពោធិ៍បឹង ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង

- តាមដានប្រចាំឆ្នាំតាមពំនុះកាត់ទទឹងក្នុងដែនជម្រកក្រពើភ្នំស្ទឹងអារ៉ែង និងស្ទឹងដាច់រកឃើញដានជើងក្រពើចំនួន០៨កន្លែង និងលាមកចំនួន០៦ដុំ

- បំពាក់ឧបករណ៍តាមដានលើក្រពើភ្នំចំនួន០៨ក្បាល ដើម្បីតាមដានបន្លាស់ទី

- សិក្សាស្រាវជ្រាវវត្តមានក្រពើភ្នំនៅតំបន់ឆាយរាប រកឃើញសំបុកពងក្រពើ០១មានពងចំនួន ២២ពង។

### ៣- ការជួសជុល និងថែទាំ

ជួសជុលផ្លូវក្រាលក្រួសក្រហមបានប្រវែង២១ ០៣០ ម៉ែត្រ និងកាប់ឆ្ការអនាម័យដើងព្រៃបាន ០៣ហិកតា។



សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីសម្ពោធ ឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០០០

សម្ដេច ហ៊ុន សែន ធ្លាប់ដឹកនាំកេណ្ឌ ឈានមុខរែកពុន
កសាងសួនសត្វ តាម៉ៅពីមុន យើងសូមដឹងគុណ
មិនដែលមានពីរ ។
លើកនេះទៀតសោត សម្ដេចបានផ្ដោត បន្តសំភី
ដកដីមកវិញ គ្រាន់សត្វឈ្មោលញី បន្តជីវី
បម្រើទេសចរណ៍ ៕ *( ដោយលោក លិ វុឌ្ឍី )*







## ការពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើ

ក្នុងឆមាសទី១ ឆ្នាំ២០២២នេះ រដ្ឋបាលព្រៃឈើគ្រប់លំដាប់ថ្នាក់ បានសហការជាមួយកងកម្លាំងប្រដាប់អាវុធ អាជ្ញាធរដែនដី និងព្រះរាជអាជ្ញាអមសាលាដំបូងរាជធានី-ខេត្តក្នុងទូទាំងប្រទេសធ្វើការបង្ក្រាបបទល្មើសព្រៃឈើ-សត្វព្រៃ និងបទល្មើស កាប់រានដីព្រៃ ទទួលបាននូវសមិទ្ធផលដូចខាងក្រោម៖

-សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើ សរុបចំនួន **៣៥៤**ករណី ដែលក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន**១១៧**ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន**២៣៧**ករណី(ព្រៃឈើចំនួន១៨៥ករណី សត្វព្រៃចំនួន៣៥ករណី និងកាប់រានដីព្រៃចំនួន១៣៥ករណី)។

-វត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមាន ឈើមូល-ជ្រុងចំនួន**៧៧**ម៉ែត្រគ្រីគុណ ឈើអារសរុបចំនួន**៥៣៤**ម៉ែត្រគ្រីគុណ(ចំនួន១៨៥ករណី សត្វព្រៃចម្រុះប្រភេទសរុបចំនួន**៣៧៤៤**ក្បាល(ចំនួន៣៥ករណី គឺក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តចំនួន៣០ករណី ក្រចេះ០២ កំពង់ស្ពឺ០១ និងរតនគិរី០២)

-ផ្ទៃដីព្រៃឈើដែលបានកាប់រានទំហំ **២៩៥៧**ហិកតា (ចំនួន១៣៥ករណី៖ ខេត្តក្រចេះ៣១ករណី កំពង់ស្ពឺ១៩ បាត់ដំបង០២ ព្រះវិហារ០៦ អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាប០១ កំពង់ឆ្នាំង០៩ ស្ទឹងត្រែង០៧ កំពង់ធំ០៩ ពោធិ៍សាត់០១ ព្រៃវែង០១ ព្រះសីហនុ០១ រតនគិរី០៤ និងខេត្តឧត្តរមានជ័យ៤៤ករណី) និងអនុផលព្រៃឈើព្រមទាំងឧបករណ៍សម្ភារផ្សេងៗមួយចំនួនទៀត

-វត្ថុតាងជាសត្វព្រៃ និងសំណាកសត្វព្រៃ បានប្រមូលតាមរយៈការប្រគល់-ទទួល សរុបចំនួន**១៥៧**ករណី ធ្វើកិច្ចសន្យាចំនួន**៣៣**ករណី ធ្វើការដកហូតចំនួន**៤៤**ករណី រួមមាន៖ សត្វព្រៃរស់ចម្រុះប្រភេទចំនួន **៤០៨**ក្បាល សត្វព្រៃងាប់ចម្រុះប្រភេទចំនួន**៦៨៦២**ក្បាល និងសំណាកសាច់សត្វព្រៃចំនួន**៨៧,៧០**គីឡូក្រាម ទ្រុងអណ្ដើកភ្នំចំនួន**០៣** ទ្រុងអណ្ដើកសោមចំនួន**០១** ស្នូកអណ្ដើកស្រែចំនួន**០១**

-បានធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ និងសត្វព្រៃ តាមរយៈការបង់ប្រាក់ពិន័យដោយតុលាការចំនួន **០៩**ករណី(ខណ្ឌរដ្ឋបាលព្រៃឈើរតនគិរីចំនួន ០៧ករណី ខណ្ឌរដ្ឋបាលព្រៃឈើកំពង់ធំចំនួន០១ករណី និងខណ្ឌរដ្ឋបាលព្រៃឈើត្បូងឃ្មុំចំនួន០១ករណី)។

-ស្រង់ព័ត៌មានពាក់ព័ន្ធនឹងវិស័យព្រៃឈើក្នុងបណ្ដាញសារព័ត៌មាននានាបានចំនួន**១០០**ករណី ដែលក្នុងនោះមាន កោះសន្តិភាពចំនួន៤៣ករណី ភ្នំពេញប៉ុស្តិ៍ចំនួន ១៨ករណី និងនគរធំចំនួន ៣៩ករណី ក្នុងនោះអធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គមានចំនួន ៣៤ករណី អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាបមានចំនួន៣៨ករណី អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាប មានចំនួន ០៩ករណី អធិការដ្ឋានរដ្ឋបាលព្រៃឈើឈូងសមុទ្រមានចំនួន១៦ករណី និងទូទាំងប្រទេសចំនួន០៣ករណី។ អត្ថបទសារព័ត៌មានដែលបានចុះផ្សាយពាក់ព័ន្ធនឹងបញ្ហាព្រៃឈើ-សត្វ និងដីព្រៃឈើទាំងអស់ត្រូវបានរក្សាទុកជាឯកសារ និងបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ព្រមទាំងផ្ទៀងផ្ទាត់ឱ្យមានសុក្រឹតភាព។



មន្ត្រីនៃផ្នែករដ្ឋបាលព្រៃឈកំពង់ថ្ម និងមន្ត្រីគម្រោងវ៉េដប្លូកទំរីង សហការជាមួយកម្លាំងតំបន់ប្រតិបត្តិកសរសីករងកំពង់ធំ បានចុះប្រតិបត្តិការបង្ក្រាបបទល្មើសព្រៃឈើក្នុងតំបន់បុស្សស្បូវ ស្ថិតក្នុងឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ បានជួបប្រទះទីតាំងកាប់រានចំនួន០១កន្លែង និងបានដកហូតរណារយន្តចំនួន០២គ្រឿង នាថ្ងៃទី០៧-០១-២០២២

# រុក្ខជាតិកម្រដែលមានរូបរាងប្លែកៗស្រដៀងទៅនឹងសត្វ ឬរបស់អ្វីម៉្យាង

# Exotic Plants That Look Like Animals or Something else

ស្រាវជ្រាវ និងប្រែសម្រួលដោយកញ្ញា **សេង ម៉ាឡា** កែសម្រួលដោយ លោក **នុត សុផា** និងរៀបចំរចនាដោយលោក **ឃៀង អៀងតិច**
*ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ*

ធម្មជាតិពោរពេញដោយភាពអស្ចារ្យ ហើយវាមិនដែលឈប់ធ្វើឱ្យយើងភ្ញាក់ផ្អើលឡើយ។ ជារៀងរាល់ថ្ងៃ ពពួកសត្វ និងរុក្ខជាតិជាច្រើនត្រូវបានគេរកឃើញ ដែលប្រភេទនីមួយៗមានលក្ខណៈពិសេស និងទិដ្ឋភាពដែលធ្វើឱ្យពួកវាមានលក្ខណៈប្លែកគេ។

មានរុក្ខជាតិច្រើនជាង ៤០០,០០០ ប្រភេទ នៅលើភពផែនដី។ ក្នុងចំណោមរុក្ខជាតិទាំងនោះ មានរុក្ខជាតិមួយចំនួនបានបង្ហាញលក្ខណៈរូបរាងស្រដៀងគ្នាខ្លាំងណាស់ទៅនឹងប្រភេទសត្វមួយចំនួន។ ខាងក្រោមនេះ ជាភស្តុតាង និងជាព័ត៌មានបញ្ជាក់អំពីរុក្ខជាតិកម្រ ដែលនឹងធ្វើឱ្យមានការភ្ញាក់ផ្អើល និងមិននឹកស្មានថាវាមានវត្តមាននៅលើផែនដីយើងនេះ៖

## ១.ផ្កាអ័រគីដេ(ឬកេសរគូល)ដែលមានរូបរាងស្រដៀងទៅនឹងមុខសត្វស្វា( *Dracula simia* - A Monkey Face Orchid )

អ័រគីដេប្រភេទនេះដុះលូតលាស់ពី ១២០០ ទៅ ២០០០ម៉ែត្រ ពីនីវ៉ូទឹកសមុទ្រ។ *Dracula simia* គឺជាផ្កាដ៏ស្រស់ស្អាតគួរឱ្យស្រលាញ់ដែលត្រូវបានគេស្គាល់ថាជាផ្កាអ័រគីដេមុខស្វា និងត្រូវបានគេរកឃើញនៅក្នុងតំបន់ខ្ពង់រាបនៃប្រទេសកូឡុំប៊ី(Colombia) អេក្វាឌ័រ(Ecuador) និងប៉េរូ(Peru)។ ផ្កាអ័រគីដេ *Dracula* មានច្រើនប្រភេទ ហើយខ្លះមានលក្ខណៈដូចមុខស្វាខ្លាំងជាងប្រភេទផ្សេងទៀត ប៉ុន្តែជាទូទៅពួកវាមានរូបរាងស្រដៀងគ្នា។ ក្លិនរបស់វាប្រហាក់ប្រហែលនឹងក្លិនផ្លែក្រូចទុំ ហើយមិនមែនជាផ្កាមានតាមរដូវធម្មតានោះទេ ព្រោះវាអាចរីកគ្រប់ពេលវេលានៅក្នុងជម្រកធម្មជាតិរបស់វា។ ដោយសារតែទម្រង់នៃការរៀបចំនូវទ្រនុងផ្កា គ្របកផ្កា និងស្រទាប់ផ្កា ដែលដុះឡើងមានពណ៌ផ្កាឈូក និងពណ៌សរបស់វា ព្រមទាំងផ្នែកខាងក្រោមមានពណ៌ស្វាយ ហើយបំពង់មេជីវិតញី (Pistil) ដុះចេញជារាងដូចជាមាត់ និងច្រមុះរបស់ស្វា ដែលកត្តាទាំងនេះធ្វើឱ្យអ័រគីដេប្រភេទនេះមានលក្ខណៈស្រដៀងទៅនឹងមុខស្វាខ្លាំងបំផុត។





## ២.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងសត្វឃ្មុំ ( *Ophrys apifera* - The Bee Orchid )

ផ្កាអ័រគីដេ *Ophrys apifera* ត្រូវបានគេរកឃើញនៅតំបន់អឺរ៉ុប និងអាស៊ីខាងលិច។ អ័រគីដេប្រភេទនេះ គឺជាពពួករុក្ខជាតិស្មៅដែលដុះឡើងវិញជារៀងរាល់ឆ្នាំ ហើយវាឋិតក្នុងអំបូរអ័រគីដេ Orchidaceae។ ជាធម្មតាវាមានកម្ពស់ ១៥-៥០សង់ទីម៉ែត្រ និងទទួលបានឈ្មោះថាជា អ័រគីដេឃ្មុំ ដោយសារតែត្របកផ្ការបស់វាដែលត្រាប់តាមរាងដូចជាសត្វឃ្មុំ (ក្នុងជីវវិទ្យា ពាក្យ “ការធ្វើត្រាប់តាម (mimic)” សំដៅលើករណីដែលការជ្រើសរើសភាពដូចដោយធម្មជាតិរវាងប្រភេទនីមួយៗទៅនឹងប្រភេទផ្សេងៗទៀត ជាឧទាហរណ៍មានផ្កាអ័រគីដេជាច្រើនដែលមានលក្ខណៈរូបរាងស្រដៀងនឹងភ្នាក់ងារចម្លងលម្អងរបស់វា)។ ជាទូទៅផ្កាអ័រគីដេឃ្មុំញីមានត្របកផ្កាបីដែលមានរោមទន់រលោង និងមានពណ៌ត្នោតចាស់ ហើយមានចំណុចតូចៗ និងពណ៌ដូចគ្នា ប៉ុន្តែស្រាល ព្រមទាំងមានបន្ទាត់ពណ៌ស និងលឿងផងដែរ។



## ៣.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងសត្វសេក ( *Impatiens psittacine* - Parrot Flower )

ផ្កាប្រភេទនេះត្រូវបានគេរកឃើញនៅក្នុងបណ្តាប្រទេសអាស៊ី ដូចជាប្រទេសថៃ ភូមា និងឥណ្ឌា។ *Impatiens Psittacina* ជាផ្កាមួយប្រភេទដែលមើលទៅដូចជា សត្វសេក ហើយត្រូវបានគេហៅថាផ្កាសេក។ វាមានកម្ពស់ប្រមាណ ៥០សង់ទីម៉ែត្រ។ ស្រទាប់ផ្កាមានចំនួន ០៣ និងត្របកផ្កាចំនួន ០៣ ហើយវាជាប្រភេទក្រុមរុក្ខជាតិចម្លែក។ ផ្ការបស់វាមានពណ៌ស្វាយស្លេក និងដូចល័ក្ខពណ៌ក្រហម ដែលមានរាងដូចសត្វសេកហោះ ពេលមើលពីចំហៀង។



## ៤.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងសត្វទា ( *Caleana major* - Large Duck Orchid )

ផ្កាអ័រគីដេប្រភេទនេះមានដើមកំណើតនៅប្រទេសអូស្ត្រាលី។ ផ្កាអ័រគីដេ *Caleana Major* ត្រូវបានគេស្គាល់ថាជាផ្កាអ័រគីដេមានលក្ខណៈដូចទាហោះ ដែលមានកម្ពស់ប្រមាណ ៤០សង់ទីម៉ែត្រ ហើយត្រូវបានកំណត់លក្ខណៈដោយពណ៌ក្រហម និងបៃតង។ នៅលើមែកមួយមានផ្កាពី ៥ ទៅ ៧ ជាពិសេសរីកនៅចន្លោះរដូវផ្ការីក និងរដូវក្តៅ។ រូបរាងពិសេសរបស់វាធ្វើឱ្យស្រទាប់ និងត្របកផ្កាមើលទៅដូចជាសត្វទាកំពុងហោះ។



### ៥.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងសត្វកុក-ក្រសា ( *Pecteilis radiata*- White Egret Flower )

វាគឺជាផ្កាអ័រគីដេដែលល្បីល្បាញបំផុតនៅក្នុងប្រទេសជប៉ុន ដែលវាត្រូវបានគេហៅថា Sagisō ហើយផ្កាប្រភេទនេះត្រូវបានរកឃើញផងដែរនៅក្នុងប្រទេសចិន ជប៉ុន កូរ៉េ និងរុស្ស៊ី។ វាត្រូវបានសម្គាល់ដោយពណ៌សប្លែក និងរូបរាងនៃផ្ការបស់វា។ ស្រទាប់ផ្កាខាងក្រោយស្រដៀងនឹងសត្វកុក-ក្រសា ហើយត្របកផ្ការបស់វាដូចទៅនឹងស្លាបបក្សី។ ជម្រកធម្មជាតិរបស់ផ្កាដ៏កម្រមួយនេះអាចរកបាននៅតំបន់ភ្នំដែលវាដុះនៅកម្ពស់ប្រមាណ ១៥០០ម៉ែត្រ។



### ៦.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងសត្វរុយ ( *Ophrys insectifera* - The Fly Orchid )

ដូចទៅនឹងអ័រគីដេរូបរាងសត្វឃ្មុំដែរ អ័រគីដេរូបរាងសត្វរុយប្រភេទនេះ គឺវាបានត្រាប់រូបរាងដោយពឹងផ្អែក



លើពពួកសត្វល្អិតជាភ្នាក់ងារចម្លងលម្អងដែលយល់ច្រឡំមកបង្កាត់ជាមួយវា ហើយវាងាយស្រួលក្នុងការកំណត់អត្តសញ្ញាណសត្វល្អិតទាំងនោះ។ ទោះបីជាយ៉ាងណាក្នុងករណីដែលផ្កានេះ វាទាក់ទាញសត្វឱម៉ាល់ឈ្មោល និងឃ្មុំដោយវាបានបង្កើតក្លិនក្រអូបម្យ៉ាងដែលធ្វើត្រាប់តាមដូចទៅនឹងសត្វញី តែផ្កាវាបែរជាស្រដៀងនឹងសត្វរុយទៅវិញ។

### ៧.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងកូនង៉ែតរុំក្នុងក្រណាត់សំពត់ ( *Anguloa Uniflora* - Swaddled Babies )

ប្រភេទផ្កា *Anguloa* ជាទូទៅត្រូវបានគេស្គាល់ថាជាផ្កាអ័រគីដេធូលីប (Tulip Orchid) ដែលជាក្រុមពូជតូចមួយនៃពូជអ័រគីដេ *Lycaste*។ វាត្រូវបានគេសរសេរជាអក្សរកាត់នៅក្នុងការងារសាកវប្បកម្ម Ang.។ ពូជមួយប្រភេទនេះត្រូវបានគេរកឃើញនៅតាមតំបន់ព្រៃដែលមានរយៈកម្ពស់ខ្ពស់នៃប្រទេស វេណេស្សូអេឡា (Venezuela), កូឡុំប៊ី (Colombia), អេក្វាឌ័រ (Ecuador), បូលីវី (Bolivia) និងប៉េរូ (Peru)។ រុក្ខជាតិនេះជាពពួកដុះលើដី និងខ្លះជាពពួកដុះតោងជាមួយនឹងរុក្ខជាតិ ឬដើមឈើដទៃទៀតដែលមានថ្នាំង (Pseudobulb) ដុះប្រវែងប្រមាណ ២០សង់ទីម៉ែត្រ។ ស្លឹកដែលមានរាងពងក្រពើ (lanceolate) និងបត់ (plicate) នៃរុក្ខជាតិពេញវ័យអាចមានប្រវែងដល់ទៅ ១ម៉ែត្រ។ ស្លឹកចំនួន២-៤ ដុះចេញពីថ្នាំង ហើយស្លឹកវានឹងទុំជ្រុះនៅពេលដុះស្លឹកថ្មី។ ផ្ការបស់វាមានក្លិនក្រអូបដូចទៅនឹងក្លិនឈើអែម និងមើលទៅដូចក្រមួន ហើយនៅក្នុងព្រៃធម្មជាតិវាអាចមាន ០២ពណ៌ គឺអាស្រ័យទៅលើប្រភេទ ដោយប្រភេទខ្លះមានពណ៌បៃតង-ស ឬពណ៌លឿង-ក្រហម។ ផ្កាមួយក្នុងចំណោមផ្កាមួយកញ្ចុំនឹងដុះចេញពីគល់ថ្នាំងថ្មីនីមួយៗ។ ផ្កាអ័រគីដេធូលីប ពណ៌ស មានផ្កាចំនួន ០៦កញ្ចុំក្នុងមួយថ្នាំង ហើយប្រភេទផ្សេងទៀតអាចមានដល់ទៅ ១២កញ្ចុំ។ ស្រទាប់ផ្កាមានរាងមូលដូចផ្កាធូលីប និងត្របកផ្កាមានចំនួន០៣ និងបំពង់លម្អងដែលមានលម្អងចំនួន ០៤។ ផ្កាអ័រគីដេធូលីបមានចំនួន ១៣ប្រភេទ ក្នុងនោះមានប្រភេទមួយចំនួនត្រូវបានគេយកមកបង្កាត់ និងប្រភេទមួយចំនួនទៀតដុះក្នុងព្រៃ។





## ៨.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងមនុស្សភពផ្កាយដ៏រីករាយ( *Calceolaria Uniflora* - Happy Alien)

ផ្កាអ័រគីដេ *Calceolaria uniflora* (syn. *Calceolaria darwinii* គេស្គាល់ថាជា Darwin's slipper) គឺជារុក្ខជាតិដែលដុះឡើងវិញជារៀងរាល់ឆ្នាំដែលស្ថិតក្នុងពូជ *Calceolaria* ដែលត្រូវបានគេស្គាល់ថាជារុក្ខជាតិមានរាងដូចជាស្បែកជើង (slipperworts) ។ វាមានដើមកំណើតមកពី Tierra del Fuego នៃអាមេរិកខាងត្បូង។ *Calceolaria uniflora* គឺជារុក្ខជាតិដុះលើភ្នំ ហើយវាមានកម្ពស់ត្រឹមតែប្រមាណ ១០សង់ទីម៉ែត្រ។ ផ្ការបស់វាមានពណ៌លាយឡំគ្នារវាងលឿង ស និងក្រហម ត្នោត។ វាជារុក្ខជាតិដែលបង្កាត់ពូជតាមរយៈការចម្លងលម្អងដោយពពួកបក្សី (Ornithophilic plant)។ ផ្ការបស់វាត្រូវបានចម្លងលម្អងដោយពពួកសត្វស្លាបទឹក (least seedsnipe/xerophilic bird)។ ពពួកសត្វស្លាបទាំងនោះស៊ីផ្នែកផ្កាពណ៌សនៅលើត្របកផ្កាខាងក្រោម ដែលផ្កាទាំងនេះមានជាតិស្ករខ្ពស់។ ខណៈពេលដែលសត្វស្លាបទាំងនោះទុំ និងចឹកស៊ីផ្កា នៅពេលនោះហើយដែលកេសរញី និងថង់លំអងផ្កាបានតោងជាប់ទៅនឹងក្បាល និងខ្នងនៃបក្សីទាំងនោះរួចវានឹងចែកចាយ និងទទួលលម្អង ដោយធានាថាលម្អងទាំងនោះនឹងត្រូវបានផ្ទេរទៅផ្កា *Calceolaria unifora* ផ្សេងទៀតដែលត្រូវបានសត្វបក្សីទាំងនោះហើរទៅទុំ។

## ៩.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងមុខរបស់សត្វខ្លា ( *Grammatophyllum speciosum* - Tiger Orchid)

ផ្កាអ័រគីដេ *Grammatophyllum speciosum* ត្រូវបានគេស្គាល់ថាជាអ័រគីដេដែលមានទំហំធំបំផុត (Giant Orchid) ឬអ័រគីដេរូបខ្លា (Tiger Orchid) ឬអ័រគីដេដើមអំពៅ (Sugar cane Orchid) ឬរាជនីអ័រគីដេ (Queen of the Orchid) ដែលមានដើមកំណើតនៅប្រទេសឥណ្ឌូនេស៊ី។ វាត្រូវបានបញ្ចូលទៅក្នុងកំណត់ត្រាពិភពលោក (Guinness Book of World Records) ជាប្រភេទអ័រគីដេដែលមានកម្ពស់ខ្ពស់បំផុតដែលមានប្រវែងរហូតដល់ទៅ៧.៦២ម៉ែត្រ។ វាជាប្រភេទបាណង្គជាតិ (epiphytic plant) និងខ្លះជាពពួករុក្ខជាតិដែលដុះលើថ្ម (lithophytic plant) និងបង្កើតជាបណ្ដុះឫសដ៏អស្ចារ្យ។ ដុំពក/ថ្នាំងដែលមានរាងស៊ីឡាំងរបស់វាអាចលូតលាស់ដល់រហូតដល់ប្រវែង ២.៥ម៉ែត្រ ហើយវាអាចដុះលូតលាស់ទៅជាចង្កោមយ៉ាងធំដែលមានទម្ងន់រាប់រយគីឡូក្រាមទៅជាងមួយតោន។ ចង្កោមផ្កានីមួយៗអាចដុះរហូតដល់កម្ពស់ ៣ម៉ែត្រ និងមានផ្ការហូតដល់ចំនួន ៨០ ដែលផ្កានីមួយៗមានទទឹងប្រវែងប្រមាណ ១០សង់ទីម៉ែត្រ។ ផ្ការបស់វាមានពណ៌លឿងត្នោត ឬពណ៌ក្រហមទុំអុជៗ។ ផ្កាទាំងនេះ គឺមានលក្ខណៈគួរឲ្យកត់សម្គាល់ ដោយសារផ្កាដែលនៅផ្នែកខាងក្រោមមិនមានត្របកផ្កាទេ ហើយផ្កាទាំងនេះមានមុខងារបង្កើតក្លិន (osmophores) សម្រាប់ចង្កោមផ្កាទាំងមូល ហើយវាបន្ត

បញ្ចេញក្លិនគីមីម្យ៉ាងដើម្បីទាក់ទាញពពួកភ្នាក់ងារចម្លងលម្អងនៅពេលដែលផ្ការីកពេញលេញ។ ផ្ការបស់វារីកជារៀងរាល់ ២-៤ឆ្នាំម្តង ប៉ុន្តែទោះយ៉ាងណាក៏ដោយផ្ការបស់វាអាចបន្តរីកបានរហូតដល់រយៈពេលពីរខែ។ បន្ថែមពីនេះ រុក្ខជាតិប្រភេទនេះត្រូវបានគេរកឃើញថាមានអត្ថប្រយោជន៍សម្រាប់ផ្នែកឱសថ ឧទាហរណ៍៖ អត្ថបទស្រាវជ្រាវមួយដែលរកឃើញដោយ Harikarnpakdee និង Chowjarean បានរកឃើញថាវាជួយជាពិសេសក្នុងការព្យាបាលមុខរបួសរបស់មនុស្ស។



### ១០.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងទេពអប្សរ ( *Habenaria Grandifloriformis* - Angel Orchid )

អ័រគីដេទេពអប្សរ *Habenaria Grandifloriformis* គឺជាប្រភេទផ្កាអ័រគីដេដែលល្អឆើតពីវាលស្មៅតំបន់ខ្ពស់នៃភាគខាងត្បូងប្រទេសឥណ្ឌា។ វាត្រូវបានពិពណ៌នាជាលើកដំបូងដោយ Charles McCann និង Ethelbert Blatter ក្នុងឆ្នាំ១៩៣២ ហើយត្រូវបានកត់សម្គាល់ភាពស្រស់ស្អាតរបស់វាដោយសារត្របកផ្កាពណ៌សចំនួន ០២ (bilobed) ដែលមើលទៅដូចជាស្លាបដ៏ស្រស់ស្អាតរបស់ទេពអប្សរដែលកំពុងសំកាំងអណ្តែតឡើង។ ដើមនីមួយៗអាចមានផ្កាចំនួនមួយ ឬច្រើន ប៉ុន្តែជាធម្មតាមិនលើសពីប្រាំក្នុងមួយដើម។ ដើមមានកម្ពស់មិនលើសពី ១២សង់ទីម៉ែត្រ ហើយបង្កើតបានផ្កាមួយនៅផ្នែកខាងលើនៃដើមនីមួយៗ។ ផ្ការីកចាប់ពីខែមិថុនា ដល់ខែកក្កដា នៅពេលចាប់ផ្តើមនៃខ្យល់ មូសុង។



### ១១.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងអ្នករាំរបាំបាឡេ( *Caladenia melanema* - A Ballerina Orchid)

ផ្កាអ័រគីដេ *Caladenia melanema* ដែលត្រូវបានគេស្គាល់ជាទូទៅថាជាផ្កាអ័រគីដេដែលមានរាងដូចទៅនឹងអ្នករាំរបាំបាឡេ។ វាគឺជាប្រភេទផ្កាអ័រគីដេដែលមានដើមកំណើតនៅភាគនិរតីនៃប្រទេសអូស្ត្រាលីខាងលិច។ វាជាផ្កាអ័រគីដេដ៏កម្រដែលមានស្លឹកដុះត្រង់តែមួយ មានរោម និងផ្កាមានពណ៌មួយ ឬពីរ គឺពណ៌ពងមាន់ ឬពណ៌លឿងស្លេកជាមួយនឹងត្របក និងស្រទាប់ផ្កាពណ៌ត្នោត។ *Caladenia melanema* គឺជារុក្ខជាតិដែលដុះលើដី និងដុះលូតលាស់ឡើងវិញជារៀងរាល់ឆ្នាំ។ វាជាប្រភេទពពួករុក្ខជាតិស្មៅជម្រុះស្លឹកដែលមានមើមនៅក្រោមដី និងស្លឹករបស់វាមានរោមដុះត្រង់ឡើងលើប្រវែង ៤០-១២០មម និងទទឹង ២-៧មម។ ផ្កាមានប្រវែង ៤០-៦០មម និងទទឹង ៤០-៥០មម។ ការចេញផ្កាកើតឡើងពីខែសីហា ដល់ ពាក់កណ្តាលខែកញ្ញា។ បន្ថែមពីនេះ រុក្ខជាតិពេញវ័យប្រភេទនេះមានចំនួនតែ ៣០០ដើម នៃក្រុមប្រភេទ *C. melanema* ប៉ុណ្ណោះ ដែលត្រូវបានទទួលស្គាល់ក្នុងឆ្នាំ២០០៦ និងត្រូវបានចាត់ចូលជាប្រភេទកំពុងរងការគំរាមកំហែងដោយរដ្ឋាភិបាលអូស្ត្រាលីខាងលិច។



### ១២.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងមេអំបៅ (*Platanthera bifolia* - Lesser Butterfly Orchid)

ផ្កាអ័រគីដេ *P. bifolia* ដែលត្រូវបានគេស្គាល់ជាទូទៅ ថាជាផ្កាអ័រគីដេដែលមានរូបរាងស្រដៀងនឹងសត្វមេអំបៅ (Lesser butterfly orchid)។ វាគឺជាប្រភេទផ្កាអ័រគីដេ ដែលស្ថិតនៅក្នុងអំបូរ *Platanthera* ដែលមានទំនាក់ទំនងយ៉ាងជិតដិតជាមួយនឹងអំបូរពពួកអ័រគីដេ និងត្រូវបានរួមបញ្ចូលតាំងពីមុនមករួមជាមួយនឹងអំបូរ *Habenaria* ផងដែរ។ វាមានដើមកំណើតចេញពីប្រទេសអៀរឡង់ខាងលិច (West Ireland) ទ្វីបអឺរ៉ុប និងអាស៊ី រហូតដល់ប្រទេសកូរ៉េ និងប្រទេសជប៉ុន។ វាត្រូវបានរកឃើញផងដែរនៅអាហ្វ្រិកខាងជើង។ ឈ្មោះ *Platanthera* នេះមកពីភាសាក្រិច មានន័យថា "ចង់កេសរឈ្មោលដែលមានទំហំធំ" ចំណែកឯឈ្មោះប្រភេទ *bifolia* មានន័យថា "ស្លឹកពីរ"។ ផ្កាអ័រគីដេមេអំបៅនេះមានមួយប្រភេទទៀត ដែលមានរូបរាង និងទំហំប្រហាក់ប្រហែលគ្នាឈ្មោះថា (*P. chlorantha* - Greater butterfly orchid) ប៉ុន្តែភាពខុសគ្នានៃផ្កាអ័រគីដេទាំងពីរនេះគឺ ទីតាំងនៃចង់លម្អង ដោយចង់លម្អងផ្កាអ័រគីដេ (Greater butterfly) ស្ថិតនៅញែកឆ្ងាយពីគ្នា ចំណែកចង់លម្អងរបស់ផ្កាអ័រគីដេ (Lesser butterfly) គឺនៅស្រប និងជិតគ្នា។ ផ្កាអ័រគីដេមេអំបៅ (Lesser butterfly) នេះត្រូវបានសម្គាល់ដោយស្លឹកពណ៌បៃតងភ្លឺចំនួន ០២ របស់វា។ គ្របក និងស្រទាប់ផ្កាផ្នែកខាងលើជារាងត្រីកោណស្ថិតនៅស្របគ្នា និងជាប់នឹងខាងលើលម្អងផ្កា។ ជាធម្មតាផ្កាមានចំនួនប្រហែល ២៥ ដែលមានពណ៌សព្រឿងៗលាយពណ៌លឿងបៃតងផ្ដុំនៅលើដើមតូចស្ដើង។ ផ្កានេះមានក្លិនក្រអូបពេលយប់ ប៉ុន្តែសមាសធាតុគីមីនៃក្លិន គឺខុសពីផ្កាអ័រគីដេមេអំបៅ (Greater butterfly) ហើយទាក់ទាញភ្នាក់ងារចម្លងលម្អងផ្សេងគ្នា។ ផ្កាអ័រគីដេមេអំបៅ (Lesser butterfly) មានដែនជម្រកយ៉ាងទូលំទូលាយ ហើយវាមានភាពធន់ទ្រាំចំពោះលក្ខខណ្ឌដីអាស៊ីតជាងផ្កាអ័រគីដេមេអំបៅ (Greater butterfly)។ ពួកវាត្រូវបានរកឃើញនៅតាមវាលស្មៅ ព្រៃ (ជាពិសេសព្រៃនៅភាគខាងត្បូងប្រទេសអង់គ្លេស) នៅវាលភ្នំកម្ពស់ ៤០០ ម៉ែត្រ និងនៅក្នុងដីវាលភក់។






### ១៣.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងខ្មោច (*Dendrophylax lindenii* - Ghost Orchid)

ផ្កាអ័រគីដេដ៏កម្រ *Dendrophylax lindenii* ត្រូវបានរកឃើញតំបន់សើម និងវាលភក់នៃប្រទេសគុយបា (Cuba), បាហាម៉ា(Bahama) និងផ្លរីដា (Florida) សហរដ្ឋអាមេរិក។

ផ្កាអ័រគីដេខ្មោច ត្រូវបានគេស្គាល់ថាជាផ្កាអ័រគីដេកង្កែបពណ៌ស (White frog orchids) ដោយសាររូបរាងដូចកង្កែប ដែលមើលទៅដូចជាផ្កាអ័រគីដេខ្មោចដ៏ចម្លែក។ ផ្ការបស់វាមានពណ៌ស និងរូបរាងផ្សេងទៀតដែលធ្វើឱ្យវាកាន់តែមានភាពអាថ៌កំបាំង។ រុក្ខជាតិប្រភេទនេះមិនសូវមានស្លឹក ដែលមើលទៅហាក់ដូចជាត្រូវបានព្យួរនៅក្នុងអាកាស នៅពេលដែលឫសរបស់វាភ្ជាប់ទៅនឹងដើមឈើ។ ក្លិនក្រអូបនាពេលរាត្រីដ៏ផ្អែមល្ហែមនៃផ្កាទាក់ទាញពពួកមេអំបៅ (Sphinx moths) ដែលជាភ្នាក់ចម្លងលម្អង ជាមួយនឹងប្រមោយយ៉ាងវែងរបស់វាដែលអាចបឺតដល់លម្អងដែលលាក់ជ្រៅនៅក្នុងផ្កាអ័រគីដេខ្មោចនេះ។ លើកលែងតែមនុស្សមួយចំនួនតូច គឺគ្មាននរណាម្នាក់ដឹងច្បាស់ថា ដើមផ្កាអ័រគីដេខ្មោចដុះនៅឯណានោះទេ។ ការរក្សាការសម្ងាត់ក្នុងកម្រិតខ្ពស់នេះ គឺដើម្បីការពារពីអ្នកប្រមាញ់ដែលព្យាយាមយកពួកវាចេញពីបរិស្ថានធម្មជាតិរបស់វា។ ដូចទៅនឹងផ្កាអ័រគីដេព្រៃផ្សេងទៀតនៅសហរដ្ឋអាមេរិក ផ្កាអ័រគីដេខ្មោចក៏ត្រូវបានរងការគំរាមកំហែងដោយសារការបាត់បង់ភ្នាក់ងារចម្លងលម្អង ថ្នាំសម្លាប់សត្វល្អិត និងការប្រែប្រួលអាកាសធាតុ។



## ១៤.ផ្កាអ័រគីដេដែលមានរូបរាងស្រដៀងទៅនឹងបុរសអាក្រាត (*Orchis italica* - Naked Man Orchid)

អ័រគីដេប្រភេទនេះជាពូជ *Orchis italica* ឬអ័រគីដេអ៊ីតាលី (Italian orchid) ដែលមានដើមកំណើតនៅតំបន់សមុទ្រមេឌីទែរ៉ាណេនៃមជ្ឈឹមបូព៌ា និងអាហ្វ្រិកខាងជើង។ វាត្រូវបានគេស្គាល់ថាជាអ័រគីដេនៃបុរសអាក្រាត ដោយសារតែត្របកផ្កា lobed (labellum) នីមួយៗដែលដូចទៅនឹងរូបរាងរបស់មនុស្សអាក្រាត។ នៅក្នុងប្រទេសអ៊ីតាលី វាត្រូវបានគេជឿថាការទទួលទានរុក្ខជាតិនេះ គឺអំណោយផលដល់ការបង្កើនសមត្ថភាពផ្លូវភេទរបស់បុរស។ វាចូលចិត្តដុះនៅក្នុងម្លប់ និងដីមានជីជាតិទាប ហើយផ្កានៅខែមេសា។ វាអាចដុះលូតលាស់ដល់កម្ពស់ ៥០សង់ទីម៉ែត្រ និងមានផ្កាដែលដុះជាចង្កោមពណ៌ផ្កាស្វាយស្រាល។



## ១៥.ផ្កាដែលមានរូបរាងស្រដៀងទៅនឹងក្រញាំសត្វកង់ហ្គារូ (*Anigozanthos manglesii* - Kangaroo Paw)

ដើមផ្កាក្រញាំ Kangaroo គឺជាប្រភេទរុក្ខជាតិម្យ៉ាងក្នុងចំណោមក្រុមនៃរុក្ខជាតិទាំង ១២ប្រភេទ ផ្សេងទៀតដែលអាចដុះឡើងវិញជារៀងរាល់ឆ្នាំ និងមានផ្កាពណ៌បៃតង និងក្រហមកាំម៉ីជាច្រើន ចាប់ពីចុងរដូវរងារហូតដល់រដូវផ្ការីក។ ចង្កោមនៃផ្កាមានរូបរាងប្រហាក់ប្រហែលនឹងក្រញាំនៃសត្វ Kangaroo។ ផ្កានេះត្រូវបានគេផ្តល់តម្លៃដោយសារតែពណ៌ក្រហម និងពណ៌បៃតងភ្លឺរបស់វា ប៉ុន្តែរុក្ខជាតិនេះអាចត្រូវបានរកឃើញតែនៅក្នុងតំបន់ភាគខាងត្បូងនៃប្រទេសអូស្ត្រាលីខាងលិចប៉ុណ្ណោះ។



### ១៦.ផ្កាដែលមានរូបរាងស្រដៀងទៅនឹងបបូរមាត់សិចស៊ី ( *Psychotria Elata - Hooker's Lips* )

ផ្កាពិសេសនេះត្រូវបានគេហៅថា *Psychotria elata* ដែលត្រូវបានគេស្គាល់ថាជាផ្កាមានរាងដូចទៅនឹងបបូរមាត់ដ៏សិចស៊ី (Hooker's Lips ឬ Hot Lip Plants)។ វាត្រូវបានគេរកឃើញនៅក្នុងព្រៃរងទឹកភ្លៀងភាគកណ្តាល និងខាងត្បូងនៃប្រទេសអាមេរិក , កូឡុំប៊ី (Colombia), កូស្តារីកា (Costa Rica), ប៉ាណាម៉ា (Panama) និងអេក្វាឌ័រ (Ecuador)។ លក្ខណៈរូបរាងដែលស្រដៀងនឹងការថើប ហើយពណ៌ក្រហមភ្លឺរបស់វាបានធ្វើឱ្យមានការទាក់ទាញភ្នាក់ងារចម្លងលម្អងជាច្រើនដូចជា ពពួកសត្វល្អិត មេអំបៅ និងបក្សី។ វាជាផ្កាដែលមានដើមកំណើតនៅក្នុងតំបន់ព្រៃត្រូពិច ហើយត្រូវបានគេស្គាល់ផងដែរថាជា ផ្កាថើបដ៏សិចស៊ី (Hot Flower Kiss)។



### ១៧.ផ្កាដែលមានរូបរាងស្រដៀងទៅនឹងស្លាបមេអំបៅក្រហម ( *Christia vespertilionis* - the Red Butterfly Wing )

ផ្កានេះមើលទៅដូចហ្វូងមេអំបៅកំពុងហោះហើរ ហើយផ្កាស្លាបមេអំបៅក្រហមនេះ គឺជាប្រភេទផ្កាត្រូពិចដ៏កម្រដែលមានដើមកំណើតមកពីអាស៊ីអាគ្នេយ៍ ហើយអាចដុះលូតលាស់ដល់កម្ពស់ ៦០ ទៅ ១២០ សង់ទីម៉ែត្រ។ ទោះបីជាវាកម្រមានក៏ដោយ វាត្រូវបានគេរាយការណ៍ថាវាងាយស្រួលដាំដុះណាស់ ទោះបីជាគ្រាប់ពូជអាចពិបាកក្នុងការរកក៏ដោយ។





## ១៨.ផ្កាដែលមានរូបរាងស្រដៀងទៅនឹងក្មេងស្រីតូច កំពុងរាំ ( *Impatiens Bequaertii* - Dancing Girl Impatiens )

ផ្កាប្រភេទនេះ ជាប្រភេទកម្រដែលមានដើមកំណើតពីព្រៃរងទឹកភ្លៀងនៃអាហ្វ្រិកខាងកើត។ ផ្កាក្មេងស្រីរបាំនេះ គឺជាប្រភេទពិសេស និងប្លែកអស្ចារ្យក្នុងអំបូរ Impatiens ដែលត្រូវបានជ្រើសរើស។ វាជាប្រភេទរុក្ខជាតិលម្អក្នុងផ្ទះដ៏អស្ចារ្យ ហើយកាន់តែមើលទៅស្រស់ស្អាតនៅពេលដាំក្នុងកន្ត្រកព្យួរ។ រុក្ខជាតិដ៏តូចនេះដុះបានត្រឹមតែមួយហ្វីត (៣០.៤៨សម) ប៉ុណ្ណោះ ហើយផ្កាមានប្រវែងប្រហែល ១.២សង់ទីម៉ែត្រ ប៉ុន្តែរូបរាងនេះធ្វើឱ្យវាមានទាក់ទាញយ៉ាងខ្លាំង។ ត្របកផ្ការបស់វាស្រដៀងនឹងក្មេងស្រីតូចដែលស្លៀកសំពត់ និងលាតសន្ធឹងដៃទាំងពីរ។ ផ្កាពណ៌ស ឬពណ៌ផ្កាឈូកស្រាលទាំងនេះរីកពេញមួយឆ្នាំ ហើយស្លឹករបស់វាក៏ទាក់ទាញផងដែរ។ វាជាប្រភេទផ្កាដែលអាចដុះឡើងវិញជារៀងរាល់ឆ្នាំ និងដុះវារឡើងដល់ប្រហែល ២០សង់ទីម៉ែត្រ ហើយឫសរបស់វាអាចដុះគ្រប់ទីកន្លែងដែលវាប៉ះដី។ ផ្កាភាគច្រើនពណ៌សនៅពេលរីក ប៉ុន្តែម្តងម្កាលមានពណ៌ផ្កាឈូកស្រាល និងមានចំណុចពណ៌លឿងចំនួន ០២ នៅលើផ្កា។ ស្លឹករាងបេះដូងមានពណ៌បៃតងនៅផ្នែកខាងលើ ហើយផ្នែកខាងក្រោមមានពណ៌ដូចស្រាក្រហម ដូចទៅនឹងមែកធាងដែរ។ វាជាពូជសុទ្ធមិនមែនបង្កាត់ តែវាអាចបង្កាត់ជាមួយប្រភេទ Impatiens ផ្សេងទៀតដើម្បីបង្កើតពូជថ្មី។



## ១៩.ផ្កាដែលមានរូបរាងស្រដៀងទៅនឹងតួបិសាចក្នុងរឿង Star War ( *Aristolochia Salvadorensis* - Darth Vader)

ផ្កាអ័រគីដេ *Aristolochia salvadorensis* មានដើមកំណើតនៅអាមេរិកកណ្តាល និងជាប្រភេទចុល្លព្រឹក្សតូចៗដែលមិនធន់នឹងអាកាសធាតុត្រជាក់។ ទងផ្កាដុះលូតវែងនៅតាមដីមានរាងដូចជាស្រោមមុខ "Darth Vader" ដែលមានពណ៌ក្រហមក្រម៉ៅ។ ផ្កានីមួយៗបន្តរីកក្នុងរយៈពេលមួយសប្តាហ៍ ឬយូរជាងនេះ។ ដើមរបស់វាមានកម្ពស់ ៣-៥ម៉ែត្រ និងផ្ការាងជាបំពង់ដែលតោងជាប់ឆ្លាស់គ្នា។ វាជារុក្ខជាតិមានភេទពីរនៅក្នុងផ្កាតែមួយ។ ផ្ការបស់វាមានលក្ខណៈជ្រួញៗ ហើយមានត្របកផ្កាចំនួន០៣។ ផ្កាមានទំហំប៉ុននឹងពែងប្រវែង ៤-៥សង់ទីម៉ែត្រ ដែលមានកេសរឈ្មោល ចំនួន ០៦ ហើយកេសរញីមានចំនួនតិចជាង និងលក្ខណៈរឹង។ រុក្ខជាតិប្រភេទនេះអាចបន្តពូជដោយការកាត់ផ្សាំ។



### ឯកសារយោង


១. https://www.indiatimes.com/
២. https://www.facebook.com/Afteen.me/

# តែស្លឹកឫស្សី

ដោយលោក ឃឿង អឿងតិច រដ្ឋបាលព្រៃឈើ

*ឯកសារយោង៖ គេហទំព័រ khmerload*



ឫស្សី ជាប្រភេទរុក្ខជាតិម្យ៉ាងមានដុះដោយធម្មជាតិ និងងាយដាំដុះ ហើយមានសារប្រយោជន៍ច្រើនយ៉ាង គេអាចប្រើសម្រាប់ធ្វើជាគ្រឿងសំណង់ គ្រឿងសង្ហារិម គ្រឿងតាំងលម្អ សម្ភារប្រើប្រាស់ផ្សេងៗ ឧបករណ៍នេសាទ ឧបករណ៍ភ្លេង វេចខ្ចប់ធ្វើនំ ធ្វើជាអាហារ ធ្វើជាឱសថជាដើម។ ជាមួយគ្នានោះ អ្វីដែលយើងមិនសូវបានចាប់អារម្មណ៍ គឺស្លឹកឫស្សីអាចយកមកធ្វើជាទឹកតែជំនួយសុខភាពបានច្រើនយ៉ាងផងដែរ ដោយវិធីងាយៗតែទទួលបានអត្ថប្រយោជន៍ច្រើនយ៉ាង។ អត្ថប្រយោជន៍របស់តែស្លឹកឫស្សី រួមទាំងវិធីធ្វើងាយៗក្នុងការធ្វើតែនេះមានដូចខាងក្រោម៖



*ដើមឫស្សី ដែលបានដាំនៅទីជនបទស្រុកស្រែចង្ក្រារ*

### ១. ជំនួយសក់ ក្រចក ធ្មេញ និងឆ្អឹង

ស្លឹកឫស្សី ផ្ទុកនូវបរិមាណដ៏ច្រើនលើសលប់នៃសារធាតុ Silica ដែលត្រូវបានគេដឹងថា សារធាតុមួយនេះមានគុណប្រយោជន៍វិសេសវិសាសណាស់សម្រាប់ជួយទៅពង្រឹងសុខភាពឆ្អឹង ធ្មេញ ក្រចក រួមទាំងសសៃសក់ឱ្យរឹងមាំ ដុះលូតលាស់ល្អ។ មិនតែប៉ុណ្ណោះ ថែមទាំងជួយថែរក្សារូបសម្រស់ស្បែករបស់អ្នកឱ្យស្រស់ស្អាតផងដែរ។

### ២. ជំនួយប្រព័ន្ធរំលាយអាហារ

ស្លឹកឫស្សី ក៏ត្រូវបានគេដឹងថា សម្បូរទៅដោយជាតិកាកសរសៃហ្វៃបឺ(Fiber) ដែលអាចជំនួយដល់ប្រព័ន្ធរំលាយអាហារឱ្យដំណើរការល្អ និងជំនួយសុខភាពក្រពះ ពោះវៀន ថែមទាំងជួយព្យាបាលជំងឺទល់លាមកបានទៀតផង។

### ៣.សារធាតុប្រឆាំងអុកស៊ីតកម្ម និងរ៉ាឌីកាល់សេរី

សារធាតុប្រឆាំងអុកស៊ីតកម្ម និងPolyphenols ដែលអាចធ្វើការប្រឆាំងនឹងរ៉ាឌីកាល់សេរី អាចជួយកាត់បន្ថយការលូតលាស់នៃកោសិកាមិនប្រក្រតីមួយចំនួនដែលគ្រោះថ្នាក់ដូចជា ជំងឺមហារីកជាដើម រួមទាំងការពារការកើតមានបញ្ហាសុខភាពជាច្រើនមុខទៀត។



*តែស្លឹកឫស្សី*

### ៤.ប្រឆាំងនឹងការរលាក និងជំងឺហឺត

ស្លឹកឫស្សី ក៏ពោរពេញទៅដោយសារធាតុម្យ៉ាងដែលអាចជួយកាត់បន្ថយអាការហើម និងរលាកក្នុងរាងកាយបានល្អ ថែមទាំងជួយកាត់បន្ថយការកើតមានជំងឺទាក់ទងនឹង

ភាពធាត់ជុះក្បាលពោះ ជំងឺបេះដូង រួមទាំងជំងឺហឺតបានផងដែរ។

### ៥.បណ្តេញជាតិពុល និងសម្រកទម្ងន់

តែពីស្លឹកឫស្សី ក៏អាចមានលទ្ធភាពជួយបណ្តេញជាតិពុលដែលមានគ្រោះថ្នាក់ចេញពីរាងកាយរបស់អ្នកផងដែរ។ លើសពីនោះ ការទទួលទានតែពីស្លឹកឫស្សី ត្រូវបានគេដឹងថា អាចជំនួយដល់ការសម្រកទម្ងន់បាន ដោយសារតែកាកសសៃហ្វៃបឺដែលមាននៅក្នុងទឹកតែមួយនេះ ជួយធ្វើឱ្យអ្នកមានអារម្មណ៍ថាឆ្អែតបានយូរ និងទទួលទានអាហារបានតិចជាងមុន។

### ៦.ការពារជំងឺទឹកនោមផ្អែម

ស្លឹកឫស្សី ត្រូវបានគេដឹងថា អាចជួយកាត់បន្ថយបរិមាណជាតិស្ករនៅក្នុងខ្លួន ដែលទាំងនេះមានប្រយោជន៍សម្រាប់ការពារការកើតជំងឺទឹកនោមផ្អែម ថែមទាំងមានផលល្អចំពោះអ្នកដែលកំពុងតែកើតមានជំងឺទឹកនោមផ្អែមផងដែរ។

### ៧.ការពារជំងឺលើសឈាម

ការទទួលទាន តែស្លឹកឫស្សីជាប្រចាំ ត្រូវបានគេដឹងផងដែរថា អាចជួយធ្វើឱ្យសម្ពាធឈាមរបស់អ្នកមានលំនឹង ថែមទាំងជំនួយដល់អ្នកដែលកំពុងតែមានជំងឺលើសឈាមទៀតផង។



តែស្លឹកឫស្សី ដែលមានលទ្ធភាពជួយបណ្តេញជាតិពុល

### ៨. បន្ថយការឈឺចុកចាប់ពេលមករដូវ

ការទទួលទាន តែស្លឹកឫស្សី ក៏អាចជួយបន្ថយអាការឈឺចុកចាប់សម្រាប់ស្ត្រីដែលមករដូវបានយ៉ាងប្រសើរ ដូចជា ការឈឺ ឬចុកក្នុងពោះ ការឈឺឆ្អឹង ឈឺខ្នង និងឈឺសាច់ដុំជាដើម។

### ៩.ជំនួយតម្រងនោម

ស្លឹកឫស្សី ថែមទាំងអាចជួយការពារ និងព្យាបាលជំងឺទាក់ទងនឹងតម្រងនោម និងប្លោកនោមបានផងដែរ។ ដោយការទទួលទានតែស្លឹកឫស្សីជាប្រចាំ អាចមានលទ្ធភាពជួយបញ្ចុះទឹកនោមដែលអាចការពារ និងព្យាបាលជំងឺទាក់ទងនឹងប្លោកនោមទាំងនេះបានយ៉ាងប្រសើរ។

### ១០.ជួយបន្ធូរបន្ថយភាពតានតឹង

ទទួលទានតែស្លឹកឫស្សី អាចមានប្រសិទ្ធភាពជួយកាត់បន្ថយអាការស្ត្រេស ធុញថប់ក្នុងអារម្មណ៍ និងអាការហត់នឿយផ្សេងៗបានយ៉ាងល្អ។ នៅក្នុងនោះផងដែរ ក្លិនដ៏ឈ្ងុយនៅក្នុងស្លឹកតែថែមទាំងជួយធ្វើឱ្យក្រអូមមាត់របស់អ្នកមានក្លិនស្រស់ថ្លា ជំនួយបន្ថែមធ្វើឱ្យអ្នកកាន់តែមានអារម្មណ៍ល្អទៀតផង។



តែស្លឹកឫស្សី អាចជួយបន្ថយអាការឈឺចុកចាប់សម្រាប់ស្ត្រីដែលមករដូវបានយ៉ាងប្រសើរ

### ១១.ជំនួយ និងពង្រឹងសុខភាពទូទៅ

ការទទួលទានតែស្លឹកឫស្សីជាប្រចាំ នឹងអាចជួយទៅជំនួយ និងពង្រឹងសុខភាពរាងកាយរបស់អ្នកទាំងមូលឱ្យកាន់តែមានសុខភាពល្អបន្ថែមទៀត។ ម្យ៉ាងវិញទៀត ប្រសិនជាអ្នកមានស្នាម ឬរបួសផ្សេងៗ តែស្លឹកឫស្សីថែមទាំងមានលទ្ធភាពឱ្យការព្យាបាលកាន់តែឆាប់ជាសះស្បើយផងដែរ។

## ១២.ជំនួយសម្រស់

ការទទួលទានតែស្លឹកឫស្សី ត្រូវបានដឹងថាអាចផ្តល់វីតាមីន និងធាតុរ៉ែសំខាន់ៗ ទៅបំប៉នស្បែកពីក្នុងរាងកាយឱ្យមានសុខភាពល្អ ស្រស់ថ្លា រួមទាំងស្បែកស្រស់ស្អាតក្មេងខ្ចីផងដែរ។ លើសពីនេះ អ្នកក៏អាចយកស្លឹកឫស្សីមកធ្វើជាម៉ាស់ថែរក្សាស្បែកមុខឱ្យ ស រលោង ស្រស់ស្អាត ម៉ដ្ឋខៃ រួមទាំងបំបាត់បញ្ហាស្បែកអាលែកហ្ស៊ី ដោយគ្រាន់តែកិន ឬបុកស្លឹកឫស្សីឱ្យម៉ដ្ឋលាយជាមួយប្រេងដូងឬប្រេងអូលីវ សឹមយកមកលាបលើស្បែកមុខជាការស្រេច។

## វិធីធ្វើតែពីស្លឹកឫស្សី

### វិធីទី១ ៖

- យកស្លឹកឫស្សីស្ងួត ប្រមាណជា ១ស្លាបព្រា ដាំជាមួយនឹងទឹកស្អាត ២ទៅ៣ពែងឱ្យពុះរយៈពេល ៣ ទៅ ៥នាទី ចាំបិទភ្លើង

-ទុកឱ្យវាចេញជាតិប្រមាណជា១០នាទីបន្ថែមទៀត ឬលើសពីនេះ ប្រសិនជាអ្នកចង់បានតែរាងចាស់បន្តិច។

- ជាចុងក្រោយអ្នកអាចទទួលទានវា ដោយអាចបង្កើនរសជាតិ ដោយការលាយជាមួយទឹកឃ្មុំ ឬក្រូចឆ្មារបន្ថែមទៀតក៏បាន។



គ្រឿងផ្សំសម្រាប់ធ្វើតែស្លឹកឫស្សី(វិធីទី១)

### វិធីទី២ ៖

- យកស្លឹកឫស្សីប្រមាណជា ១០សន្លឹក ស្រស់ៗ និងខ្ចីដាំជាមួយនឹងទឹកស្អាត១ផ្តាំង ឱ្យពុះរយៈពេល៣ ទៅ ៥នាទី ចាំបិទភ្លើង

-ទុកឱ្យវាចេញជាតិប្រមាណជា ១០នាទីបន្ថែមទៀត ឬលើសពីនេះប្រសិនជាអ្នកចង់បានតែរាងចាស់បន្តិច។

- ជាចុងក្រោយអ្នកអាចទទួលទានវា ដោយអាចបង្កើនរសជាតិ ដោយការលាយជាមួយទឹកឃ្មុំ ឬក្រូចឆ្មារបន្ថែមទៀតក៏បាន។



តែស្លឹកឫស្សី(វិធីទី២)

**ចំណាំ៖** អ្នកក៏អាចទិញកញ្ចប់តែពីផ្សារមកប្រើការក៏បាន តែត្រូវប្រាកដថា វាគឺជាតែធម្មជាតិ គ្មានជាតិគីមី៕



តែស្លឹកឫស្សីនៅទីផ្សារអាចមានជាថង់តូចៗ

# អត្ថប្រយោជន៍របស់ ផ្លែរកាំ ឬសាឡាក់

ដោយលោក **ឃឿង ឃឿងតិច** រដ្ឋបាលព្រៃឈើ

*ឯកសារយោង៖* គេហទំព័រ khmerload, kbn.news, chomreun

ផ្លែរកាំ ឬគេនិយមហៅផ្លែសាឡាក់(Salak) តាមភាសាបរទេស គឺជាផ្លែឈើមួយប្រភេទដែលមួយរយៈក្រោយនេះ មានការហូរចូល និងមានការលក់ជាហូរហែតាមការពេញនិយមទទួលទានរបស់ប្រជាជនក្នុងប្រទេសរបស់យើង។ អ្នកខ្លះក៏និយមទទួលទានលេងជាបង្អែម ឬម្ជូរលាងមាត់ អ្នកខ្លះក៏យកមកប្រឡេះសាច់វាក្រឡុកជាមួយអំបិលម្ទេស ដោយសារតែវាមានរសជាតិជូរអែមឆ្ងាញ់ពិសា។ ផ្លែរកាំមានរសជាតិជូរអែម ឬផ្អែមអាស្រ័យតាមពូជរបស់វា។ វាជាតាលព្រឹក្ស ដើមវាមានធាងវែងៗមានបន្លារឹង ស្លឹកដុះចេញពីធាងជាស្និតមិនរៀបរយស្រដៀងនឹងផ្តៅសោម។ កញ្ចុំផ្កាដុះចេញពីគល់ប្រគាបស្លឹក ផ្លែចេញជាធ្លាយ ដែលផ្លែនីមួយៗរាងស៊ុតស្រួចចុងក្រហមជាំ សម្បកផ្លែមានបន្លាមុតតូចៗ។ វាបន្តពូជដោយគ្រាប់ ហើយច្រើនដុះដោយខ្លួនឯងនៅតាមតំបន់ភ្នំ គេធ្លាប់ប្រទះឃើញច្រើននៅខេត្តកោះកុង។



ផ្លែរកាំនៅជាប់នឹងដើមរបស់វា




ក្រៅអំពីរសជាតិជូរអែមឆ្ងាញ់ហើយនោះ ផ្លែរកាំក៏ត្រូវបានគេដឹងថា មានប្រយោជន៍ចំពោះសុខភាព និងសម្រស់ផងដែរ។ នៅក្នុងផ្លែរកាំមានសារជាតិបេតាឃែរ៉ូទីន ដែលជាវីតាមីនដើមរបស់វីតាមីនA ច្រើនជាងការ៉ុតដល់ទៅ ១០ដង។ សន្ទះស្រោមរបស់ផ្លែរកាំមានសារជាតិឡៃខូភីន ច្រើនជាងប៉េងប៉ោះដល់ទៅ៧០ដង។ ប្រូតេអ៊ីននៅក្នុងទឹករកាំមានសារជាតិឱសថអាចប្រឆាំងជាមួយមហារីកយ៉ាងល្អ ពិសេសរោគមហារីកក្រពេញពងស្វាស មហារីកសួត និងមហារីកក្រពះ។ ក្រៅពីនេះសារជាតិក្នុងផ្លែឈើប្រភេទនេះអាចជួយទប់ស្កាត់ការរីកលូតលាស់នៃមេរោគ HIV បានថែមទៀត។



ផ្លែរកាំ និងសាច់ផ្លែវាដែលគេបកក្រឡុកអំបិលម្ទេស

អត្ថប្រយោជន៍ផ្លែរកាំមានដូចខាងក្រោមៈ

**១.ការពារអាការស្លេកស្លាំង រាគរូស និងអស់កម្លាំង**

ប្រភពវីតាមីន C និងជាតិដែក ដែលមាននៅក្នុងផ្លែរកាំ ត្រូវបានគេដឹងថា អាចជំនួយថាមពលរាងកាយទាំងមូល បំបាត់ភាពអស់កម្លាំង និងការពារភាពស្លេកស្លាំងផងដែរ។ មិនតែប៉ុណ្ណោះថែមទាំងអាចការពាររាងកាយពីការកើតជំងឺរ៉ាំរ៉ៃមួយចំនួន និងការពារពីជំងឺរាករូសព្រោះវាមានផ្ទុកជាតិកាកសរសៃ ដែលជាសារធាតុមានជីវជាតិខ្លាំង។

**២. ជំនួយឆ្អឹង**

ជាតិកាល់ស្យូម ដែលមាននៅក្នុងផ្លែរកាំ ត្រូវបានគេដឹងថាអាចមានតួនាទីជាជំនួយ ពង្រឹងសុខភាពឆ្អឹង និងធ្មេញឱ្យរឹងមាំមិនចាញ់ផលិតផលទឹកដោះគោ ឬផ្លែឈើដទៃទៀតនោះទេ ថែមទាំងការពារការកើតជំងឺផ្សេងៗទាក់ទងនឹងមាត់ធ្មេញ និងការពារការឈឺចាប់គ្រង់សន្លាក់ឆ្អឹង និងជំងឺពុកឆ្អឹងជាដើម។

**៣.ប្រភពប្រូតេអ៊ីនជំនួយសាច់ដុំ**

ផ្លែរកាំសម្បូរទៅដោយជាតិប្រូតេអ៊ីន និងផូស្វ័រ ដែលមានតួនាទីលើកកម្ពស់សុខភាពរាងកាយ ធ្វើឱ្យមានតុល្យភាពអរម៉ូនក្នុងរាងកាយ ជួសជុលកោសិការាងកាយដែលខូចខាត ថែមទាំងអាចជំនួយដល់សាច់ដុំឱ្យរឹងមាំផងដែរ ជាពិសេសជំនួយដល់អ្នកដែលចង់ហាត់ប្រាណយកសាច់ដុំ។

**៤.សារធាតុប្រឆាំងអុកស៊ីតកម្ម ពង្រឹងប្រព័ន្ធភាពស៊ាំ**

ផ្លែរកាំផ្ទុកទៅដោយសារធាតុ Beta-Carotene និងសារធាតុប្រឆាំងអុកស៊ីតកម្មដែលអាចជំនួយដល់សុខភាពបេះដូងឱ្យរឹងមាំ ថែមទាំងអាចមានលទ្ធភាពការពាររាងកាយពីជំងឺតម្កាត់ផ្សេងៗ ជាពិសេសគឺជំងឺដាច់សរសៃឈាម ជំងឺបេះដូង ជំងឺដាច់សរសៃឈាមខួរក្បាល និងជំងឺមហារីក ជាដើម។

**៥.ជួយដល់ការសម្រកទម្ងន់**

មិនត្រឹមតែជារបបផ្លែឈើដ៏ល្អសម្រាប់ទទួលទាននោះទេ ផ្លែរកាំថែមទាំងគ្មានជាតិកាឡូរីដែលធ្វើឱ្យធាត់ទៀតផង។ ជាពិសេសវាមានអាហារូបត្ថម្ភសំខាន់ៗដែលអាចជួយគ្រប់គ្រងទម្ងន់ និងជំនួយដល់ការសម្រកទម្ងន់ផងដែរ ប្រសិនជាអ្នកទទួលទានវាពេលព្រឹក។

**៦.ជំនួយគ្រាប់ភ្នែក**

ជាតិ Beta-Carotene និងវីតាមីន C ដែលមាននៅក្នុងផ្លែរកាំគឺជាឱសថធម្មជាតិដែលអាចជំនួយគ្រាប់ភ្នែកឱ្យមានភាពភ្លឺថ្លា និងការពារពីការកើតជំងឺភ្នែកផ្សេងៗ ដូចជាជំងឺខ្វាក់មាន់ (ងងឹតនៅពេលយប់) ជាដើម។

**៧.ជំនួយដល់ការចងចាំ**

ជាតិប៉ូតាស្យូម និង Pectin ដែលមាននៅក្នុងផ្លែរកាំអាចមានលទ្ធភាពជំនួយដល់សុខភាពខួរក្បាល បង្កើនការចងចាំ ការគិត និងការយល់ដឹងឱ្យប្រសើរជាងមុន។

**៨.គ្រប់គ្រងកម្រិតជាតិស្ករក្នុងឈាម**

សារធាតុ Pterostilbene ដែលមាននៅក្នុងផ្លែរកាំអាចជួយកាត់បន្ថយជាតិគ្លុយកូស(ស្ករ) ដែលមាននៅក្នុងឈាម។ ជាពិសេសអាចការពារការឡើងជាតិស្ករក្នុងរាងកាយ និងជួយគ្រប់គ្រងកម្រិតជាតិស្ករជំនួយដល់អ្នកកើតជំងឺទឹកនោមផ្អែមផងដែរ។

**៩.ល្អសម្រាប់ស្ត្រីមានផ្ទៃពោះ**

សម្រាប់ស្ត្រីដែលមានផ្ទៃពោះ ការទទួលទានផ្លែរកាំអាចផ្តល់សារធាតុចិញ្ចឹមសំខាន់ៗសម្រាប់សុខភាពម្តាយ និងទារកក្នុងផ្ទៃ ថែមទាំងជំនួយធ្វើឱ្យទារកក្នុងផ្ទៃមានស្បែកស្រស់ស្អាតគួរឱ្យស្រលាញ់ផងដែរ។ ក្រៅពីនេះ ការទទួលទានផ្លែរកាំ ថែមទាំងអាចជួយការពារ និងកាត់បន្ថយអាការៈចាញ់កូនថែមទៀតផង។

**១០.ជំនួយសុខភាពស្បែក**

ដើម្បីឱ្យស្បែកស្រស់ស្អាតភ្លឺថ្លា អ្នកអាចទទួលទានផ្លែរកាំជាប្រចាំ។ ដោយសារតែផ្លែរកាំមានសារធាតុប្រឆាំងអុកស៊ីតកម្ម និងរ៉ាឌីកាល់សេរី ដែលអាចជួយធ្វើឱ្យស្បែកស្អាត មានសុខភាពល្អ ក្មេងជាងវ័យ ថែមទាំងអាចការពារស្បែកចាស់ជ្រីវជ្រួញទៀតផង។

# រុក្ខជាតិឱសថ

# ដើមក្រពាត់ជ្រូក

## *Xanthium strumarium* L.

## ASTERACEAE

-ឈ្មោះខ្មែរ៖ ក្រពាត់ជ្រូក

-ឈ្មោះវិទ្យាសាស្ត្រ៖ *Xanthium strumarium L.*

-ឈ្មោះអម្បូរ៖ ASTERACEAE

ដើមក្រពាត់ជ្រូក គឺជាប្រភេទរុក្ខជាតិដុះនៅតាមព្រៃស្រោង ដុះនៅមាត់ត្រពាំង និងទន្លេសាប ក្នុងប្រទេសកម្ពុជា នារដូវទឹកសម្រក វាមានកម្ពស់ប្រហែល១ម៉ែត្រ ស្លឹកមានរាងស្លាបព្រួញ និងគែមធ្មេញរណារ ផ្ការាងដូចកួរសណ្ដែក ខ្លះចេញនៅមែកខ្ចីៗ ខ្លះចេញនៅប្រគាប់ស្លឹក ផ្លែតូចៗរាងពងក្រពើ មានបន្លាស្រួចៗញឹក ងាយនឹងជាប់ខោអាវ ឬសក់ ដែលក្មេងៗចូលចិត្តលេងដាក់លើក្បាលគ្នា។

ដើមក្រពាត់ជ្រូកមានអត្ថប្រយោជន៍ច្រើនយ៉ាង ដូចជា ធ្វើថ្នាំជួយសម្រួលឱ្យញើសចេញតាមស្បែក ប្រឆាំងនឹងជំងឺសើរស្បែក រមាស់ពងបែក កន្ទាលត្រអាក រមាស់កន្ទួលក្រហម បូស ទឹកនោមផ្អែម ជំងឺផ្លូវដង្ហើម រលាកច្រមុះរ៉ាំរ៉ៃ ឈាមច្រមុះ ជំងឺផ្លូវអាហារ ឈឺបំពង់ក ព្យាបាលឈឺធ្មេញ រាគមូល នោមទាស់ សម្រួលអារម្មណ៍ និងជាថ្នាំប្រឆាំងគ្រុនចាញ់។

ដើមរុក្ខជាតិនេះ ផ្ទុកសារធាតុគីមី ដូចជា ជាតិខ្លាញ់ carbohydrate saponins alkaloids glucosides polyphenol និង sesquiterpene lactone xathatin (ដែលមានលក្ខណៈប្រឆាំងនឹងមេរោគ)។

-**ឫស**៖ឆុងទឹកក្ដៅជាថ្នាំល្វីង ប្រើព្យាបាលដំបៅក្រពះ ពិសបូស។

-**ស្លឹក**៖ប្រើជាថ្នាំ រឹត ទប់ទល់ការភ្លោចប្រព័ន្ធប្រសាទ។

-**ផ្លែ**៖ ផ្លែឆុងទឹកក្ដៅប្រើជាថ្នាំប្រឆាំងនឹងជំងឺទឹកនោមផ្អែម។ ផ្លែស្ងោរម្ទាស់យកទឹកបៀមព្យាបាលឈឺធ្មេញ និងលាបលើស្បែកព្យាបាលផ្សិត កមររមាស់។

-**គ្រាប់**៖ ប្រើជាថ្នាំបន្ថយហើម រលាក និងព្យាបាលជំងឺឫសដូងបាត។

រុក្ខជាតិនេះមានជាតិពុលតិចតួចទៅនឹងប្រព័ន្ធសរសៃប្រសាទកណ្ដាល ដែលបង្កើតឱ្យមានអាការៈដូចជា ដង្ហើមមិនប្រក្រតី នាំឱ្យពិបាកដកដង្ហើម រួចសន្លប់បាត់ស្មារតី។ បច្ចុប្បន្ននេះ អ្នកស្រាវជ្រាវកំពុងពិនិត្យលើដើមក្រពាត់ជ្រូក ដើម្បីស្វែងរកលក្ខណៈប្រឆាំងជំងឺមហារីកថែមទៀតផង។



ដើម និងឫសរបស់ដើមក្រពាត់ជ្រូក




ផ្កា ផ្លែខ្ចី ផ្លែទុំ និងគ្រាប់របស់ដើមក្រពាត់ជ្រូក

ដោយលោក **ឃៀង ឡេងតិច** រដ្ឋបាលព្រៃឈើ

*ឯកសារយោង៖ គេហទំព័ររុក្ខជាតិជាឱសថបុរាណខ្មែរ*

# ការសិក្សាស្រាវជ្រាវវត្តមានឧរង្គសត្វ និងថលជលិកសត្វ នៅក្នុងតំបន់គម្រោងរេដបូកទំរីង ខេត្តកំពង់ធំ

*ដោយកញ្ញា សាន់ សុវណ្ណារី មន្ត្រីនាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ*

## ១.សេចក្ដីផ្ដើម

ឧរង្គសត្វ និងថលជលិកសត្វ គឺជាប្រភេទសត្វដែលមានឈាមត្រជាក់ និងសីតុណ្ហភាពនៅក្នុងខ្លួនវាគឺវាប្រែប្រួលទៅតាមបរិស្ថានជុំវិញវាដើម្បីរស់នៅ។ ក្រុមថលជលិកសត្វមានបីក្រុមមាន លំដាប់អានូរ៉ា Anura (ថលជលិកសត្វដែលគ្មានកន្ទុយៈ កង្កែប គីង្គក់ កញ្ចាញ់ចេក), សាខាខូដេតា (Codeta) ជាពពួកមានឆ្អឹងកងខ្នង( ថជលិកសត្វដែលមានកន្ទុយៈ សាលាវេនឌឺ(salamanders) និង នូ(newts)) និងអំបូរជីមណូហ្វីអូណា(Gymnophiona) ជាពពួលថជលិកសត្វដែលមានជើងតិចតួចៈ សេស៊ីលៀន(caecilians)។ ក្រុមឧរង្គសត្វមានបីក្រុមធំៗ មានដូចជា អណ្ដើក(ប្រហែល ៣០០ប្រភេទ), បង្គួយ និងពស់ (ប្រហែល៦០០០ប្រភេទ), និងក្រពើ (ប្រហែល២១ប្រភេទ)។ អនុក្រឹត្យលេខ ៧៤ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការបង្កើតដែនជម្រកសត្វព្រៃព្រៃឡង់ដែលមានទំហំផ្ទៃដី៤៣១ ៦៨៣ហិកតា ស្ថិតក្នុងខេត្តកំពង់ធំ ព្រះវិហារ ស្ទឹងត្រែង និងខេត្តក្រចេះ។

ករណីសិក្សាមួយក្នុងឆ្នាំ២០១៥ដែលគេធ្វើការសិក្សាសត្វឧរង្គសត្វ និងថលជលិកសត្វ នៅក្នុងដែនជម្រកសត្វព្រៃ ព្រៃឡង់បានឃើញមានចំនួន ៦៧ប្រភេទ ដោយលោក នាង ធី។

ការសិក្សារកឃើញប្រភេទថ្មីចំនួន០២ដែលត្រូវបានគេពិពណ៌នានៅដែនជម្រកសត្វព្រៃ ព្រៃឡង់ មានប្រភេទថ្លែនព្រៃឡង់ (*Spenomorphus preylangensis*) និងតុកកែភ្នំជី (*Cyrtodactylus phnomchiensis*) ។

គម្រោងរេដបូកទំរីង មានទំហំផ្ទៃដីសរុបចំនួន ៤១ ១៦៦ហិចតា។ នៅក្នុងខែធ្នូ ឆ្នាំ២០២១ នាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ នៃរដ្ឋបាលព្រៃឈើ និងមជ្ឈមណ្ឌលអភិរក្សជីវចម្រុះនៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចុះធ្វើការសិក្សាស្រាវជ្រាវវត្តមានឧរង្គសត្វ និងថលជលិកសត្វដែលមាននៅក្នុងតំបន់គម្រោងរេដបូកទំរីង ខេត្តកំពង់ធំ។ គោលបំណងនៃការធ្វើសិក្សាគឺដើម្បីធ្វើការសិក្សាពីវត្តមានឧរង្គសត្វ និងថលជលិកសត្វ និងការសិក្សាពីចំនួនប្រភេទ និងចំនួនក្បាលពីវត្តមានសត្វព្រៃក្នុងសហគមន៍ព្រៃឈើ គម្រោងរេដបូកទំរីង។




រូបភាពទី១ ផែនទីទីតាំងសិក្សាស្រាវជ្រាវវត្តមានឧរង្គសត្វ និងថលជលិកសត្វ ក្នុងតំបន់គម្រោងរេដបូកទំរីងខេត្តកំពង់ធំ

## ២.វិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវ

### ២.១. ទីតាំងសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងរយៈពេល ១០ថ្ងៃ ចាប់ពីថ្ងៃ០៦ ដល់ថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ២០២១ បានចុះសិក្សាស្រាវជ្រាវនៅក្នុងសហគមន៍ព្រៃឈើចំនួន៧កន្លែង និង០១កន្លែងទៀតជាស្ថាននីយ៍ស្រាវជ្រាវវត្តទឹក ស្ថិតក្នុងស្រុកសណ្ដាន់ និងស្រុកសន្ទុក ខេត្តកំពង់ធំ។ សហគមន៍ព្រៃឈើទាំង០៧កន្លែង និង០១កន្លែងជាស្ថាននីយស្រាវជ្រាវវត្តទឹកគឺស្ថិតក្នុងតំបន់គម្រោងរេដបូកទំរីង។

ការសិក្សាមាននៅសហគមន៍ព្រៃឈើព្រៃអូរក្រញាក សហគមន៍ព្រៃឈើព្រៃតាតៃ សហគមន៍ព្រៃឈើអូរក្រញូង សហគមន៍ព្រៃឈើអូរដាសស្គ័ សហគមន៍ព្រៃឈើព្រៃអូរ-បុស្សលាវ សហគមន៍ព្រៃឈើព្រៃហុងចំតិត សហគមន៍ព្រៃឈើល្បោះស្រល់ និងស្ថាននីយស្រាវជ្រាវវត្តទឹក (ព្រៃអង់តែន)។

### ២.២. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យឧរង្គសត្វ និងថលជលិកសត្វ គឺយើងធ្វើការប្រមូលនៅពេលយប់ និងពេលថ្ងៃ(រូបភាពទី២)។



រូបភាពទី២ សកម្មភាពចុះសិក្សាស្រាវជ្រាវវត្តមានថលជលិកសត្វ និងឧរង្គសត្វ តាមផ្លូវ នៅពេលថ្ងៃ ក្នុងសហគមន៍គម្រោងរេដបូកទំរីង

ការសិក្សានេះយើងត្រូវដើរយឺតៗ និងធ្វើការសម្លឹងមើលខាងក្រោមស្លឹកឈើ ស្មៅ គម្របព្រៃឈើ គល់ឈើ ឈើឈរឈើដែលគេកាប់រំលំ និងធ្វើការដើរតាមផ្លូវ និងតាមអូរ។ នៅពេលថ្ងៃគឺយើងធ្វើការដើរនៅតាមផ្លូវដោយធ្វើការមើលទៅលើប្រភេទឧរង្គសត្វដោយមើលទៅលើខាងក្រោមស្លឹកឈើ ក្រុមឈើដែលបានគេកាប់រំលំ ក្នុងនោះយើងនឹងមានឱកាសឃើញសត្វពស់ កង្កែប តុកកែ ប្រភេទបង្កួយ...។ នៅពេលយប់យើងធ្វើការដើរតាមអូរ និងពេលខ្លះយើងធ្វើការដើរមើលតាមផ្លូវព្រៃដើម្បីរកប្រភេទផ្សេងៗទៀតដូចជាក្រុមថលជលិកសត្វជាដើម។ យើងបានធ្វើការដំឡើងអន្ទាក់សម្រាប់ទាក់ប្រភេទឧង្គសត្វ និងថលជលិកសត្វតូចៗ នៅក្នុងសហគមន៍ព្រៃឈើព្រៃអូរបុស្សលាវ (រូបភាពទី៣)។



រូបភាពទី៣ ការដាក់ឧបករណ៍សម្រាប់ទាក់សត្វជាមួយនឹងថង់ប្លាស់ស្ទិកតាមបណ្តោយអូរ នៅសហគមន៍ព្រៃឈើព្រៃអូរបុស្សលាវ

សត្វដែលយើងបានឃើញភាគច្រើនគឺយើងធ្វើការថតរូប និងចុចចំនុចនិយាមការទុក តែចំពោះប្រភេទសត្វខ្លះដែលយើងពិបាកថត គឺយើងធ្វើការចាប់វាដាក់ក្នុងថង់ដែលមានខ្យល់គ្រប់គ្រាន់កុំឲ្យវាមានគ្រោះថ្នាក់ ទុកថតរូបនៅពេលក្រោយ។ ការធ្វើការកំណត់អត្តសញ្ញាណសត្វតាមសៀវភៅឧរង្គសត្វនៅតំបន់អាស៊ីអាគ្នេយ៍ របស់លោក Robinson បោះពុម្ពឆ្នាំ២០១៧ និងសៀវភៅមគ្គុទេសថលជលិកសត្វនៅកម្ពុជា របស់លោក នាង ធី និងលោក Jeremy Holden បោះពុម្ពឆ្នាំ២០០៨ និងប្រភេទខ្លះទៀតគឺត្រូវបានកំណត់អត្តសញ្ញាណតាមប្រភពអនឡាញ។

## ២.៣. ការសម្ភាសសមាជិកសហគមន៍ព្រៃឈើ

នៅក្នុងការសិក្សានេះផងដែរយើងក៏បានធ្វើការសិក្សាស្រាវជ្រាវតាមរយៈការធ្វើកិច្ចសម្ភាសន៍ជាមួយប្រជាជន និងសមាជិកសហគមន៍ដែលបានចូលរួមសិក្សាស្រាវជ្រាវ ដើម្បីបានដឹងពីប្រភេទសំខាន់ៗលើប្រភេទ ថលជលិកសត្វ និងឧរង្គសត្វ ដែលមាននៅក្នុងតំបន់សិក្សា។ កិច្ចសម្ភាសន៍នេះបានផ្តល់ផលប្រយោជន៍ជាច្រើនទាំងកត្តាគំរាមកំហែងលើព្រៃឈើក៏ដូចជាធនធានដែលមាននៅក្នុងតំបន់នោះផងដែរ (រូបភាពទី៤)។



រូបភាពទី៤ ការសម្ភាសន៍ប្រជាជនមូលដ្ឋានអំពីព័ត៌មានសត្វព្រៃដែលមាននៅក្នុងសហគមន៍ និងព័ត៌មានលើការគំរាមកំហែងលើវត្តមានសត្វព្រៃ និងព្រៃឈើ

## ៣. លទ្ធផលនៃការសិក្សា

### ៣.១ វត្តមានឧរង្គសត្វ និងថលជលិកសត្វ

នៅក្នុងសហគមន៍តំបន់គម្រោងរេដបូកទំរីង ខេត្តកំពង់ធំ បានរកឃើញថាមានចំនួន ៣៦ប្រភេទ នៃប្រភេទឧរង្គសត្វ

និងថលជលិកសត្វក្នុងនោះមាន ១៦ប្រភេទជាថលជលិក-សត្វ និង២០ប្រភេទ ជាឧរង្គសត្វ(រូបភាពទី៥ និងទី៦)។




រូបភាពទី៥ ការកត់ត្រានូវចំនួនអំបូរនីមួយៗនៃប្រភេទថលជលិកសត្វ




រូបភាពទី៦ ការកត់ត្រានូវចំនួនអំបូរនីមួយៗនៃប្រភេទឧរង្គសត្វ

នៅក្នុងការរកឃើញចំនួនសត្វថលជលិកសត្វទាំងអស់ ឃើញមានចំនួនប្រភេទហ៊ឹងហ្វីស៊ីពីស (*Microhyla fissipes*) ច្រើនជាគេ និងតិចជាងគេគឺហ៊ឹងចំបក់ (*Calluella guttulata*) នៅក្នុងតំបន់សិក្សាគម្រោងរេដបូកទំរីង (រូបភាពទី៧)។




រូបភាពទី៧
ការកត់ត្រាចំនួនក្បាលរបស់ក្រុមប្រភេទថលជលិកសត្វ




រូបភាពទី៨ ការកត់ត្រាចំនួនក្បាលរបស់ប្រភេទឧរង្គសត្វ

ប្រភេទឧរង្គសត្វដែលមាននៅក្នុងតំបន់សហគមន៍គម្រោងរេដបូកទំរីងមានសរុបចំនួន ២០ប្រភេទ ត្រូវជា ១២៦ក្បាល។ នៅក្នុងធ្វើការស្រាវជ្រាវនេះគឺយើងឃើញថាមានប្រភេទថ្លែនឆ្នូតខ្នងធំ គឺមានចំនួនច្រើនជាងគេមានចំនួន៥៥ក្បាល (រូបភាពទី៨)។

## ៣.២ ការសម្ភាសន៍

យោងតាមការសម្ភាសន៍អ្នកនាំផ្លូវចុះសិក្សាស្រាវ ជ្រាវវត្តមានសត្វឧរង្គសត្វ និងថលជលិកសត្វនៅក្នុងតំបន់អនុវត្តគម្រោងរេដបូកទំរីង គិតត្រឹម៥ឆ្នាំចុងក្រោយដែលគាត់បានឃើញ និងបានដឹង ក្នុងនោះមានចំនួន ១៣ប្រភេទឧរង្គសត្វដែលទទួលបានពីការធ្វើកិច្ចសម្ភាសន៍ជាមួយប្រជាជន ក៏ដូចជាសមាជិកសហគមន៍នៅក្នុងតំបន់គម្រោង (តារាងទី១)។

| ល.រ | ឈ្មោះខ្មែរ | ឈ្មោះអង់គ្លេស | ប្រកាស កសក ០២០ |
|---|---|---|---|
| ១ | ត្រកួត | Bengal Monitor | បង្ករ |
| ២ | អន្សង | Water Monitor | បង្ករ |
| ៣ | ពស់វែករនាម | King Cobra | កម្រ |
| ៤ | ពស់វែកក្របី | Monocled Cobra | កម្រ |
| ៥ | ពស់វែកដំបូក | Indochinese Spitting Cobra | កម្រ |
| ៦ | ពស់ថ្លាន់តូច | Burmese Python | បង្ករ |
| ៧ | ពស់ថ្លាន់ធំ | Reticulated Python | បង្ករ |
| ៨ | អណ្ដើកព្រិច | Elongated Tortoise | បង្ករ |
| ៩ | កន្ធាយអាស៊ី | Asiatic Softshell Turtle | - |
| ១០ | អណ្ដើកសោម | Asian Giant Terrapin | - |
| ១១ | អណ្ដើកសកល | Yellow Headed Temple Turtle | - |
| ១២ | អណ្ដើកក្អែក | Black Mask Turtle | - |
| ១៣ | អណ្ដើកបិទមុខ | Southeast Asian Box Turtle | បង្ករ |

តារាងទី១ ប្រភេទឧរង្គងសត្វបានមកពីការសម្ភាសន៍ប្រជាជន




## ៤. កត្តាគម្រាមកំហែង

សកម្មភាពដែលប៉ះពាល់ដល់ការគម្រាមកំហែងដល់ប្រភេទឧរង្គសត្វ និងថលជលិកសត្វនៅក្នុងសហគមន៍គម្រោងរេដបូកទំរីង ខេត្តកំពង់ធំ។ ក្នុងនោះដែលមានផលប៉ះពាល់មកពីកត្តាធំៗចំនួន ៣ ដូចខាងក្រោម៖

-ការកាប់បំផ្លាញព្រៃឈើ ៖ បញ្ហានេះបានធ្វើឲ្យមានការបាត់បង់ប្រព័ន្ធអេកូឡូស៊ី និងធ្វើឲ្យបាត់បង់ទីជម្រកសម្រាប់បន្តពូជរបស់ប្រភេទឧរង្គសត្វ និងថលជលិកសត្វ។ ការបាត់បង់ព្រៃឈើនេះអាចធ្វើឲ្យមានការកាត់បន្ថយអត្រាបន្តពូជ ការបាត់បង់ភាពចម្រុះនៃសេនេទិច និងការប្រែប្រួលនៃការលូតលាស់ និងលំនាំសកម្មភាពរបស់ពួកគេ។

-ការបរបាញ់សត្វព្រៃ ៖ ប្រជាជនទាំងក្នុង និងក្រៅតំបន់សហគមន៍តែងចូលធ្វើការបរបាញ់សត្វព្រៃដោយប្រើអន្ទាក់(ឌូរ) ដើម្បីធ្វើការចាប់សត្វទាំងឧរង្គសត្វ ក៏ដូចជាថលជលិកសត្វ។ អន្ទាក់ (ឌូរ) បានធ្វើការតំឡើងនៅតាមអូរនៅក្នុងតំបន់សិក្សាស្រាវជ្រាវក្នុងសហគមន៍ព្រៃឈើ។

-ការរាំងស្ងួតអូរ ឬក្បាលហុង ៖ ការប្រែប្រួលអាកាសធាតុ មានឥទ្ធិពលដល់ការរាំងស្ងួតទឹកនៅតាមអូរត្រពាំង (Bickford et al., 2010) ។

## ៥. សន្និដ្ឋាន

នៅក្នុងការសិក្សាស្រាវជ្រាវប្រភេទថលជលិកសត្វ និងឧរង្គសត្វសរុបមានចំនួន ៤៩ប្រភេទ។ ក្នុងនោះមាន ៣៦ប្រភេទ (១៦ប្រភេទថលជលិកសត្វ និង២០ប្រភេទឧរង្គសត្វ) ត្រូវបានកត់ត្រាដោយការចុះស្រាវជ្រាវផ្ទាល់នៅទីតាំងស្រាវជ្រាវ។ ចំណែក១៣ប្រភេទឧរង្គសត្វ ទទួលបានពីការសម្ភាសន៍ប្រជាជន ក៏ដូចជាសមាជិកសហគមន៍ដែលរស់នៅក្នុងសហគមន៍តំបន់គម្រោងរេដបូកទំរីង។

## ៦. អនុសាសន៍

-ផ្តល់ការអប់រំផ្សព្វផ្សាយដល់ប្រជាជនក្នុងតំបន់/អ្នកភូមិ អំពីសារសំខាន់នៃការការពារ និងអភិរក្សប្រភេទថលជលិកសត្វ និងឧរង្គសត្វ និងប្រភេទសត្វព្រៃផ្សេងទៀត ដូចជាថនិកសត្វថ្នាក់ធំ និងបក្សី

-ពង្រឹងការអនុវត្តច្បាប់អោយបានខ្លាំង ដើម្បីបញ្ឈប់ការកាប់បំផ្លាញ និងការបរបាញ់សត្វព្រៃក្នុងរូបភាពផ្សេងៗ

-ស្តាព្រៃឈើឡើងវិញនៅតំបន់មួយចំនួនដែលបានបាត់បង់(ឧទាហរណ៍៖ ស្ថានីយស្ថាវជ្រាវវត្តទឹក(ព្រៃអង់តែន)) ដែលអាចផ្តល់ទីជម្រកដល់ប្រភេទថលជលិកសត្វ និងឧរង្គសត្វ ឲ្យវាប្រសើរជាងនេះនៅក្នុងតំបន់។

## ឯកសារយោង


Bickford, D., Howard, S.D., Ng, D.J.J., & Sheridan, J. A. (2010). Impacts of climate change on the amphibians and reptiles of Southeast Asia. *Biodivers Conserv (19) 1043–1062*. https://doi.org/10.1007/s10531-010-9782-4

Daltry, J. C., & Wüster, W. (2002). a New Species of Wolf Snake (Serpentes: Colubridae: Lycodon) From the Cardamom Mountains, Southwestern Cambodia. *Herpetologica*, *58*(4), 498–504. https://doi.org/10.1655/0018-0831(2002)058[0498:ansows]2.0.co;2

Establishment of Prey Lang Wildlife Sanctuary, Pub. L. No. 74, 1 (2016). https://www.facebook.com/314699302002531/photos/ms.c.eJwtx7ENADAMArCPqkICIv8~;1qHxZqe7BtZl1DjewyPe7Ml~;7q2UEeoBnFQM4g~-~-.bps.a.684438735028584.1073741989.314699302002531/684439165028541/?type=3&theater

Geissler, P., Hartmann, T., Koenig, A., Ihlow, F., & Wagner, P. (2019). Herpetofauna of the Phnom Kulen National Park , northern Cambodia-An annotated checklist Herpetofauna of the Phnom Kulen National Park , northern Cambodia — An annotated checklist. *Cambodian Journal of Natural History*, *2019*(2019), 40–63.

Grismer, L. L., Wood, P. L., Quah, E. S. H., Anuar, S., Poyarkov, N. A., Thy, N., Orlov, N. L., Thammachoti, P., & Seiha, H. (2019). Integrative taxonomy of the Asian skinks Sphenomorphus stellatus (Boulenger, 1900) and S. praesignis (Boulenger, 1900) with the resurrection of S. annamiticus (Boettger, 1901) and the description of a new species from Cambodia. *Zootaxa*, *4683*(3), 381–411. https://doi.org/10.11646/zootaxa.4683.3.4

Hayes, B., Khou, H., Thy, N., Furey, N., Sophea, C., Holden, J., Seiha, H., Sarith, P., Pengly, L., & Simpson, V. (2015). *May 2015 BIODIVERSITY ASSESSMENT OF PREY LANG Kratie, Kampong Thom, Stung Treng and Preah Vihear Provinces*.

IUCN. (2021). *The IUCN Red List of Threatened Species.* Version 2021-3. https://www.iucnredlist.org

Murdoch, M. L., Lee Grismer, L., Wood, P. L., Neang, T., Poyarkov, N. A., Tri, N. V. A. N., Nazarov, R. A., Aowphol, A., Pauwels, O. S. G., Nguyen, H. N., & Grismer, J. L. (2019). Six new species of the Cyrtodactylus intermedius complex (Squamata: Gekkonidae) from the Cardamom Mountains and associated highlands of Southeast Asia. *Zootaxa*, *4554*(1), 1–62. https://doi.org/10.11646/zootaxa.4554.1.1

Neang, T., Hartmann, T., Hun, S., Souter, N. J., & Furey, N. M. (2014). A new species of wolf snake (Colubridae: Lycodon Fitzinger, 1826) from Phnom Samkos Wildlife Sanctuary, Cardamom Mountains, southwest Cambodia. *Zootaxa*, *3814*(1), 68–80. https://doi.org/10.11646/zootaxa.3814.1.3

Neang, T., Henson, A., & Stuart, B. L. (2020). A new species of cyrtodactylus (Squamata, gekkonidae) from cambodia's prey lang wildlife sanctuary. *ZooKeys*, *2020*(926), 133–158. https://doi.org/10.3897/zookeys.926.48671

Neang, T., & Holden, J. (2008). *A field guide to the Amphibians of Cambodia*. Fauna & Flora International, Cambodia Programme.

Robinson, M. (2017). A Field Guide to the Reptiles of South-East Asia. In *Reference Reviews* (1st ed., Vol. 31, Issue 1). Bloomsbury Publishing Plc. https://doi.org/10.1108/rr-08-2016-0210

# ការវាយតម្លៃលើចំណេះដឹង ឥរិយាបថ និងការអនុវត្តស្តីពី ការការពារជំងឺឆ្លងពីសត្វមកមនុស្ស នៅស្រុកបាណន់ ខេត្តបាត់ដំបង

*ដោយ៖ ប៊ូរ វុឌ្ឍី មន្ត្រីនាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ*

សុខភាពសាធារណៈ គឺជាបញ្ហាដ៏ចម្បងដែលត្រូវដោះស្រាយហើយក្នុងនោះ ៧៥% ជាធាតុបង្កនៃជំងឺដែលឆ្លងពីសត្វទៅមនុស្ស។ ជំងឺឆ្លងពីសត្វមកមនុស្ស ជាជំងឺដែលចម្លងរវាងសត្វដែលមានផ្ទុកមេរោគ ដោយសារមានការប្រាស្រ័យទាក់ទងគ្នាទៅនឹងមនុស្ស ក៏ដូចជាទៅកាន់មជ្ឈដ្ឋានជុំវិញផងដែរ។ ជំងឺឆ្លងពីសត្វមកមនុស្សដែលហៅ (Zoonosis) គឺជាជំងឺដ៏កាចសាហាវ ដែលមានការវិវត្តទម្រង់របស់វា និងចម្លងពីសត្វទៅមនុស្ស ហើយប្រមាណជាង ៧០% នៃប្រភេទជំងឺទាំងនោះ គឺឆ្លងពីសត្វព្រៃ ដូចជាពពួកសត្វកកេរ(កណ្តុរ) ជាដើម។

ប្រទេសកម្ពុជាយើង គឺជាប្រទេសមួយដែលមានភូមិសាស្ត្រស្ថិតនៅក្នុងតំបន់ត្រូពិចក្តៅសើមសម្បូរធនធានធម្មជាតិ និងភោគផលគ្រប់ប្រភេទ។ ព្រៃឈើតំបន់ដីសើម និងវាលក្នុងប្រទេសកម្ពុជា ជាទីជម្រកដ៏មានសារសំខាន់សម្រាប់ធនធានសត្វ និងជីវចម្រុះរួមមាន សត្វស្លាប ថនិសត្វ ឧរង្គសត្វ ថលជលិកសត្វ បាណកសត្វ សប្បីសត្វ សត្វឥតឆ្អឹងកង និងរុក្ខជាតិគ្រប់ប្រភេទ។ ដោយសារសម្បត្តិធនធានធម្មជាតិទាំងអស់នេះហើយ ទើបធ្វើឱ្យប្រជាជនកម្ពុជា ជាទូទៅដែលតែងតែមានវប្បធម៌ ប្រពៃណីការបរិភោគសាច់សត្វព្រៃ ការបរបាញ់ ការចិញ្ចឹម ការយកធ្វើជាឱសថជាដើម ដែលកត្តាទាំងអស់នេះគឺជាសកម្មភាពឥរិយាបថ ការអនុវត្ត ប៉ះពាល់ជាមួយសត្វព្រៃ ដែលថ្ងៃខាងមុខ ជាហានិភ័យត្រូវប្រឈមនឹងជំងឺឆ្លងពីសត្វព្រៃមកមនុស្ស។

បច្ចុប្បន្ននេះសត្វព្រៃ និងជីវចម្រុះកំពុងទទួលការគំរាមកំហែងដោយសារ ការបាត់បង់ទីជម្រក ការបរបាញ់ហួសកម្រិត ការបំពុល ការរាតត្បាតនៃជំងឺឆ្លង និងកត្តាផ្សេងទៀត។ ប្រទេសកម្ពុជា ក៏ជាប្រទេសកំពុងអភិវឌ្ឍន៍ដែរ ដូច្នេះការយល់ដឹងរបស់ប្រជាជន រួមនឹងការសិក្សាស្រាវជ្រាវអំពីជំងឺផ្សេងៗ នៅមានកម្រិតនៅឡើយ។ ជាក់ស្តែងការចរាចរណ៍សត្វកកេរ ជាពិសេសសត្វកណ្តុរនៅក្នុងស្រុក និងនាំចេញទៅប្រទេសវៀតណាម ពីបណ្តាខេត្តផ្សេងៗក្នុងប្រទេសកម្ពុជា កំពុងតែពេញនិយមដែលជាហេតុធ្វើឱ្យមានការប្រឈមមុខទៅនឹងការចម្លង CoVs យ៉ាងខ្លាំងដល់ប្រជាពលរដ្ឋ ជាពិសេសចំពោះអ្នកប្រមាញ់ ឈ្មួញកណ្តាល និងអ្នកបរិភោគ។

## វិធីសាស្ត្រសិក្សាស្រាវជ្រាវ

### ក.ការជ្រើសរើសទីតាំង

ការសិក្សានេះ បានធ្វើឡើងនៅក្នុង ស្រុកបាណន់ ខេត្តបាត់ដំបង ដែលមានទាំងអស់ចំនួន៥ឃុំ ដែលមានល្អាង ព្រៃ និងភ្នំ ដែលជាទីជម្រកសត្វព្រៃ គ្រប់ប្រភេទរស់នៅដូចជាថនិកសត្វតូចៗ សត្វស្លាប ថលជលិក សត្វល្អិត និងឧរង្គសត្វ។ ឃុំទាំងប្រាំនោះគឺ ឃុំបាយដំរាំ ឃុំតាគ្រាម ឃុំភ្នំសំពៅ ឃុំឈើទាល និងឃុំស្នឹង។



ផែនទី៖ ទីតាំងសិក្សាស្រាវជ្រាវ នៅក្នុងស្រុកបាណន់

### ខ. ចំនួនសំណាក និងការវិភាគទិន្នន័យ

ចំនួនសំណាកសរុប៩៩គ្រួសារ ត្រូវបានជ្រើសរើសតាមរយៈការប្រើប្រាស់រូបមន្ត Yamane (1967) ដើម្បីធ្វើការសម្ភាសដោយផ្អែកលើបញ្ជីសំណួរ (KAP) ដែលត្រូវបានសម្ភាសន៍លើចំណុចគោលសំខាន់ៗចំនួនបីគឺ ការអនុវត្ត ចំណេះដឹង និងឥរិយាបថ។

ការវិភាគព័ត៌មានស្តីពីចំណេះដឹង ឥរិយាបថ និងការអនុវត្ត (Knowledge, Attitude, Practice) ត្រូវបានប្រើកម្មវិធី SPSS ដោយប្រើប្រាស់ទៅលើមុខងារវិភាគទិន្នន័យពីរគឺ Binomal Test សម្រាប់ប្រៀបធៀបចំណែក Chi-Square និង Pearson Correlation សម្រាប់សិក្សាទំនាក់ទំនងរវាងកត្តាមួយ ជាមួយនឹងកត្តាមួយផ្សេងទៀត។ មួយវិញទៀតក៏បានប្រើប្រាស់នូវកម្មវិធី SPSS ផងដែរលើឧបករណ៍ពីរគឺ Descriptive statistic (Frequencies និង Cross tables) និង Multiple Response(Frequencies និង Cross tables)។ ការប្រើប្រាស់កម្មវិធី R-Program (ggplot និង Pie-Chart) ។

## លទ្ធផល

### ក. ការអនុវត្ត

ការប៉ះពាល់ជាមួយសត្វព្រៃ ជានិច្ចកាលតែងតែមានតាមបណ្តាស្រុក ភូមិ ឃុំ តាមតំបន់ជនបទជាប់ព្រៃភ្នំជាដើម ដែលការប៉ះពាល់ជាមួយសត្វព្រៃទាំងអស់នោះតាមទម្រង់ផ្សេងៗគ្នា ចំណែកឃុំទាំងប្រាំដែលបានចុះធ្វើការសិក្សាវិញ គឺមាន៩៧នាក់ ដែលបានប៉ះពាល់ជាមួយសត្វព្រៃ ស្មើនឹង ៩៨,០% ដែលឃុំបាយដំរាំ ឃុំឈើទាល និងឃុំតាគ្រាម មានចំនួនអ្នកប៉ះពាល់ទាំងអស់នៃសំណាកសរុប។

ជាលទ្ធផលបានពីការសិក្សាគឺ លើការអនុវត្តមាន ៩៨,០% នៃសំណាកទាំងអស់បានប៉ះពាល់ជាមួយនឹងសត្វព្រៃ ឬសត្វក្រៅស្រុកដូចជា ការប្រើប្រាស់សត្វព្រៃជាអាហារគឺមានភាគរយ ច្រើនជាងគេនៅក្នុងឃុំទាំងប្រាំមាន ៧៩,៥% ការលក់ដូរមានអត្រា ៦,៦% ការចិញ្ចឹមសត្វព្រៃមាន ០,៨% និងការងារពាក់ព័ន្ធជាមួយសត្វព្រៃ គឺមាន ១៣,១%។




ក្រាហ្វិកបង្ហាញពីការអនុវត្តលើការប៉ះពាល់សត្វព្រៃ

### ខ.ឥរិយាបថ

ឥរិយាបថដែលទទួលគាំទ្រលើការអនុវត្ត នោះគឺមានតែ ១០,០% ប៉ុណ្ណោះ រីឯឥរិយាបថមិនគាំទ្រនៅរាល់ការអនុវត្តមានរហូត ៦៥,៤%។ ឥរិយាបថ ១០,០% នៅក្នុងឃុំទាំងប្រាំបានឆ្លើយយល់ស្របលើសកម្មភាពទាំងអស់នៃការប៉ះពាល់សត្វព្រៃគ្រប់សកម្មភាពនៃឥរិយាបថរបស់ពួកគាត់។ ឃុំឈើទាល គឺមានភាគរយច្រើនជាងគេ ៣,៩% បើធៀបនឹងឃុំដ៏ទៃ ដែលមានការយល់ស្របទាំងស្រុងលើសកម្មភាពប៉ះពាល់សត្វព្រៃទាំងអស់។ ឃុំភ្នំសំពៅ មាន ២,២% និងឃុំតាគ្រាមមាន ១,៩%។

ទោះបីជាយ៉ាងណាក៏ដោយប្រជាជននៅតែនិយមការប្រើប្រាស់សត្វព្រៃជាអាហារ និងការលក់ដូរសត្វព្រៃ បើទោះបីជាការឆ្លើយរបស់ពួកគាត់មិនសមស្របក៏ដោយ ប៉ុន្តែសកម្មភាពនៃការអនុវត្តរបស់គាត់ គឺបានបង្ហាញយ៉ាងច្បាស់ពីការប៉ះពាល់របស់ពួកគាត់។

### គ.ចំណេះដឹង

ចំណេះដឹង គឺជាងពាក់កណ្តាលនៃអ្នកទាំងនោះមាន ៥២,៥% គឺមានការយល់ដឹងពីជំងឺ និងគ្រោះថ្នាក់នៃជំងឺឆ្លងពីសត្វមកមនុស្ស។ ទោះបីជាយ៉ាងណាភាគច្រើននៃអ្នកឆ្លើយដែលមានការយល់ដឹងតិចតួចអំពីជំងឺឆ្លងពីសត្វមកមនុស្សមាន ៤៧,៥% នៃចំនួនសម្ភាសន៍សរុប ក៏ដូចជាពុំសូវចេះអំពីរបៀបនៃការការពារខ្លួន និងគ្រួសារពីការចម្លងនៃជំងឺឆ្លងពីសត្វព្រៃឡើយ។

ការយល់ដឹងរបស់ប្រជាជននៅតាមឃុំនីមួយៗ គឺឃុំដែលមានការយល់ដឹងច្រើនជាងគេ គឺឃុំស្ទឹង មានភាគរយ ២១,៧% ដោយសារតែប្រជាជនមានការប្រើប្រាស់ និងការប៉ះពាល់ទៅលើថនិកសត្វ បក្សី និងល្មូន តិចជាងឃុំផ្សេងៗទៀត។

ការសិក្សាគឺ ប្រជាជនមានការយល់ដឹងអំពីជំងឺឆ្លងពីសត្វព្រៃច្រើនជាងគេគឺ ជំងឺផ្តាសាយបក្សី មាន ៥៨,៦% ដោយសារកន្លងមកមានការចុះអប់រំផ្សព្វផ្សាយអំពីជំងឺនេះច្រើននៅក្នុងសហគមន៍របស់ពួកគាត់រស់នៅ។

ចំណែកជំងឺឆ្កែឆ្កួតមាន ៥,១% ដោយប្រជាជនមានការដឹងខ្លះពីជំងឺនេះ គឺជាប្រជាជនដែលបានចូលរួមបណ្តុះបណ្តាលពីការងារអភិរក្សសត្វប្រចៀវនៅក្នុងឃុំឈើទាល និងមានមួយចំនួនទៀតគឺ នៅឃុំភ្នំសំពៅ ក៏ធ្លាប់បានដឹងពីជំងឺនេះផងដែរ។

**តារាងការយល់ដឹងពីជំងឺឆ្លងផ្សេងៗរបស់ប្រជាជន**

| ជំងឺផ្សេងៗ | ភាគរយ (%) | ចំនួនចម្លើយ |
|---|---|---|
| គ្រុនឈាម | ៤,០ | ៤ |
| រាគរូស | ១,០ | ១ |
| គ្រុនក្តៅ | ៤,០ | ៤ |
| ផ្តាសាយបក្សី | ៥៨,៦ | ៥៨ |
| គ្រុនចាញ់ | ១,០ | ១ |
| ជំងឺឆ្កែឆ្កួត | ៥,១ | ៥ |
| ជំងឺតេតាណុស | ៣,០ | ៣ |
| មិនដឹង | ២៣,៣ | ២៣ |
| សរុប | ១០០,០ | ៩៩ |

## ពិភាក្សា

### ក.កត្តាភូមិសាស្ត្រដែលជះឥទ្ធិពលលើការប៉ះពាល់ជាមួយសត្វព្រៃ

-ឃុំបាយដំរាំ គឺជាជម្រកសត្វជ្រឹងនៅតាមបណ្តោយដងស្ទឹងសង្កែ នៅកណ្តាលភូមិជាប់ផ្សារ



ហ្វូងសត្វជ្រឹងនៅឃុំបាយដំរាំ

-ភ្នំសំពៅ ល្អាងភ្នំសំពៅមានភូមិនៅជាប់នឹងជើងភ្នំនិងមានល្អាងប្រចៀវចំនួនពីរមានចម្ងាយពីគ្នា ៣០០-៣៥០ម ហើយពីច្រកល្អាងទៅភូមិមានចម្ងាយពី ៣០០-៤០០ម

-ឃុំតាគ្រាម ឆ្ងាយពីល្អាងប្រចៀវប្រហែល ៥០០ម និង កន្លែងដាក់អន្ទាក់សត្វកណ្តុរ ១០០ម ខាងក្រោយភូមិ



ល្អាងភ្នំតាគ្រាម

-ឃុំឈើទាល ល្អាងភ្នំព្រះរាជទ្រព្យ ភូមិនៅជាប់ជើងភ្នំចម្ងាយពីល្អាងប្រហែល ៥០០ម



ល្អាងភ្នំព្រះរាជទ្រព្យ ដែលជាទីជម្រកសត្វប្រចៀវ



ហ្វូងសត្វប្រចៀវនៅល្អាងភ្នំព្រះរាជទ្រព្យ

-ឃុំស្ទឹង តំបន់លក់កណ្តុរ ប្រភពចំណី ភូមិនៅជាប់វាលស្រែ និងមានការលក់កណ្តុរអាំងនៅកណ្តាលភូមិ។

### ខ.ហានិភ័យនៃការប៉ះពាល់សត្វព្រៃ

ប្រជាជនបានប៉ះពាល់ទាំងស្រុងជាមួយនឹងសត្វព្រៃក្នុងទម្រង់ការប្រើប្រាស់ជាអាហារ ការជួញដូរ ការចិញ្ចឹម និងការធ្វើការងារពាក់ព័ន្ធនឹងសត្វព្រៃ។

| ការប៉ះពាល់ | ការអនុវត្ត | ឥរិយាបថគាំទ្រ | ការយល់ដឹងទាប |
|---|---|---|---|
| អាហារ | ៧៩,៥ | ៤៩,៣ | ១៥,៨ |
| ចិញ្ចឹមនៅផ្ទះ | ០,៨ | ១៩,៨ | ១៤,៦ |
| ការជួញដូរ | ៦,៦ | ២៩,៥ | ៣៤,៧ |
| ធ្វើការពាក់ព័ន្ធ | ១៣,១ | ៨,៣ | ៣៤,៨ |

ការវិភាគកម្រិតហានិភ័យនៃការប៉ះពាល់សត្វព្រៃ គឺផ្អែកទៅលើលក្ខណៈវិនិច្ឆ័យសំខាន់ៗមួយចំនួន គឺទៅលើចំនួនអ្នកប៉ះពាល់ធៀបនឹងចំនួនសំណាកសរុប ប្រភេទសត្វព្រៃភាគច្រើនប៉ះពាល់កត្តាភូមិសាស្ត្រ ការអនុវត្ត ការការពារដោយផ្អែកសំខាន់ទៅលើឥរិយាបថគាំទ្រ ការប្រើប្រាស់សត្វព្រៃ ចំណេះដឹងទាប និងការអនុវត្តលើការប៉ះពាល់សត្វព្រៃនៅតាមឃុំនីមួយៗ។

| ឃុំ | លក្ខណៈវិនិច្ឆ័យទំនាក់ទំនងកម្រិតហានិភ័យតាមឃុំនីមួយៗ (ភាគរយ) | | | | |
|---|---|---|---|---|---|
| | អ្នកប៉ះពាល់ | សត្វប៉ះពាល់ | ការអនុវត្ត | ឥរិយាបទគាំទ្រ | ចំណេះដឹងទាប |
| បាយដំរាំ | ១០,០ | ៤៥,៥ | ៩,០ | ៦,៦៦ | ២២,២២ |
| ភ្នំសំពៅ | ២០,២ | ៣៨,៨ | ១៧,២ | ៨,៣៣ | ២២,៧៧ |
| តាក្រាម | ២៥,៣ | ៥៨,១ | ២៧,៩ | ១០,៦៦ | ៣០,៦៦ |
| ឈើទាល | ២២,២ | ៣៦,២ | ២៨,៧ | ២១,២១ | ១១,៦៦ |
| ស្នឹង | ២២,២ | ៤២,៦ | ១៧,២ | ១២,១២ | ២,៥២ |

នៅឃុំ ចំនួនប្រាំ គឺឃុំតាក្រាម និងឃុំឈើទាល មានសង្គត់ភាពនៃកត្តាទាំងបីគឺការអនុវត្តឥរិយាបថ និងចំណេះដឹងទាប មានកម្រិតទំនាក់ទំនងប្រហាក់ប្រហែលគ្នាដែលអាចនឹងឈានទៅរកគ្រោះថ្នាក់ខ្ពស់បំផុតនៅពេលខាងមុខប្រសិនបើប្រជាជននៅតែបន្តសកម្មភាពរបស់ពួកគាត់ដោយមិនមានវិធានការការពារខ្លួននោះទេ។ ចំណែកឃុំដទៃទៀតមានកម្រិតហានិភ័យទាបជាងឃុំឈើទាល និងឃុំតាក្រាម ប៉ុន្តែឃុំទាំងបី គឺមានកម្រិតប្រហាក់ប្រហែលគ្នារវាងទំនាក់ទំនងនៃកត្តាទាំងបីក៏ដូចជាការប៉ះពាល់តាមរយៈកត្តាភូមិសាស្ត្រ ចំនួនប្រជាជនប៉ះពាល់ធៀបចំនួនសំណាកការប៉ះពាល់លើក្រុមសត្វព្រៃ និងការអនុវត្តការការពារជាដើម។

ដូច្នេះតាមការសិក្សាបានបង្ហាញថាឃុំទាំងប្រាំ អាចប្រឈមនឹងហានិភ័យសម្រាប់ប្រជាជនដែលបានប៉ះពាល់ និងប្រើប្រាស់លើសត្វព្រៃទាំងអស់នេះប្រសិនបើមានការផ្ទុះឬចម្លងជំងឺបានកើតឡើងពីសត្វប្រចៀវ ក៏ដូចជាសត្វកណ្ដុរ ឬសត្វព្រៃដទៃទៀតជាដើមនៅថ្ងៃខាងមុខ បើសិនមិនមានវិធានការអនុវត្តការការពារឱ្យបានត្រឹមត្រូវនោះទេ។ លទ្ធផលវិភាគការអនុវត្ត ឥរិយាបថ និងចំណេះដឹង ស្នើឱ្យមានវិធានការការពារជាច្រើនដើម្បីរួមបញ្ចូលទៅក្នុងកម្មវិធីពង្រីកការយល់ដឹងសម្រាប់កាត់បន្ថយការចម្លងជំងឺពីសត្វព្រៃទៅមនុស្ស។



ការប៉ះពាល់ដោយផ្ទាល់ជាមួយសត្វព្រៃរបស់ប្រជាជន

### គ.ការអនុវត្តការផ្សព្វផ្សាយរបស់អាជ្ញាធរមូលដ្ឋាន

កន្លងមកនៅក្នុងស្រុកបាណន់ទាំងមូល ក៏ដូចជាក្នុងខេត្តបាត់ដំបងមានការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងកិច្ចការពារអនាម័យក្នុងការរស់នៅឱ្យបានស្អាត។ ក្រៅពីនេះមានការណែនាំពីវិធានការការពារពីជំងឺផ្ដាសាយបក្សី ការអប់រំអំពីការពាក់ម៉ាស់ និងស្រោមដៃពេលប៉ះពាល់សត្វដែលឈឺងាប់។ ការផ្សព្វផ្សាយពីការការពារចំពោះជំងឺឆ្កែឆ្កួត ការអប់រំអំពីការអភិរក្សសត្វប្រចៀវ ជ្រើង សត្វស្លាបផ្សេងៗ ដោយហាមមិនឱ្យមានការបរបាញ់ បរិភោគ និងលក់ដូរជាដើម។

ក្រសួងសុខាភិបាល រួមជាមួយអង្គការ FAO បានចេញសៀវភៅណែនាំសម្រាប់ភ្នាក់ងារសុខភាពសត្វក្នុងភូមិ និងមេភូមិផងដែរ នៅទូទាំងប្រទេស ស្ដីពីការបង្ការ និងការទប់ស្កាត់ជំងឺផ្ដាសាយបក្សីក្នុងការចិញ្ចឹមសត្វបក្សីជាលក្ខណៈគ្រួសារ។

## សន្និដ្ឋាន

តាមការសិក្សា ឃុំតាគ្រាម និងឃុំឈើទាល គឺមានទំនាក់ទំនងរវាងកត្តាទាំងបីសមស្រប បើមើលពីកម្រិតហានិភ័យវិញគឺច្រើនជាងគេ ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យសំខាន់ៗមួយចំនួនគឺការវិនិច្ឆ័យលើចំនួនអ្នកប៉ះពាល់ធៀបចំនួនសំណាកសរុប ប្រភេទសត្វព្រៃភាគច្រើនប៉ះពាល់កត្តាភូមិសាស្ត្រ ការអនុវត្តកាការពារដោយផ្អែកសំខាន់ទៅលើឥរិយាបថនៃការគាំទ្រ ការប្រើប្រាស់សត្វព្រៃ ចំណេះដឹង ទាប និងការអនុវត្តលើការប៉ះពាល់សត្វព្រៃ នៅក្នុងឃុំនេះមានភាគរយប៉ះពាល់ ក៏ដូចជាការប្រើប្រាស់ច្រើនជាងគេ។ ចំណែកឃុំដទៃទៀតគឺមានកម្រិតប្រហាក់ប្រហែលគ្នារវាងទំនាក់ទំនងនៃកត្តាទាំងបី។

ដូច្នេះតាមការសិក្សាបានបង្ហាញថា ឃុំទាំងប្រាំអាចប្រឈមនឹងហានិភ័យសម្រាប់ប្រជាជនដែលបានប៉ះពាល់ និងប្រើប្រាស់លើសត្វព្រៃទាំងអស់នេះ ប្រសិនបើមានការផ្ទុះ ឬចម្លងជំងឺបានកើតឡើងពីសត្វប្រចៀវ ក៏ដូចជាសត្វកណ្ដុរ ឬសត្វព្រៃដទៃទៀតជាដើម នៅថ្ងៃខាងមុខបើសិនមិនមានវិធានការអនុវត្តការការពារឲ្យបានត្រឹមត្រូវនោះទេ។

## អនុសាសន៍

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងលទ្ធផលវិភាគ យើងអាចផ្ដល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោម៖

-បញ្ឈប់រាល់ការប៉ះពាល់ ជាមួយសត្វឈឺ ទាំងសត្វស្រុក និងសត្វព្រៃ ការប៉ះពាល់ ឬបរិភោគសាច់សត្វព្រៃ ការបរិភោគសាច់ឆៅ ឬសាច់ស្រស់របស់សត្វព្រៃ ការចាប់យកសត្វព្រៃពីក្នុងព្រៃធម្មជាតិ និងការទាក់ទងទៅនឹងការជួញដូរសត្វព្រៃ

-គួរមានវិធានការការពារដោយធ្វើការពាក់សម្ភារ ឬសំលៀកបំពាក់ការពារនៅពេលប៉ះពាល់សត្វព្រៃ

-ជម្រាបជូនអជ្ញាធរមូលដ្ឋាន ពេទ្យសត្វ មន្ត្រីមណ្ឌលសុខភាពអំពីករណីការផ្ទុះជំងឺឆ្លងពីសត្វមកមនុស្ស

-ផ្សព្វផ្សាយពីការការពារជំងឺឆ្លងពីសត្វមកមនុស្សតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម (វិទ្យុ ទូរទស្សន៍ហ្វេសប៊ុក យូធូប...) ការផ្សាយតាមផ្ទាំងបដាមានរូបភាព និងអក្សរផ្ទាំងរូបភាព ឬខិត្តប័ណ្ណផ្សេងៗ

-ធ្វើការសម្អាតលំនៅឋាន និងសម្ភារកំពុងប្រើប្រាស់ប៉ះពាល់ជាមួយនឹងសត្វព្រៃ ពីព្រោះមេរោគផ្សេងៗអាចនឹងបង្កការចម្លងតាមលក្ខខណ្ឌផ្សេងៗបាន

-សូមឱ្យមានការសិក្សាស្រាវជ្រាវ ឬពិសោធន៍បន្ថែមទៀត ជាពិសេសគឺការយកសំណាកពិសោធន៍ពីមេរោគនានាដែលមាននៅក្នុងសត្វព្រៃទាំងអស់នោះ ពីព្រោះវីរុសនានានឹងវិវត្តហ្សែនទៅជាកាចសាហាវ ឬអាចជាជំងឺឆ្លងពីសត្វមកមនុស្ស (Zoonosis)។

## ឯកសារយោង


- រដ្ឋបាលព្រៃឈើ ទស្សនាវដ្ដីព្រៃឈើ ប្រចាំឆ្នាំ លេខ៥៩ ឆ្នាំ២០១៨
- Anderson LJ and Tong S. Update on SARS research and otherpossibly zoonotic coronaviruses. Int J Antimicrob Agents (2010) 36 Suppl 1:S21-5.
- Bermingham, A., Chand, M.A., Brown, C.S., Aarons, E., Tong, C., Langrish, C., Hoschler, K., Brown, K., Galiano, M., Myers, R. and Pebody, R.G., (2012). Severe respiratory illness caused by a novel coronavirus, in a patient transferred to the United Kingdom from the Middle East, September 2012.Euro Surveill, 17(40).
- Carvalho, C. L., Lopes de Carvalho, I., Zé-Zé, L., Núncio, M. S., & Duarte, E. L. (2014). Tularaemia: A challenging zoonosis. *Comparative Immunology, Microbiology and Infectious Diseases*, *37*(2), 85–96. https://doi.org/10.1016/j.cimid.2014.01.002
- Hayman, D. T. S., Bowen, R. A., Cryan, P. M., Mccracken, G. F., O'Shea, T. J., Peel, A. J., Gilbert, A., Webb, C. T., & Wood, J. L. N. (2013). Ecology of Zoonotic Infectious Diseases in Bats: Current Knowledge and Future Directions. *Zoonoses and Public Health*, *60*(1), 2–21. https://doi.org/10.1111/zph.12000
- Jones, K. E., Patel, N. G., Levy, M. A., Storeygard, A., Balk, D., Gittleman, J. L. and Daszak, P. (2008). Global trends in emerging infectious diseases. Nature 451, 990-993.
- Kruse, H., Kirkemo, A. M., & Handeland, K. (2004). Wildlife as source of zoonotic infections. *Emerging Infectious Diseases*, *10*(12), 2067–2072. https://doi.org/10.3201/eid1012.040707
- Macpherson, C. N. L. (2005). Human behaviour and the epidemiology of parasitic zoonoses. *International Journal for Parasitology*, *35*(11–12), 1319–1331. https://doi.org/10.1016/j.ijpara.2005.06.004
- MAFF (2010) National Forest Programme 2019-2029. 146.
- MAFF, F., & Institutre. (2009). *H5N1.pdf*.
- Toeum, N. (2016). Detection and molecular characteriza of coronavirus in rodents in cambodia (p. 71).
- Travis, D. a, Watson, R. P., & Tauer, a. (2011). Examining the source□: scope and scale of the. *Rev. Sci. Tech.*, *30*(1), 219–239.
- Zu, Z. Y., Jiang, M. Di, Xu, P. P., Chen, W., Ni, Q. Q., Lu, G. M., & Zhang, L. J. (2020). Coronavirus Disease 2019 (COVID-19): A Perspective from China. *Radiology*, *2019*, 200490. https://doi.org/10.1148/radiol.2020200490

# ស្វែងយល់ពី ការសាងសង់ផ្ទះសត្វត្រចៀកកាំ



ដោយលោក៖ ញ៉ាន ប៊ុនថន ការិ.សង្គ្រោះ វិបុលកម្ម និងកីឡាប្រមាញ់

សំបុកទឹកមាត់ត្រចៀកកាំមានអត្ថប្រយោជន៍ខ្លាំងសម្រាប់ជួយដល់សុខភាពមនុស្ស គឺដោយសារតែនៅក្នុងសំបុកទឹកមាត់ត្រចៀកកាំសម្បូរទៅដោយជាតិរ៉ែ និងប្រូតេអ៊ីនខ្ពស់ក្នុងការជួយទ្រទ្រង់សារពាង្គកាយ។ ហេតុនេះហើយទើបតម្រូវការសំបុកទឹកមាត់ត្រចៀកកាំក្នុងពិភពលោកកាន់តែកើនឡើង ហើយតម្លៃថ្លៃថែមទៀតផង។ ប្រទេសមួយចំនួននៅតំបន់អាស៊ីអាគ្នេយ៍ រកចំណូលពីការចិញ្ចឹមសត្វត្រចៀកកាំបានរាប់សិបលានដុល្លារក្នុងមួយឆ្នាំៗ ហើយបច្ចុប្បន្នមានវិនិយោគិនបរទេសមួយចំនួនបានវិនិយោគទុនទៅលើការចិញ្ចឹមសត្វត្រចៀកកាំក្នុងប្រទេសកម្ពុជា ដោយសារពួកគេមើលឃើញថា ប្រទេសយើងជាប្រទេសមួយដែលមានសក្តានុពលខ្ពស់នៅក្នុងការចិញ្ចឹមសត្វនេះ ពីព្រោះប្រទេសកម្ពុជាសម្បូរទៅដោយបឹងបួរ ជ្រោះ ជ្រលងដងអូរ ព្រៃភ្នំ សមុទ្រ ជាដើមដែលជាប្រភពផ្តល់ចំណី និងជាជម្រកសម្រាប់សត្វត្រចៀកកាំ។

អត្ថបទដែលលើកយកមកបង្ហាញនាពេលនេះ គឺជាជំនួយស្មារតីមួយដល់អ្នកវិនិយោគក្នុងការធ្វើផ្ទះត្រចៀកកាំដើម្បីទទួលបានជោគជ័យ។

## ១-ការជ្រើសរើសទីតាំង

ការជ្រើសរើសទីតាំងមានសារសំខាន់ណាស់ គឺត្រូវយល់ឱ្យច្បាស់ពីតំបន់ដែលមានសុវត្ថិភាពល្អសម្រាប់សត្វត្រចៀកកាំ និងជាកន្លែងដែលមានប្រភពចំណីយូរអង្វែង។ តំបន់ទាំងឡាយណាមានអង្កត់ផ្ចិត១៥ ទៅ ២០គីឡូម៉ែត្រជុំវិញ ដែលមានលក្ខខណ្ឌ៣យ៉ាង ដូចខាងក្រោម៖

**តំបន់ទី១-** គឺតំបន់ដែលមានរុក្ខជាតិកម្ពស់ទាបជាង១ម៉ែត្រកន្លះ ដែលមានគ្រប់រដូវកាលពេញមួយឆ្នាំ ដូចជា ដំណាំ ស្រូវ ពោត សណ្តែក ជាដើម ដែលវាមានតួនាទីសំខាន់សម្រាប់ឱ្យសត្វត្រចៀកកាំហោះរកចំណីបាន ចាប់ពីពេលវាចេញពីផ្ទះរបស់វា ពីម៉ោង៥កន្លះព្រឹក រហូតដល់ម៉ោង១០កន្លះព្រឹក មុនពេលវាចាកចេញទៅតំបន់ទី២។

**តំបន់ទី២-** ជាតំបន់ដែលមានរុក្ខជាតិខ្ពស់ៗ ឬព្រៃដែលមានកម្ពស់ខ្ពស់ជាង ១ម៉ែត្រកន្លះ ដូចជា ចម្ការស្វាយ កៅស៊ូ ឬព្រៃឈើជាដើម ដែលជាតំបន់សត្វត្រចៀកកាំទៅអាស្រ័យនៅវេលាម៉ោង១០កន្លះព្រឹក រហូតដល់ម៉ោង ៣ ឬ៤រសៀល ព្រោះជាពេលវេលាដែលមានកម្តៅថ្ងៃខ្លាំងជាហេតុបណ្តាលឱ្យសត្វត្រចៀកកាំទាមទាររកទីតាំងដែលមានព្រៃក្រាស់សម្រាប់ជ្រកផ្តល់ភាពត្រជាក់ដល់ពួកវា។

**តំបន់ទី៣-** ជាតំបន់ដែលមានមុខទឹក ដូចជា ស្ទឹង បឹង ទន្លេ ព្រែក អូរ សមុទ្រ ជាដើម ក្នុងគោលបំណងវាហោះហើរទៅឆាបលេងមុនពេលវាត្រឡប់ទៅផ្ទះវិញ ដែលវានៅតំបន់នេះចាប់ពីម៉ោង ៣ ឬ៤រសៀលរហូតដល់ម៉ោង ៦ល្ងាច មុនពេលដែលវាហោះចូលផ្ទះវាវិញ។

កត្តាមួយទៀត គឺជាតំបន់ទាំងនោះត្រូវចៀសវាងពីប្រភពបំពុលដោយជាតិពុល ឬផ្សែងពុលនានា ដូចជា រោងចក្រដែលមានផ្សែងច្រើន កន្លែងដុតសំរាម ទឹកកខ្វក់ ជាដើម។

## ២- ការរចនាសាងសង់ផ្ទះសត្វត្រចៀកកាំ

មូលដ្ឋានក្នុងការរចនាសាងសង់អាគារសម្រាប់ធ្វើផ្ទះឱ្យវានៅ ត្រូវមានលក្ខខណ្ឌ និងការរចនាដូចខាងក្រោម៖

**ទី១**-សំណង់យ៉ាងហោចណាស់ត្រូវតែធ្វើកម្ពស់ ពី៦ ទៅ៧ម៉ែត្រផុតពីដីធៀបនឹងនីវ៉ូច្រកចូល។ តែទោះយ៉ាងណាក៏ដោយកម្ពស់វាអាស្រ័យសំខាន់ទៅនឹងបរិស្ថានជុំវិញនោះតាមការជាក់ស្តែង។

**ទី២**-ទំហំផ្ទះដែលល្អយ៉ាងហោចណាស់ ទទឹង៨ម៉ែត្របណ្តោយ២០ម៉ែត្រ ហើយកាន់តែធំកាន់ កាន់តែល្អសម្រាប់សត្វត្រចៀកកាំរស់នៅ។ តែបើសិនជាតូច បានត្រឹម៤ម៉ែត្រគុណ ១៦ម៉ែត្រ ក៏បាន គ្រាន់តែវាមិនជាលក្ខខណ្ឌដែលល្អគ្រប់គ្រាន់នោះទេ។

**ទី៣**-នៅក្នុងផ្ទះកម្ពស់ពីពិដានឈើមកដីយ៉ាងហោចណាស់ក៏ត្រូវមានកម្ពស់ ៣ម៉ែត្រ ដែរ។

**ទី៤**-សីតុណ្ហភាពខាងក្នុងផ្ទះត្រូវស្ថិតនៅចន្លោះពី ២៨ ដល់ ៣០អង្សាសេ ត្រូវកុំឲ្យមានពន្លឺចាំងចូលក្នុងផ្ទះ និងធ្វើយ៉ាងណាកុំឲ្យហាប់ខ្យល់ក្នុងផ្ទះ។

**ទី៥**-ត្រូវការពារខ្ពស់ពីសត្វឈ្លានពាន ដូចជា កណ្ដុរ កន្លាត តុកែ ពស់ជាដើម និងត្រូវការពារកុំឲ្យមានការសាចទឹកភ្លៀងចូលខ្លាចធ្វើឱ្យខូចឈើ។

**ទី៦**-គឺសិក្សាអំពីការកំណត់ទិសនៃសំណង់ ដែលវាជាកត្តាសំខាន់ដើម្បីកំណត់ច្រកចូល និងទាក់ទងទៅនឹងពន្លឺដែលចាំងចូលក្នុងផ្ទះទៀតផង។ ក្នុងនោះវាមានកត្តាច្រើនក្នុងការចូលរួមផ្សំដូចជា អាស្រ័យនឹងទីតាំងទំហំដី ទិសចាំងនៃពន្លឺព្រះអាទិត្យ ដែលជាទូទៅយើងចូលចិត្តសង់យកមុខផ្ទះចូលបែរទៅទិសខាងលិច ព្រោះក្នុងគោលដៅសម្រួលដល់ចំណាំងពន្លឺ និងកាត់បន្ថយកម្ដៅក្នុងផ្ទះទាំងមូល ហើយក៏មានចំណុចផ្សេងទៀតទាក់ទងនឹងទីតាំងប្រភពចំណី ព្រោះចង់ឱ្យសត្វត្រចៀកកាំទៅរកចំណីស៊ីរួចហើយត្រឡប់មកផ្ទះវិញ ឱ្យចំទិសតែម្ដង។

**ទី៧**-គឺជាលក្ខខណ្ឌពិសេសជាងគេដែលត្រូវមាននៅក្នុងផ្ទះនីមួយៗ គឺការជ្រើសរើសច្រកសត្វត្រចៀកកាំចូលការខ័ណ្ឌបន្ទប់សម្រាប់សត្វហោះហើរ កន្លែងដែលសត្វអាចចាក់សម្បុក និងរស់នៅ។

**ទី៨**-ជញ្ជាំងផ្ទះត្រចៀកកាំត្រូវមានកម្រាស់ ២តឹកកន្លះ ដោយរៀបឥដ្ឋជាពីរជួរសងខាង រក្សាប្រហោងនៅផ្នែកកណ្ដាល ព្រមទាំងដាក់គម្របបំពង់ទីបជ័រទំហំមួយតឹក ដោយចោះប្រហោងតូចៗ ទំហំ៥លី ដំរៀបជាជួរចម្ងាយពីមួយទៅមួយ ២ ទៅ៤តឹក ម្យ៉ាងទៀតគេអាចដាក់ឥដ្ឋខ្យល់ជំនួសឱ្យបំពង់ទីបជ័រ តម្រៀបតគ្នាជាជួរប្រវែង៣ម៉ែត្រតាមប្រឡោះជើងសសរមួយទៅជើងសសរមួយទៀត ប៉ុន្តែផ្នែកខាងក្រៅត្រូវវាយសំណាញ់ដែកមានរន្ធទំហំ៥លី ហើយផ្នែកខាងក្នុងពុំចាំបាច់វាយសំណាញ់ដែកទេ។ ការដាក់រន្ធខ្យល់ផ្នែកខាងក្នុង និងខាងក្រៅមានមួយជួរដូចគ្នាក្នុងមួយជាន់ ដោយផ្នែកខាងក្រៅក្រោមបាតប្លង់សេមានប្រវែង៥តឹក និងផ្នែកខាងក្នុងមានកម្ពស់៧តឹកលើបាតប្លង់សេ។

បន្ទាប់មកយើងចាប់ផ្ដើមបូកលើជញ្ជាំង ដោយផ្នែកខាងក្នុងពុំចាំបាច់ធ្វើការកៀរទេ សម្រាប់ទុកឱ្យសត្វទុំ តែផ្នែកខាងក្រៅយើងកៀរសំអាតធម្មតា។ ចំពោះប្លង់សេយើងពុំចាំបាច់កៀរសំអាតទាំងលើទាំងក្រោម។ ដំបូលត្រូវរៀបចំប្រក់ភីប្រូ ឬស័ង្កសី ប៉ុន្តែត្រូវរៀបចំដាក់ប្រព័ន្ធទឹកបាញ់នៅពេលថ្ងៃផ្នែកខាងលើដំបូលដើម្បីឱ្យដំបូលផ្ទះមានភាពត្រជាក់ជានិច្ច។





ជញ្ជាំងផ្ទះសត្វត្រចៀកកាំ និងផ្ទះកំពុងសាងសង់



ទិដ្ឋភាពខាងក្រៅផ្ទះសត្វត្រចៀកកាំដែលវាកំពុងរស់នៅ

## ៣-ការរចនាក្នុងផ្ទះតាមបច្ចេកទេស

ពេលនេះយើងនឹងធ្វើការសិក្សាអំពីចំនុចសំខាន់ដែលពាក់ព័ន្ធដូចខាងក្រោម៖

ក-ទិដ្ឋភាពទូទៅនៅក្នុងផ្ទះ ការខ័ណ្ឌបន្ទប់ ការរើសច្រកចូល ដំណើរកៀងការហោះ និងការជ្រករបស់សត្វ

ខ-ចំពោះទិដ្ឋភាពក្នុងផ្ទះ ត្រូវមានកត្តាចាំបាច់ខ្លះៗដូចខាងក្រោម៖

-ទំហំផ្ទះដែលល្អត្រូវមានទំហំ ៨ម៉ែត្រx២០ម៉ែត្រ

-ផ្ទះដែលល្អត្រូវមាន ១ជាន់ ឬ២ជាន់ តាមទីតាំង

-ផ្ទះដែលល្អត្រូវមាន ភាពត្រជាក់ ២៨អង្សាសេ

-ផ្ទះដែលល្អត្រូវមាន សំណើម ៧៥ភាគរយ

ហើយចំពោះមូលដ្ឋានក្នុងការសាងសង់សំណង់ថ្មីត្រូវទាមទាចំណុចពាក់ព័ន្ធបច្ចេកទេសមួយចំនួនមាន៖

-ត្រូវមានខ្យល់រក្សាភាពត្រជាក់ ២៨អង្សាសេ

-ត្រូវគ្មានពន្លឺ

-ការរចនាបន្ទប់ច្រកចូល

-ទ្វារចូលតាមបន្ទប់ទី១ និងទី២ ជាបន្ទប់ហោះឆ្វែល

-ទំហំបន្ទប់ចូលមានទំហំ៤ម៉ែត្រx៤ម៉ែត្រ លក្ខខណ្ឌដែលជាទំហំតូច សម្រាប់ធម្មជាតិក្នុងការហោះចាក់ឆ្វែលរបស់សត្វត្រចៀកកាំ

-ការខ័ណ្ឌបន្ទប់ដែលជាបន្ទប់រស់នៅ និងចាក់សម្បុក។

ចំពោះការខ័ណ្ឌបន្ទប់សម្រាប់កន្លែងរស់នៅ និងកន្លែងចាក់សម្បុកគឺអាស្រ័យទៅនឹងការតាមដានរបស់ការវិវឌ្ឍរស់នៅរបស់សត្វត្រចៀកកាំតាមខែក្រោយៗទៀត។ ត្រូវកៀងវាយ៉ាងណាឲ្យចូលនៅគ្រប់កន្លែងពេញផ្ទះ។













គំនូសបំប្រួញផ្ទះត្រចៀកកាំ និងចលនានៃការហោះឆ្វែលចូលក្នុងផ្ទះរបស់សត្វត្រចៀកកាំ

## ៤-ការរចនាចាប់ឈើលើពិដាន

ជាដំបូងយើងត្រូវយកចិត្តទុកដាក់ទៅលើ ៖

-ត្រូវជ្រើសរើសប្រភេទ និងទំហំឈើ

-ការទុកដាក់រៀបចំឈើមុនពេលយកមកប្រើប្រាស់

-វិធីសាស្រ្តក្នុងការចាប់ឈើលើពិដាន ការរៀបចំប្លង់ឈើ។

កាលដើមឡើយយើងចាប់ឈើលើពិដានតាមបែបទទឹងៗទៅនឹងទិសហោះចូលផ្ទះរបស់សត្វត្រចៀកកាំ តែក្រោយមកតាមបទពិសោធន៍ជាច្រើនឆ្នាំយើងមិនចាំបាច់គិតពីទិសហោះរបស់សត្វត្រចៀកកាំទៀតទេ ព្រោះជាការពិតយើងពិបាកក្នុងការកំណត់ទិសដៅសត្វហោះក្នុងផ្ទះនោះណាស់។ យើងកំណត់ថា ការវាយឈើត្រូវចាប់ដោយមានវិមាត្រ គឺទទឹង៦តឹក និងបណ្តោយ១ម៉ែត្រ ស្មើពេញក្នុងផ្ទះតែម្តង តែចង់បញ្ជាក់ថាទំហំទទឹងអាចតូចជាងនេះក៏បានកុំឲ្យតែតូចជាង៣តឹក។





ប្លង់ឈើដែលចាប់លើពិដានផ្ទះសត្វត្រចៀកកាំ

ក្នុងការរើសឈើត្រូវឈរលើគោលការណ៍ ទី១គឺប្រភេទឈើដែលមានលក្ខណៈដូចជា៖ សាច់មិនទន់ពេក មិនរឹងពេក មិនដុះផ្សិត មិនមានជ័រច្រើន ព្រោះកត្តាទាំងអស់នោះបានជះឥទ្ធិពលទៅលើការចាក់សម្បុក គឺបើវារឹងពេកសត្វធ្វើការចាក់សម្បុកមិនជាប់ បើទន់ពេកក៏ចាក់មិនចេញរាងដែរ ហើយបើមានជ័រច្រើននាំឲ្យខូចដល់គុណភាពនៃសម្បុកដែរ និងបើដុះផ្សិតក៏នាំឱ្យឈើឆាប់ពុកផុយ និងខូចសម្បុកផងដែរ។ កត្តាទី២ គឺអំពីទំហំឈើ ដែលជាទូទៅយើងនិយមយកឈើដែលមានកម្ពស់ត្រឹម ១២សង់ទីម៉ែត្រមិនលើសពីនោះទេ ព្រោះវាសម្រួលដល់ការទំរបស់សត្វត្រចៀកកាំតែម្តង រហូតដល់ក្រោយមកពីពីរទៅបីឆ្នាំក្រោយពេលសត្វត្រចៀកកាំបានធ្វើសម្បុកពេញ អាចវាយឈើបន្ថែមបានទៀត។

ឈើដែលគេប្រើនៅម៉ាឡេស៊ីឈ្មោះថា ម៉ាឡានទីត តែតាមបទពិសោធន៍នៅប្រទេសយើងគេប្រើឈើ ដួងចែម (*Tarrietia javanica Blume*) ឬផ្គុង(*Callophyllum sp.*) ក៏បានដែរ។ ក្នុងការរៀបចំទុកដាក់ឈើមុនទៅធ្វើការចាប់ចូលក្នុងផ្ទះ គឺត្រូវយកឈើស្ងួតល្អ កុំយកទៅចាប់ទាំងសើមនាំឱ្យដុះផ្សិត។ ការធ្វើឈើឲ្យស្ងួតល្អគេអាចយកទៅសំដិលឬយកទៅចំហុយក៏បាន ហើយចំពោះវិធីសាស្រ្តក្នុងការចាប់ឈើ គឺធ្វើយ៉ាងណាឱ្យរត់ត្រង់ជួរចុះមកក្រោម ដោយចាប់ក្នុងប្លង់ ទទឹង៦តឹក និងបណ្តោយ១ម៉ែត្រ។



ឈើក្តារបន្ទះសម្រាប់ធ្វើពិដានផ្ទះសត្វត្រចៀកកាំ

## ៥-ការជ្រើសរើសសំឡេង និងប្រព័ន្ធសំឡេង

ក្នុងការជ្រើសរើសសំឡេងនេះមានមូលដ្ឋាន ៣ប្រភេទសំខាន់ៗ ដែលទី១ យើងនឹងសិក្សាអំពីប្រភេទសំឡេងដែលជាទូទៅមានពីរប្រភេទគឺ៖

**-សំឡេងក្រៅ៖** ជាប្រភេទទី១ដែលមានតួនាទីជង្គោយហៅរកសត្វត្រចៀកកាំឱ្យចូលមករកផ្ទះដែលបានសាងសង់សម្រាប់ពួកគេ និងដើម្បីនាំផ្លូវផងដែរ។ ពួកសំឡេងក្រៅនេះអាចមានប្រភេទសំឡេងហៅឱ្យមកលេងផងដែរ ដែលសម្រាប់សម្រួលដល់ផ្ទះ ឬតំបន់ដែលកម្រមានសត្វត្រចៀកកាំ។

**-សំឡេងក្នុង៖** ជាប្រភេទសំឡេងទី២ ដែលប្រើសម្រាប់ដាក់ក្នុងបន្ទប់ឱ្យវារស់នៅនឹងចាក់សម្បុកពង និងកូន។

ចំពោះប្រភេទសំឡេងទាំងពីរនេះគឺមានច្រើនប្រភេទណាស់ ដែលយើងត្រូវធ្វើការជ្រើសរើសឱ្យបានល្អ ព្រោះវាអាចជាសំឡេងប្រកាសអាសន្នរវាងគ្នាវា សំឡេងហោះដេញគ្នាលេង សំឡេងមកយាយីគ្នា និងសំឡេងពីពូជខុសគ្នា។ ដូច្នេះការជ្រើសរើសយកសំឡេងមកចាប់ដាក់ក្នុងផ្ទះដែលយើងបានសាងសង់រួចហើយត្រូវប្រុងប្រយ័ត្នណាស់ អាចគួររើសយកដោយទិញពីកន្លែងណាដែលប្រើប្រាស់សំឡេងនេះជោគជ័យហើយទើបជាការល្អ ។

ខាងក្រោមនេះយើងនឹងសិក្សាអំពីប្លង់នៃការចាប់សំឡេង ចំនួន និងពេលវេលា ដែលត្រូវបើក និងបិទ។ យើងនឹងសិក្សាបន្តទៀតទាក់ទងទៅនឹង៖

- ទីតាំងសំឡេងខាងក្រៅ
- សំឡេងនាំផ្លូវ
- ការចាប់ និងទិសនៃការចាប់ឧបករណ៍បំពងសំឡេង
- ការបំពាក់ឧបករណ៍បំពងសំឡេងក្នុងផ្ទះ។

ចំពោះទីតាំងការចាប់សំឡេងក្រៅ អាស្រ័យទៅនឹងការជ្រើសរើសច្រកចូលរបស់ផ្ទះដែលបានសាងសង់ ដែលក្នុងនោះយើងកំណត់ជាមូលដ្ឋានផ្ទះ ៨ម៉ែត្រ x ២០ម៉ែត្រ ដោយត្រូវមានសំឡេងក្រៅ១៤គ្រាប់ ដែលត្រូវបានបែងចែកតាមលក្ខខណ្ឌដូចតទៅ៖

**ក**-ចំពោះផ្លូវច្រកចូលត្រូវដាក់៖

- បាញ់ទៅឆ្ពោះទៅមេឃមុំ ៤៥ ទៅ ៦០អង្សា
- ចាប់កែងៗ ៤គ្រាប់
- កែងលើបញ្ឈរ កែងក្រោមដាក់ផ្តេក
- កណ្តាល២គ្រាប់ ផ្តេក។




ដាក់មុំ ៤៥ទៅ ៦០អង្សា ឆ្ពោះទៅមេឃ

**ខ**-ចំពោះសំឡេងទ្វារបន្ទប់ទី១ គឺត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- ចាប់ធម្មតា
- ដាក់បាញ់ទៅច្រកចូល
- វាស់កម្ពស់ ២ម៉ែត្រ ចុះ១តឹក ដាក់១
- វាស់កម្ពស់ ១ម៉ែត្រ ៤តឹក ដាក់១។

ច្រកទ្វារបន្ទប់ទី១




**គ**-ចំពោះសំឡេងក្រៅបន្ទប់ទី២ គឺមានលក្ខណៈដូចគ្នានឹងបន្ទប់ទី១ ទាំងស្រុង។

ចំពោះសំឡេងក្រៅនេះពេលវេលាដែលត្រូវបើក និងបិទ គឺត្រូវធ្វើដូចខាងក្រោម៖

- បើកម៉ោង ៥កន្លះ បិទម៉ោង ៩ព្រឹក
- បើកម៉ោង ៩ និង១៥នាទី បិទម៉ោង ១២ថ្ងៃត្រង់
- បើកម៉ោង ១២ និង៣០នាទី បិទម៉ោង ៣រសៀល

- បើកម៉ោង ៣ និង១៥នាទីរសៀល បិទម៉ោង ៧យប់
- បិទរហូតដល់ ៥កន្លះបានចាប់ផ្ដើមបើកបន្តទៀត។

មូលហេតុនៃការបើក និងបិទសំឡេងនេះគឺមកពីសត្វត្រចៀកកាំជាសភាវរស់មានជីវិតដូចមនុស្សដែរ ដែលត្រូវការសម្រាក ដូច្នេះមិនចាំបាច់អ្វីដែលត្រូវបើករហូតដល់ ២៤ម៉ោងនោះឡើយ ហើយម្យ៉ាងទៀត គឺវាសម្រួលដល់គ្រឿងប្រព័ន្ធសំឡេងដែលត្រូវសម្រាកកុំឱ្យក្ដៅពេក ដែលធ្វើឲ្យឆាប់ឆេះខូច។

ចំពោះសំឡេងក្នុងវិញគឺត្រូវធ្វើយ៉ាងណាឱ្យឮស្មើពេញផ្ទះកុំឱ្យខ្សោយត្រង់កន្លែងណាមួយឡើយ។ ការចាប់ឧបករណ៍បំពងសំឡេងត្រូវអនុវត្តតាមជាក់ស្ដែងនៃទម្រង់របស់បន្ទប់និងកន្លែងនីមួយៗ ហើយតម្រូវឲ្យធ្វើដូចខាងក្រោម៖

- ចំនួន ឧបករណ៍បំពងសំឡេងដាក់តាមបន្ទប់មាន ១៩២គ្រាប់ ក្នុងកម្រិត៤ម៉ែត្រការ៉េ ដាក់២០គ្រាប់
- តាមជួរឈើ (បណ្ដោយផ្ទះ ១,២ម៉ែត្រ ចំនួន១)
- ទទឹង ៨តឹក ១ម៉ែត្រ មានចំនួន ១គ្រាប់
- ការចាប់ឧបករណ៍បំពងសំឡេងទៅតាមឈើ និងទិស ដោយគិតពីបញ្ហាខ្ចរសំឡេង
- បែរទទឹងផ្ទះ ឆ្លាស់គ្នា ១,២ម៉ែត
- ត្រង់កែងៗ ចាប់ជ្រុងមុំ ៤៥អង្សា។



ទីតាំងឧបករណ៍បំពងសំឡេងរាយដាក់តាមបន្ទប់

ចំពោះការចាប់ត្រូវគិតរកទីតាំងទៅបន្ទប់ត្រួតពិនិត្យ និងការបែងចែកខ្សែមេ ដោយធ្វើយ៉ាងណាឱ្យស្មើគ្នា ដែលជៀសវាងពីរយៈចម្ងាយវែងខ្លីខុសគ្នាដែលអាចឱ្យសំឡេងខ្សោយក្នុងលក្ខខណ្ឌណាមួយនោះ។ ម្យ៉ាងវិញទៀតការតខ្សែ និងតំណជាកត្តាសំខាន់ត្រូវរុំឱ្យល្អកុំឱ្យបាត់បង់សំឡេងឬឮមិនស្មើ។

ការចាប់ឧបករណ៍បំពងសំឡេងត្រូវអនុវត្តដូចខាងក្រោម៖

- ប្រកចូល មានចំនួន ១២គ្រាប់
- បន្ទប់ទី២ មានចំនួន ២០គ្រាប់
- ប្រឡោះទី៣ មានចំនួន ២០គ្រាប់
- ២ប្រឡោះ ក្រោយ មួយ មេ
- ល្វែងមួយទៀត ២មេ ទៀត រួមមាន៖
  - ល្វែងឆ្ងាយ ២ប្រឡោះ ១មេ
  - បីប្រឡោះ កៀកបន្ទប់ត្រួតពិនិត្យ ១មេ។

ចំពោះរយៈពេលក្នុងការបើក និងបិទមានសភាពខុសគ្នាបន្តិចពីសំឡេងក្រៅដូចតទៅ៖

- បើកម៉ោង ៥ បិទម៉ោង ៩ព្រឹក
- បើកម៉ោង ៩ និង១៥នាទី បិទម៉ោង ១២ថ្ងៃត្រង់
- បើកម៉ោង ១២ និង១៥នាទី បិទម៉ោង ៣រសៀល
- បើកម៉ោង ៣ និង១៥នាទីរសៀល បិទម៉ោង ៧យប់
- បើកម៉ោង ៧ និង១៥នាទីយប់ បិទម៉ោង ១០យប់
- បិទរហូតដល់ ៥ព្រឹក បានចាប់ផ្ដើមបើកទៀត។

សំឡេងជាកត្តាសំខាន់ដែលត្រូវយកចិត្តទុកដាក់ពេលដែលសាងសង់ជំឡើងចប់សព្វគ្រប់ ត្រូវដើរត្រួតពិនិត្យស្ដាប់ឱ្យបានយកចិត្តទុកដាក់ដើម្បីប្រាកដថា វាឮល្អគ្រប់កន្លែងស្មើសាច់ ពេញផ្ទះ ជាសំឡេងក្នុង ហើយសំឡេងក្រៅត្រូវឮតាមទីតាំងឱ្យបានល្អប្រពៃ។

## ៦- ប្រព័ន្ធទឹកក្នុងផ្ទះ

គោលបំណងក្នុងការដាក់ប្រព័ន្ធទឹក គឺដើម្បីធ្វើយ៉ាងណាជំរុញសីតុណ្ហភាពក្នុងផ្ទះឱ្យនៅបានចន្លោះពី ២៧ ដល់ ៣០អង្សាសេ និងសំណើម ចន្លោះពី ៧៥% ដល់ ៨៥%។ ការបែងចែកទឹកត្រូវធ្វើឱ្យបានសព្វពេញផ្ទះក្នុងតែម្ដង។ កាលពីសម័យបុរាណគេដាក់ចានធំៗ សម្រាប់ជួយសំណើម តែក្រោយមកក៏មានម៉ាស៊ីនទឹកដែលល្អសម្រាប់ធ្វើឱ្យមានសំណើមចុះអ័ព្ទដូចនៅលើភ្នំបូកគោដូច្នោះដែរ។

ការដាក់ប្រព័ន្ធទឹកត្រូវសិក្សាចំណុចដូចខាងក្រោម៖

- មូលដ្ឋាននៃប្រព័ន្ធទឹក
- ប្រភេទប្រព័ន្ធទឹក

- ទីតាំងដាក់ប្រព័ន្ធទឹក
- ការប្រែប្រួលនៃប្រព័ន្ធទឹក។

ជាទូទៅមូលដ្ឋាននៃប្រព័ន្ធទឹកគឺ៖

- កម្រិត សំណើម ៧៥%
- សីតុណ្ហភាព ២៨អង្សាសេ
- តាមរដូវកាល
- តាមតំបន់
- តាមខែដែលសត្វត្រចៀកកាំធ្វើសម្បុកពង និងកូន។

ចំពោះការរៀបចំប្រព័ន្ធទឹក យើងសូមលើកឡើងតែពីម៉ាស៊ីនទឹកមួយមកបង្ហាញ ដែលត្រូវអនុវត្តតាម៖

- មូលដ្ឋានធ្វើយ៉ាងណាឲ្យស្រោចស្រពពេញផ្ទៃផ្ទះ
- ដាក់ក្នុងបន្ទប់ទី២
- ដាក់តាមទំហំបាញ់
- ជាទូទៅ៤០ម៉ែត្រការ៉េ ដាក់ម៉ាស៊ីនបាញ់ផ្សែង១។

មានការកែប្រែកម្រិតទឹក និងប្រព័ន្ធទឹកទៅតាមលក្ខណៈជាក់ស្តែងដែលរួមមាន៖

- មូលដ្ឋានទៅតាមទីតាំង និងរដូវ
- ដាក់១៥នាទីម្តងពីម៉ោង១០ព្រឹក រហូតដល់ម៉ោង៥រសៀល
- ខែខ្យល់ខ្លាំងឱ្យវាលេងក្នុងផ្ទះ
- ភ្លៀងខ្លាំងពេកវាលេងក្នុងផ្ទះ
- ពេលចាក់សម្បុកវាលេងក្នុងផ្ទះ
- ពេលទើបចេះហើរវាហោះលេងក្នុងផ្ទះ
- ប្រព័ន្ធទឹកតាមម៉ាស៊ីនបាញ់ផ្សែងនេះត្រូវបានត្រួតពិនិត្យបើកបិទដោយស្វ័យប្រវត្ត(Timer) សំឡេងក្នុង និងសំឡេងក្រៅប្រព័ន្ធទឹក
- មូលដ្ឋានស្រោចស្រព ៧ថ្ងៃពេញក្នុងមួយសប្តាហ៍
- ដាក់ឱ្យត្រូវតាមល្វែងម៉ោង
- ដាក់បិតបើកទៅតាមម៉ោងពេលដែលបានកំណត់នៃសំឡេងក្នុង សំឡេងក្រៅ និងប្រព័ន្ធទឹក។

វាសំខាន់ណាស់ដែលត្រូវមានទឹកសម្រួលដល់ការចូលចិត្តហោះហើរលេង សម្រួលដល់ការពង ញាស់ និងការលូតលាស់របស់សត្វ និងកូនត្រចៀកកាំ ដែលសំខាន់រក្សាឱ្យបាននូវសីតុណ្ហភាព២៨អង្សាសេ និងសំណើម៧៥% ជាដើម ដែលជាកត្តានាំមកនូវភាពជោគជ័យ។



ម៉ាស៊ីនបាញ់ផ្សែងទឹកក្នុងផ្ទះសត្វត្រចៀកកាំ និងការកំណត់ដាក់ម៉ោងបិទបើកដោយស្វ័យប្រវត្ត

ក្រៅពីការរៀបចំដូចបានរៀបរាប់ខាងលើហើយ ក៏ត្រូវធ្វើការតាមដានលើការវិវឌ្ឍផ្សេងៗទៀត ដូចជាសំឡេង សីតុណ្ហភាព ក្លិនសំណង់ ក្លិនលាមកវា របាយសត្វត្រចៀកកាំក្នុងផ្ទះ ការយាយីរំខានពីសត្វផ្សេងៗទៀតជាដើម ស្របតាមក្បួនខ្នាតបច្ចេកទេស នោះទើបទទួលបានជោគជ័យ។ នៅអត្ថបទក្រោយនឹងលើកយកមកបង្ហាញពីបច្ចេកទេសនេះ និងរបៀបនៃការប្រមូលផលផងដែរ។

## ឯសារយោង៖

https://www.nytimes.com/2011/07/14/world/asia/14sukadana.html

https://rove.me/to/malaysia/harvest-of-edible-swiftlet-nests

https://www.bbc.com/news/world-asia-pacific-2274825

# កិច្ចសហការរដ្ឋបាលព្រៃឈើ និងអង្គការសម្ព័ន្ធមិត្តសត្វព្រៃគាំទ្រសហគមន៍ព្រៃឈើប្រាំបីមុំខេត្តកំពង់ស្ពឺ

ដោយ៖ លោក រ័ត្ន ប៊ុនធឿន ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវដី និងព្រៃឈើ នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ព្រៃឈើ-សត្វព្រៃ

សហគមន៍ព្រៃឈើប្រាំបីមុំ ជួបប្រជុំបែងចែកក្រុមល្បាតសហគមន៍ជាពីរក្រុមឆ្លាស់វេនគ្នា ក្នុងការស្វែងរកអន្ទាក់ទាំងក្នុង និងក្រៅដែនព្រៃ។ រវាងខែកុម្ភៈ និងមីនា ឆ្នាំ២០២២ ក្រុមការងាររុករកឃើញអន្ទាក់៨៩ខ្សែនៅតាមចម្ការអំពៅ ព្រៃមាត់អូរ។ រីឯម៉ាស៊ីនថតបានកំណត់ឃើញសត្វទន្សោងមានកូន០៤ក្បាល និងហ្វូងដទៃទៀតមួយចំនួនមានកូនតូចអាយុក្រោម១ឆ្នាំ មិនអាចកំណត់ចំនួនបាន។ ជាមួយគ្នានេះ ក្រុមល្បាតបានព្យាយាមគៀងទន្សោងពេលយប់កាត់បន្ថយការស៊ីបានខ្លះៗ ប៉ុន្តែជួបកាលំបាកច្រើន ព្រោះពេលយប់សត្វបានបង្កផលប៉ះពាល់ដំណាំអំពៅនៅភាគខាងត្បូងជាច្រើន។ យើងបានបង្ហោះ Drone និងកំណត់បានហ្វូងទន្សោងមួយមានចំនួន ២៤ក្បាលនៅភាគអគ្នេយ៍នៃព្រៃសហគមន៍ និងកំពុងប្រត្តិបត្តិការហោះរកដើម្បីវាយតម្លៃ ប៉ាន់ប្រមាណចំនួនហ្វូង និងចំនួនសត្វបន្ថែមទៀត ប៉ុន្តែជួបការលំបាកខ្លះៗព្រោះមានល្បះថ្មីលាស់លាយឡំស្លឹកចាស់។





សត្វទន្សោងមករកចំណី និងផឹកទឹកក្នុងអាង



រូបភាពថតពីដ្រូន (Drone) ដើម្បីកំណត់ហ្វូងទន្សោង



ចម្ការអំពៅរងនូវការស៊ីពីសត្វទន្សោងនៅភាគខាងត្បូង

នៅខែមេសា និងឧសភា ឆ្នាំ២០២២ ក្រុមទាំងពីរបានល្បាតព្រៃចំនួន២៤លើក ស្មើនឹង១៦៣នាក់ និងបានរុករកឃើញអន្ទាក់៨២ខ្សែនៅតាមចម្ការអំពៅ ព្រៃមាត់អូរ។ រីឯម៉ាស៊ីនថតបានកំណត់ឃើញសត្វទន្សោងមួយចំនួនបានចល័តចាកចេញទៅកន្លែងផ្សេង និងមួយចំនួនមករកប្រភពទឹកអាងដូចតាមទម្លាប់។ ក្រៅពីរុករកអន្ទាក់ ក្រុមល្បាតបានតាមដានហ្វូងទន្សោងជាប្រចាំដែលបានបម្លាស់ទីទៅភាគខាងត្បូងឈៀងខាងលិចប្រមាណ៦គម។ ទីនោះជាតំបន់ភ្នំស្ថិតក្រៅដែនព្រៃសហគមន៍ និងព័ទ្ធដោយចម្ការអំពៅ។ ចំពោះការល្បាតនៅពេលយប់បាន បញ្ចៀសហ្វូងទន្សោងចេញមកស៊ីអំពៅនៅចម្ការភាគខាងត្បូង។ ក្រុមការងារបានពិនិត្យការជីកប្រឡាយរបស់ក្រុមហ៊ុនដើម្បីទប់ស្កាត់ការឆ្លងរបស់សត្វមកស៊ីដំណាំអំពៅ និងបានកំណត់ហានិភ័យចំពោះកូនសត្វ ប្រសិនបើមានធ្លាក់ចូលក្នុងប្រឡាយ ដែលជាការងារក្រុមល្បាតរបស់យើងត្រូវត្រួតពិនិត្យជាប្រចាំ។





ការពិនិត្យការជីកប្រឡាយរបស់ក្រុមហ៊ុន ដើម្បីទប់ស្កាត់ការឆ្លងរបស់សត្វមកស៊ីដំណាំចម្ការអំពៅ



ក្រុមការងារជ្រើនដែលចុះប្រតិបត្តិការជាប្រចាំដើម្បីវាយតម្លៃ ប៉ាន់ប្រមាណចំនួនហ្វូង និងចំនួនសត្វបន្ថែមទៀត

# តើអ្នកដឹងអ្វីខ្លះពី សត្វក្រៀល? Sarus crane

*ដោយលោកៈ ញ៉ាន ប៊ុនថន ការិ.សង្គ្រោះ វិបុលកម្ម និងកីឡាប្រមាញ់*

សត្វក្រៀលគឺជាសត្វស្លាបដែលមានកម្ពស់ខ្ពស់ជាងគេលើពិភពលោក ហើយអាចហើរបាន។ ជាទូទៅ សត្វក្រៀលមានកម្ពស់ប្រហែល ១,៧៦ ម៉ែត្រ មានទម្ងន់ពី ៥-១២គីឡូក្រាម និងប្រវែងស្លាបទាំងសងខាង ២,៥ ម៉ែត្រ។ ពួកវាមានម្រាមជើងមុខវែងៗចំនួនបី និងម្រាមជើងក្រោយខ្លីមួយ។ ពួកវាមិនអាចទំនៅលើដើមឈើបានទេ ហើយដេកដោយឈរស្ងៀមផ្អឹងនៅទីតាំងជិតៗកន្លែងរកចំណីរបស់វានៃតំបន់ដីសើម។ សត្វក្រៀលមានសម្បុរប្រផេះលើដងខ្លួន កផ្នែកខាងលើនិងក្បាលមានពណ៌ក្រហមក្បាលផ្នែកខាងលើបំផុត និងត្រចៀក មានពណ៌ប្រផេះស្រាល។ កូនក្រៀលមានមាឌតូចបន្តិច និងមានពណ៌ត្នោតនៅចំក្បាលរបស់វា។ គេពិបាកសម្គាល់ថា សត្វក្រៀលណាជាឈ្មោល ឬញី នៅពេលដែលពួកវានៅជាគូ ប៉ុន្តែមីញីមានមាឌតូចជាងអាឈ្មោលបន្តិច។ សត្វក្រៀលត្រូវបានចាត់ជាប្រភេទសត្វងាយរងគ្រោះនៅក្នុងបញ្ជី ក្រហម IUCN។






សត្វក្រៀលញីឈ្មោល



ហ្វូងសត្វក្រៀល

## លក្ខណៈជីវសាស្ត្រនៃសត្វក្រៀល

ការរស់នៅរបស់សត្វក្រៀលនារដូវប្រាំង (ខែធ្នូ ដល់ខែមេសា)ដែលជារដូវមិនបន្តពូជ និងត្រូវខិតខំស្វែងរកចំណី សត្វក្រៀលបានហើរផ្លាស់ទីពីតំបន់ដែលពួកវាពងកូន ទៅរកចំណី និងដេកជាហ្វូងៗ នៅតាមតំបន់ដីសើមដែលមានទឹករាក់ៗ និងសម្បូរដោយចំណី។ ទោះបីជាសត្វក្រៀលរស់នៅជាហ្វូងក៏ដោយពួកវាក៏នៅតែរស់នៅជាក្រុមគ្រួសារផ្សេងៗគ្នា ដោយស្រែកច្រៀងដាក់គ្នាទៅវិញទៅមក។ នេះអាចជាការបញ្ជាក់ពីភក្ដីភាពរបស់ពួកវា ឬបញ្ចេញសញ្ញាថាពួកវាកំពុងត្រូវបានទទួលរងការគំរាមកំហែងនានា។

ការរកចំណីរបស់សត្វក្រៀលទាំងអស់ជាសព្វាសី មានន័យថាពួកវាស៊ីទាំងរុក្ខជាតិ និងសត្វ។ សត្វក្រៀលស៊ីរុក្ខជាតិទឹក មើមរុក្ខជាតិ សត្វឥតឆ្អឹងកង គ្រាប់ធញ្ញជាតិ និងសត្វឆ្អឹងកងតូចៗ ព្រមទាំងសត្វល្អិតជាអាហារ។ សត្វក្រៀលប្រើចំពុះវែងរឹងមាំរបស់វាសម្រាប់ចឹកស៊ីមើមផ្លង និងសត្វល្អិតពីក្នុងភក់ល្បាប់។ ជូនកាលពួកវាចឹកប៉ះចំត្រី ឬកង្កែប ទោះបីជាពួកវាមានការលំបាកក្នុងការបំបែកអាហារទាំងនេះជាចំណែកតូចៗដើម្បីលេបក៏ដោយ។ បន្ទាប់ពីកសិករបានច្រូតកាត់ប្រមូលផលស្រូវរួចសត្វក្រៀលនឹងទៅរកចំណីក្នុងវាលស្រែទាំងនោះដោយស៊ីគ្រាប់ស្រូវដែលជ្រុះក្នុងស្រែ។ មេបារបស់សត្វក្រៀលបង្រៀនកូនរបស់វាពីវិធីរកចំណី ព្រមទាំងពាំនាំយកចំណីឲ្យកូន ទោះបីជាកូនរបស់វាធំធាត់ស្មើរតែពេញវ័យហើយក៏ដោយ។

## ការសំអាតខ្លួនរបស់សត្វក្រៀល

សត្វក្រៀលតែងតែងូតទឹក និងសសិតរោមរបស់វាជាទៀងទាត់ដើម្បីសំអាតខ្លួន។ នៅពេលដែលសសិតរោមវានឹងបញ្ចេញជាតិប្រេងពីក្រពេញម៉្យាងទៅដល់រោមរបស់វា។

## ការបន្តពូជរបស់សត្វក្រៀល

មនោសញ្ចេតនាស្នេហារបស់សត្វក្រៀល គឺសត្វក្រៀលញីឈ្មោលដែលបានបន្តពូជជាមួយគ្នា ពួកវានឹងរួមរស់នៅជាមួយគ្នាអស់មួយជីវិត(សត្វស្មោះស្នេហ៍)។ ក្នុងអំឡុងរដូវបន្តពូជ សត្វក្រៀលដែលមានគូ គឺមានដែនដីផ្ទាល់ខ្លួនរបស់វា តែនៅអំឡុងពេលមិនបន្តពូជ និងពេលដែលពួកវារកចំណីជាហ្វូងៗ ពួកវានៅតែងដើររកចំណីជាក្រុមគ្រួសាររៀងៗខ្លួន។ ពួកវាតែងតែស្រែកច្រៀងដាក់គ្នាទៅវិញទៅមកដើម្បីបញ្ជាក់ពីចំណងភក្តីភាពនៃគ្រួសាររបស់ខ្លួន។ សម្រែកច្រៀងត្រសងគ្នាសត្វក្រៀលដែលមានគូ តែងតែស្រែកច្រៀងត្រសងគ្នាជាញឹកញាប់ដោយស្រែកបន្តគ្នា។ ការស្រែកនេះចាប់ផ្តើមពីអាឈ្មោល និងបន្តដោយមីញី ហើយយើងពិបាកនឹងដឹងថាពេលណាជាសំលេងអាឈ្មោលចប់ និងសំឡេងមីញីចាប់ផ្តើម។ នៅពេលស្រែកម្តងៗ អាឈ្មោលតែងតែត្រដាងស្លាបទៅលើខ្នង ហើយមីញីតែងតែក្តោបស្លាបនៅនឹងខ្លួនវា។

## ការចែចង់គ្នារបស់សត្វក្រៀល

ការចែចង់គ្នាគឺចាប់ផ្តើមពីអាឈ្មោល និងបន្តដោយមីញី ទោះបីជាមីញីមិនសូវសកម្មក៏ដោយ។ អាឈ្មោលចាប់ផ្តើមដោយត្រដាងស្លាបបើក រួចបង្អោនខ្លួនបន្តិច បន្ទាប់មកលោតផ្លោះ ថែមទាំងផ្អៀងផ្អងខ្លួនចុះឡើងៗ រួចងើបក្បាលឡើងមុននឹងស្រែកកងរំពង។ បន្ទាប់មកមីញីក៏ចូលរួមកាយវិការទាំងនេះ ដោយយើងឃើញក្រៀលញីឈ្មោលចែចង់គ្នាដោយលោតចុះឡើងដាក់គ្នាទៅវិញទៅមក។ ការចែចង់គ្នានេះមានភាពរស់រវើក និងពិសេសអស្ចារ្យណាស់ដោយមានសម្រែកច្រៀងត្រសងគ្នាក្នុងពេលដំណាលគ្នានោះ។



សម្រែកច្រៀងត្រសងក្នុងពេលចែចង់គ្នានៃដៃគូសត្វក្រៀល ដែលញីតែងតែក្តោបស្លាបនៅនឹងខ្លួនរបស់វា

## ការរួមសង្វាស់

បន្ទាប់ពីការចែចង់គ្នាបានបញ្ចប់ សត្វក្រៀលនឹងត្រឡប់ទៅសភាពធម្មតាវិញ ប៉ុន្តែជូនកាលសត្វញីនឹងបន្ទាបខ្លួនឲ្យអាឈ្មោលជាន់ញី(រួមសង្វាស់)។ ការរួមសង្វាស់នេះមានរយៈពេលតែ ៣ ឬ ៤វិនាទី ប៉ុណ្ណោះ ហើយវាមានរយៈពេលខ្លីណាស់បើធៀបនឹងការចែចង់គ្នា។

## វដ្តជីវិតសត្វក្រៀល

ពេលកាច់សំបុកនៅរដូវបន្តពូជ សត្វក្រៀលញីឈ្មោលនឹងបំបែកហ្វូង រួចស្វែងរកទីតាំងសម្រាប់កាច់សំបុក។ នៅប្រទេសកម្ពុជា សត្វក្រៀលជ្រើសរើសព្រៃឈ្មោះដែលមានតំបន់ដីសើមដែលជាផ្នែកមួយនៃវាលស្មៅ

នៅក្នុងព្រៃនោះ។ ក្រៀលញីឈ្មោលទាំងពីររួមគ្នាធ្វើសំបុក ដែលសំបុកនោះធ្វើពីចំបើង និងស្មៅត្រែងជាដើម។ សំបុកទាំងនោះមានអង្កត់ផ្ចិតរហូតដល់២ម៉ែត្រ និងកម្ពស់រហូតដល់១ម៉ែត្រ ចំណែកឯស៊ុតក្រៀលគឺស្រាលអាចអណ្តែតលើផ្ទៃទឹកបាន។



សត្វក្រៀល និងសំបុកពងរបស់វា



ពងសត្វក្រៀល

## ការផ្តល់កំណើត

ជាទូទៅ សត្វក្រៀលផ្តល់កំណើតដោយមានស៊ុតចំនួន ០២គ្រាប់ តែនៅពេលខ្លះមានស៊ុតចំនួន០៣គ្រាប់ ហើយកម្រនឹងមានស៊ុត០៤គ្រាប់ណាស់។ ក្រៀលញីឈ្មោលទាំងពីរក្រាបពង ទោះបីជាភាគច្រើនមីញីមានតួនាទីក្រាបពង រីឯអាឈ្មោលមានតួនាទីការពារសំបុកពីការឃាយីរបស់សត្រូវ។ ស៊ុតត្រូវបានញាស់ក្នុងអំឡុងពេលពី ៣០ ទៅ ៣៤ ថ្ងៃ រហូតដល់ពេលវាញាស់។

## ការញាស់

កូនតូចដែលទើបនឹងញាស់គឺឆាប់ធំធាត់ណាស់បើធៀបនឹងសត្វស្លាបផ្សេងទៀត។ ពួកវាបើកភ្នែកភ្លាមៗបន្ទាប់ពីញាស់ ហើយអាចដើរបាននៅពេលដែលរោមរបស់វាស្ងួតភ្លាមៗនោះ។ កូនតូចអាចរត់កាត់ទឹករាក់ៗបានយ៉ាងលឿន ហើយដើរតាមមេរបស់វា។ នៅពេលដែលកូនក្រៀលមានអាយុ ៣ ឬ ៤ខែ វានឹងមានដុះស្លាបសម្រាប់ហោះហើរបានហើយ។



កូនសត្វក្រៀល

## ការរស់នៅរបស់កូនក្រៀល

កូនក្រៀលធំធាត់យ៉ាងឆាប់រហ័ស ហើយជាទូទៅ រៀងរាល់ឆ្នាំមានតែកូនមួយទេដែល អាចរស់រៀនមានជីវិត។ កូនក្រៀលនឹងដើរតាមមេបារបស់វាដើម្បីរៀនស្វែងរកចំណី និងគេចវេសពីសត្រូវដែលតាមយាយីវា។ នៅពេលដែលកូនក្រៀលមានអាយុ៥ ឬ៦ខែ វានឹងត្រូវបានចូលរួមក្នុងហ្វូងក្រៀល។ កូនក្រៀលនឹងនៅជាមួយមេបារបស់វាពេញមួយឆ្នាំដើម្បីឲ្យមានភាពម្ចាស់ការអាចដើរហើរដោយខ្លួនឯងបាន។

## សត្វក្រៀលពេញវ័យ

សត្វក្រៀលពេញវ័យនឹងចូលរួមជាមួយហ្វូងក្រៀល ហើយហោះហើរចុះឡើងនៅក្នុងប្រទេសកម្ពុជាទៅតាមរដូវកាល រហូតដល់ពេលដែលវាជួបដៃគូបន្តពូជរបស់វា និងបន្តខ្សែជីវិតដូចដែលវដ្តជីវិតរបស់វា។ គេបានកត់ត្រាថាសត្វក្រៀលអាចរស់នៅបានរហូតដល់អាយុ៤២ឆ្នាំ (រស់នៅក្នុងសួនសត្វ)។

## ជំនឿវប្បធម៌ទៅលើសត្វក្រៀល

សត្វក្រៀលមានវត្តមាននៅក្នុងប្រទេសកម្ពុជាតាំងពីយូរលង់ណាស់មកហើយគិតចាប់ពីសម័យអង្គរ នាសតវត្សទី៩ ដល់ សតវត្សទី១៥។ បើសិនយើងបានទស្សនាប្រាសាទបាយ័ននៅខេត្តសៀមរាប យើងនឹងឃើញរូបចម្លាក់សត្វក្រៀលដែលត្រូវបានឆ្លាក់ជាប់នឹងផ្ទាំងថ្ម។ ប្រជាជនមូលដ្ឋានធ្លាប់មានជំនឿថានៅពេលដែលមានសត្វក្រៀលមួយគូហើរវិលវង់ដំបូលផ្ទះនរណាម្នាក់ នោះនឹងមានគូស្នេហ៍វ័យក្មេងនៃគ្រួសារនោះពង្រត់គ្នាពុំខាន។ ប៉ុន្តែសព្វថ្ងៃនេះ ប្រជាជនឈប់ជឿអបិយជំនឿនោះទៀតហើយ។



រូបចម្លាក់សត្វក្រៀលដែលត្រូវបានឆ្លាក់ជាប់នឹងផ្ទាំងថ្ម នៃប្រាសាទបាយ័ន នៅខេត្តសៀមរាប

## នៅក្នុងទ្វីបអាស៊ី

សត្វក្រៀលគឺជានិមិត្តរូបនៃជោគវាសនាល្អ និងអាយុយឺនយូរ។ ពួកវាក៏ត្រូវបានគេគិតថាជានិមិត្តរូបនៃមនោសញ្ចេតនាស្នេហាស្ម័គ្រស្មោះ ដោយយោងទៅតាមការភ្ជាប់ចំណងមេត្រីភាពរបស់ពួកវា។ តាំងពីបុរាណកាលរហូតដល់បច្ចុប្បន្ន ប្រជាជននៅទ្វីបអាស៊ី មានចិន កូរ៉េ ជប៉ុន វៀតណាម និងខ្មែរ មានជំនឿថា សត្វក្រៀល ជានិមិត្តរូបនាំមកនូវសេចក្ដីសុខដុមរមនា ត្រជាក់ត្រជុំ អាយុយឺនយូរដល់មនុស្ស ហេតុដូច្នេះហើយបានជាគេនិយមជូនអំណោយដល់គ្នាទៅវិញទៅមកនូវរូបសត្វក្រៀលដ៏ស្រស់ស្អាតសម្រាប់ដាក់តាំងនៅតាមគេហដ្ឋាន។ នៅក្នុងប្រទេសភូមា សត្វក្រៀល ត្រូវបានគេឃើញមានក្នុងពុទ្ធសាសនា។



រូបគំនូរសត្វក្រៀលចិន ត្រូវបានប្រើជានិមិត្តរូបហុងស៊ុយ ដើម្បីនាំថាមពលនៃជីវិតដ៏ថ្លៃថ្នូរ និងសន្តិភាព និងនាំព្រលឹងមនុស្សទៅកាន់ឋានសួគ៌

## ទីជម្រកសត្វក្រៀលនៅកម្ពុជា

សត្វក្រៀលប្រើប្រាស់ទីជម្រកផ្សេងៗ គ្នាដែលមានវិសាលភាពធំគ្របដណ្ដប់ទូទាំងប្រទេសកម្ពុជាដែលនេះជា

តម្រូវការនានានៅរដូវកាលផ្សេងៗគ្នាសម្រាប់សត្វក្រៀល។

នៅរដូវពងកូនចាប់ពី ខែកក្កដា ដល់ ខែតុលា សត្វក្រៀលធ្វើបំលាស់ទីទៅភាគខាងជើង និងភាគឦសាន (ខាងជើងឈាងខាងកើត) នៃប្រទេសកម្ពុជា។ នៅក្នុងព្រៃដែលសម្បូរដោយតំបន់ដីសើមតូចៗ(ត្រពាំង ឬថ្លុកទឹក) គឺជាទីជម្រកដ៏សំខាន់សម្រាប់បន្តពូជ។

នៅរដូវរកចំណីមិនបន្តពូជចាប់ពី ខែធ្នូ ដល់ ខែមេសា សត្វក្រៀលធ្វើការផ្លាស់ទីទៅភាគពាយ័ព្យ(ខាងជើងឈាងខាងលិច) និងភាគអាគ្នេយ៍ (ខាងត្បូងឈាងខាងកើត) នៃប្រទេសកម្ពុជា ដែលជាទីជម្រកដ៏សំខាន់សម្រាប់រកចំណីបំប៉នសុខភាពសម្រាប់រដូវបន្តពូជ។ សត្វក្រៀលធ្វើការផ្លាស់ទីពីទីតាំងបន្តពូជទៅទីតាំងរកចំណីនៅចន្លោះ ខែតុលា និងខែវិច្ឆិកា អាស្រ័យលើស្ថានភាពរដូវវស្សាប្រចាំឆ្នាំ។ ពួកវាធ្វើការផ្លាស់ទីពីទីតាំងរកចំណីទៅទីតាំងបន្តពូជវិញនៅចន្លោះខែមេសា និងខែមិថុនា។

## រដូវពងកូន

នៅរដូវពងកូន សត្វក្រៀលញីឈ្មោលដែលជាដៃគូបន្តពូជនឹងបំបែកខ្លួនចេញពីហ្វូងរបស់វា ហើយស្វែងរកទីតាំងសមរម្យដើម្បីធ្វើសំបុក។ នៅក្នុងប្រទេសកម្ពុជា ទីតាំងដែលពួកវាធ្វើសំបុកគឺជាតំបន់ព្រៃល្បោះដែលសំបូរដោយតំបន់ដីសើមតូចៗ (ត្រពាំង ឬថ្លុកទឹកផ្សេងៗ)។



សត្វក្រៀលញីឈ្មោលដែលជាដៃគូបន្តពូជ បំបែកខ្លួនចេញពីហ្វូងរបស់វានៅតំបន់អាងត្រពាំងថ្ម

ទីតាំងពងកូនទាំងនេះ គឺស្ថិតនៅតំបន់ព្រៃភាគខាងជើងនៃប្រទេសកម្ពុជា។ ទីតាំងពងកូនទាំងនោះភាគច្រើនគឺស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ។

## រដូវរកចំណី និងមិនបន្តពូជ

នៅរដូវមិនបន្តពូជ សត្វក្រៀលតែងរកចំណីផ្តុំគ្នាជាហ្វូងៗ ដែលក្នុងហ្វូងនោះពួកវារកស៊ីផ្តុំគ្នា ឬហោះហើរជាគ្រួសារនីមួយៗ។ ក្នុងរដូវនេះ សត្វក្រៀលដែលពុំទាន់មានគូនឹងប្រមូលផ្តុំ គ្នាដើម្បីចងសម្ព័ន្ធមេត្រីសម្រាប់រដូវពងកូនបន្ទាប់ពីរដូវរកចំណីនេះ។ នៅរដូវរកចំណី សត្វក្រៀលធ្វើផ្លាស់ទីទៅតំបន់ផ្សេងៗគ្នានៅក្នុងប្រទេសកម្ពុជា។ ចំនួនសត្វក្រៀលប្រហែលពាក់កណ្តាល ធ្វើការផ្លាស់ទីទៅតំបន់នានានៃអាងទន្លេសាប ដោយរាប់បញ្ចូលទាំងតំបន់ការពារទេសភាពអាងត្រពាំងថ្ម ហើយចំនួនសត្វក្រៀលប្រហែលពាក់កណ្តាលទៀត ធ្វើការផ្លាស់ទីទៅតំបន់ដែនដីសណ្តរទន្លេមេគង្គនៃប្រទេសកម្ពុជា និងវៀតណាម។ តំបន់ដែនដីសណ្តរទន្លេមេគង្គ នៃប្រទេសកម្ពុជារួមមានតំបន់ការពារទេសភាពអន្លង់ព្រីង និងតំបន់ការពារទេសភាពបឹងព្រែកល្ពៅ៕



សត្វក្រៀលដែលរកចំណីជាហ្វូងក្នុងរដូវកាលមិនបន្តពូជ

# ស្វែងយល់ពី ប្រភេទសត្វខ្លាជីតាស (Cheetah)



សត្វខ្លាជីតាស (Cheetah) មានឈ្មោះវិទ្យាសាស្ត្រ Acinonyx jubatus គឺជាប្រភេទខ្លាម៉្យាង មានដើមកំណើតនៅទ្វីបអាហ្វ្រិក និងនៅភូមិភាគកណ្តាលនៃប្រទេសអៀរ៉ង់។ សត្វនេះមានក្បាលរាងមូលតូច រីឯច្រមុះខ្លី។ វាជាសត្វរត់លឿនបំផុត ដែលអាចរត់បានក្នុងល្បឿនពី៨០ ទៅ ១២៨ គីឡូម៉ែត្រក្នុង១ម៉ោង។ តាមការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របានបង្ហាញថា វាអាចរត់បានពី៩៣ ទៅ ៩៨គីឡូម៉ែត្រក្នុង១ម៉ោង ព្រោះសត្វនេះមានជើងតូចវែង ក្រចកស្រួច និងកន្ទុយវែង ជាអំណោយផលក្នុងការរត់បានលឿន។ ដងខ្លួនវាមានប្រវែងចាប់ពី ១.១ម៉ែត្រទៅ១.៥ម៉ែត្រ។ ពួកវាមានទម្ងន់ខុសៗគ្នា អាស្រ័យលើអាយុ ភេទ សុខភាព និងទីតាំងរស់នៅរបស់វា។ ជាទូទៅ សត្វខ្លាជីតាសពេញវ័យមានទម្ងន់ចាប់ពី២១ ទៅ ៧២គីឡូក្រាម។ ចំពោះកូនវាទើបកើតមានទម្ងន់ពី១៥០ ទៅ ៣០០ក្រាម កូនខ្លះមានទម្ងន់រហូតដល់៥០០ក្រាម។ គេសង្កេតនៅចុងសងខាងភ្នែករបស់វាមានឆ្នូតពណ៌ខ្មៅចាក់ចុះមកក្រោមក្រអូមមាត់ រីឯរោមវាមានពណ៌ត្នោតស្រអាប់ លាយពណ៌សព្រឿងៗ និងអុចខ្មៅតូចៗ។

ជាទូទៅ សត្វខ្លាជីតាស មានលក្ខណៈស្រដៀងទៅនឹងខ្លារខិន (Leopard) ប៉ុន្តែវាខុសគ្នាត្រង់នៅលើដងខ្លួនវាមានចំណុចខ្មៅមូលៗ និងមានឆ្នូតខ្មៅចាប់ពីចុងភ្នែករហូតដល់មាត់ ចុងច្រមុះពណ៌ខ្មៅ ហើយមានមាឌតូចជាងខ្លារខិន ហើយខ្លារខិនមានចំណុចដូចផ្កាកុលាប (rosettes) នៅលើស្បែករបស់វា។

ខ្លាជីតាសចូលចិត្តរស់នៅចែកជាក្រុមផ្សេងៗគ្នា មិនរស់នៅលាយឡំគ្នាទេ មានន័យថាខ្លាញី និងកូនវារស់នៅជាមួយគ្នា រីឯខ្លាឈ្មោលវិញរស់នៅជាមួយឈ្មោលគ្នាវាមួយក្រុមដោយឡែក។ គេតែងសង្កេតឃើញខ្លាញីៗរស់នៅចល័តពីកន្លែងមួយទៅកន្លែងមួយដើម្បីស្វែងរកចំណីនៅក្នុងដែនជម្រកដ៏ធំរបស់វា ចំណែកឯខ្លាឈ្មោលវិញច្រើនអង្គុយមួយកន្លែង ហើយបង្កើតជាក្រុមតូចៗក្នុងតំបន់ដែលសម្បូរទៅដោយសត្វសម្រាប់ចាប់ធ្វើជាចំណី ប៉ុន្តែតំបន់ខ្លាឈ្មោលរស់នៅៗជិតតំបន់ខ្លាញីដែរ ដើម្បីងាយស្រួលមានទំនាក់ទំនងជាមួយគ្នា។



ខ្លាជីតាស ( Cheetah )



ខ្លារខិន ( Leopard )

## អេកូឡូស៊ី និងអត្តចរិតរបស់ខ្លាជីតាស (Ecology and behavior)

សត្វខ្លាជីតាសតែងមានសកម្មភាពនៅពេលថ្ងៃដោយឈរនៅលើទីទួលខ្ពស់ៗ ជាពិសេសគេឃើញពួកវានៅពេលព្រលឹមស្រាងៗ និងពេលព្រលប់ថ្ងៃរៀបលិច ចំណែកឯខ្លារខិន (leopard) និងសត្វតោវិញ ចូលចិត្តចេញប្រមាញ់នៅពេលយប់។ ពួកវាចូលចិត្តចាប់សត្វតូចៗ និងសត្វល្មមៗធ្វើជាចំណី ជាពិសេសសត្វមួយចំនួនដែលមានទម្ងន់ក្រោម ៤០គីឡូក្រាម ដូចជាសត្វក្តាន់ ឈ្លូស រមាំង ... ជាដើម។

សត្វប្រភេទនេះធន់ទៅនឹងការដេញចាប់សត្វណាស់ ដោយសារដងខ្លួនវាស្រឡូន ស្រាល ដូច្នេះពេលវាដេញចាប់សត្វម្តងៗវាអាចបង្កើនល្បឿន និងបត់បែនបានយ៉ាងឆាប់រហ័ស។ ម្យ៉ាងទៀតសត្វប្រភេទនេះមានបេះដូង និងសួតធំធ្វើឲ្យដង្ហើមវាដកបានវែង ហើយបង្កើតអុកស៊ីហ្សែនបញ្ជូនទៅក្នុងឈាមបានលឿនក្នុងរយៈពេលខ្លី។ ម្យ៉ាងទៀត ក្រចកនិងកន្ទុយរបស់វាក៏ជាផ្នែកមួយជួយឲ្យវារត់បានលឿនផងដែរ។ នៅពេលរត់ដេញចាប់សត្វម្តងៗ ចង្វាក់បេះដូងវាលោតពី៦០ ទៅ១៥០ដងក្នុង១នាទី។

វិធីចាប់សត្វធ្វើជាចំណីរបស់ពួកវា គឺដើរលបៗសំដៅទៅរកសត្វណាមួយដែលវាចង់ចាប់ ក្នុងចម្ងាយប្រហែលពី ៦០ ទៅ ៧០ម៉ែត្រ រួចចាប់ផ្តើមដេញចាប់សត្វនោះសំដៅខាំបំពង់ករហូតដល់សត្វនោះងាប់។

ពួកវាបង្កាត់ពូជពេញមួយឆ្នាំ ហើយមានផ្ទៃពោះក្នុងរយៈពេលតែ៣ខែទេ ដោយវាកើតកូនម្តងបានពី ៣ ទៅ ៤ក្បាល។ កូនៗរបស់វាមានលក្ខណៈកាចសាហាវ ដូចសត្វអាជីណា និងសត្វតោដែរ។ កូនៗរបស់វាត្រូវបានផ្តាច់ដោះក្រោយពីកើតបានប្រមាណ៤ខែ ហើយចាប់ពីអាយុ ២០ខែទៅ កូនៗទាំងនោះរស់នៅឯករាជ្យដោយខ្លួនវា លែងពឹងផ្អែកលើម្តាយវាទៀតហើយ។

គេតែងឃើញវត្តមានសត្វខ្លាជីតាសនៅក្នុងតំបន់ជម្រកសត្វព្រៃមួយចំនួន ដូចជានៅតំបន់វាលស្មៅសាវ៉ាន់ណា (Savannahs) តំបន់សេរិនហ្គេតទី(Serengeti) នៅតំបន់ជួរភ្នំមួយចំនួននៃវាលខ្សាច់សាហារ៉ា(Sahara) និងនៅតំបន់ខ្ពស់ដែលសម្បូរទៅដោយវាលខ្សាច់ក្នុងប្រទេសអៀរ៉ង់។ ពួកវាមានបញ្ហាប្រឈមជាច្រើនអាចនឹងឈានទៅបាត់បង់នាពេលអនាគតដោយសារបញ្ហា ទី១-ការបាត់បង់ទីជម្រក ទី២-ការលួចបរបាញ់ល្មើសច្បាប់ និងទី៣-ការឆ្លងជំងឺផ្សេងៗ។ តាមប្រវត្តិសាស្ត្របានបញ្ជាក់ថា សត្វខ្លាជីតាសរស់នៅលាតសន្ធឹងចាប់ពីអនុតំបន់វាលខ្សាច់សាហារ៉ា ក្នុងទ្វីបអាហ្វ្រិក រហូតដល់ភាគខាងកើត រួចឆ្លងទៅដល់មជ្ឈិមបូព៌ា និងបន្តរហូតដល់តំបន់ភាគកណ្តាលនៃប្រទេសឥណ្ឌា។ បច្ចុប្បន្នខ្លាជីតាសត្រូវបានគេបែងចែកជាក្រុមតូចៗ រួមមាននៅក្នុងតំបន់ភាគកណ្តាលនៃប្រទេសអៀរ៉ង់ ភាគខាងត្បូងឈៀងខាងកើត និងភាគខាងជើងឈៀងខាងលិចនៃទ្វីបអាហ្វ្រិក។ នៅក្នុងឆ្នាំ២០១៦ តាមការប៉ាន់ស្មាន សត្វខ្លាជីតាសមានវត្តមាននៅក្នុងពិភពលោកតែប្រមាណ ៧១០០ ក្បាល ប៉ុណ្ណោះដែលកំពុងរស់នៅក្នុងព្រៃធម្មជាតិ (តួលេខនេះបានចុះក្នុងបញ្ជីសៀវភៅក្រហមរបស់អង្គការ IUCN Red List)។ កាលពីសម័យមុន សត្វខ្លាជីតាសត្រូវបានគេយកទៅផ្សាំង និងបង្រៀនវាឱ្យចេះចាប់សត្វមួយចំនួនរស់នៅក្នុងព្រៃ ដូចជា សត្វសេះបង្កង់ ជ្រូកព្រៃ ឈ្លូស ក្តាន់ រមាំង។ល។ (ប្រភេទសត្វ Ungulates)។



ក្តាន់ (Impala)



ឈ្លូស (Springbok)



Thomson's gazelles

ជាសត្វចំណីរបស់សត្វខ្លាជីតាស

**ដើមកំណើត**

សត្វខ្លាជីតាស ត្រូវបានអ្នកស្រុកក្នុងតំបន់នោះដាក់ឈ្មោះវាថា ជីតាស (cheetah) មានន័យថា មកពីពាក្យហិណ្ឌូ(Hindustani Urdu) ឬមកពីពាក្យសំស្ក្រឹត ប្រែថា ក្រឡេក្រឡា(variegate)។ កាលពីដើម គេហៅវាថា ខ្លារខិន (hunting leopard)។ បើតាមឈ្មោះវិទ្យាសាស្ត្រហៅថា Acinolyx ពាក្យនេះមកពីការផ្គុំគ្នានៃពាក្យ២ម៉ាត់របស់ប្រទេសក្រិច មានន័យថា មិនមានចលនា (unmove) ឬមិនកម្រើក(motionless) ឬជាសត្វលាក់ក្រចក (immobile nails)។

ផ្អែកតាមការវាយតម្លៃរបស់អង្គការ IUCN ខ្លាជីតាសត្រូវបានបែងចែកជា៤អនុប្រភេទ (Subspecies)។ សត្វខ្លាជីតាសរស់នៅទ្វីបអាហ្វ្រិកភាគអាគ្នេយ៍ (Southeast African cheetah) ៖ តាមការប៉ាន់ស្មានប្រហែលពី ៦៧.០០០ ទៅ ៣២.០០០ឆ្នាំមុន ពួកវាមានប្រភពមកពីទ្វីបអាស៊ី។ នៅឆ្នាំ២០១៦ គេឃើញពួកវាជិត ៤០០០ក្បាល កំពុងរស់នៅប្រទេសមួយចំនួនដូចជា Angola, Botswana, Mozambique, Namibia, South Africa and Zambia។





ខ្លាជីតាសរស់នៅទ្វីបអាស៊ី៖ នៅឆ្នាំ២០១៦ គេឃើញពួកវាមានចំនួន ៤៣ក្បាល ហើយកំពុងសង្គ្រោះនៅក្នុងភាគកណ្តាលនៃប្រទេសអៀរ៉ង់។

**ស្តេចខ្លាជីតាស** ( King cheetah )

ស្តេចខ្លាជីតាសមានលក្ខណៈខុសពីខ្លាជីតាសធម្មតាត្រង់ថា នៅលើរោមខ្នងវា មានឆ្នូតខ្មៅ៣ឆ្នូតរហូតដល់កន្ទុយ។ តាមការកត់សម្គាល់ វាអាចមានទំនាក់ទំនងសម្ព័ន្ធជាមួយខ្លារខិន។ នៅឆ្នាំ១៩២៧ ស្តេចខ្លាជីតាស ត្រូវបានគេប៉ាន់ស្មានមានចំនួនតែជាង ៥ក្បាល ប៉ុណ្ណោះ រស់នៅក្នុងព្រៃនៃប្រទេស Zimbabwe, Botswana និងភាគខាងជើងនៃ Transvaal ហើយក្នុងចំណោមនោះ ត្រូវបានគេថតបាន០១ក្បាលនៅឆ្នាំ១៩៧៥។ នៅឆ្នាំ១៩៨១ ខ្លាជីតាសញី ០២ក្បាល ត្រូវបានយកមកបង្កាត់ពូជជាមួយស្តេចខ្លាជីតាសឈ្មោលព្រៃ ០១ក្បាល ដែលយកមកពីតំបន់ Transvaal



ស្តេចខ្លាជីតាស(លើខ្នងមានឆ្នូតខ្មៅ៣ឆ្នូតរហូតដល់កន្ទុយ)

មកបង្កាត់នៅក្នុងមជ្ឈមណ្ឌលបង្កាត់ពូជសត្វព្រៃក្នុងប្រទេសអាហ្រ្វិកខាងត្បូង ហើយជាលទ្ធផលបង្កើតបានស្ដេចខ្លាជីតាស ០១ក្បាល ហើយក្រុមស្រាវជ្រាវបានបន្តបង្កាត់ពួកវារហូតទទួលបានស្ដេចខ្លាជីតាសជាបន្តបន្ទាប់។

## ការបន្តពូជឡើងវិញ និងវដ្ដជីវិតរបស់សត្វខ្លាជីតាស( Reproduction and life cycle )

ខ្លាជីតាសញីតែងដោយឈ្មោលមានមាឌធំ និងធ្ងន់ជាងវា ហើយវាអាចបន្តពូជពេញមួយឆ្នាំ។ ខ្លាញីអាចបន្តពូជចាប់ពីអាយុពី២ ទៅ ៣ឆ្នាំ ហើយវាអាចដោយឈ្មោលតែរយៈពេល១២ថ្ងៃប៉ុណ្ណោះ បើគិតជាមធ្យម ប៉ុន្តែពេលខ្លះវាអាចបន្តពូជចាប់ពី ៣ថ្ងៃទៅ១ខែ ក៏មានដែរ។ បន្ទាប់មកខ្លាញីអាចមានកូនម្ដងទៀតបន្ទាប់ពី១៧ ទៅ២០ខែក្រោយពីមានកូនសារមុនរួច ឬអាចមានកូនឆាប់មុនពេលកំណត់ប្រសិនបើកូនវាមុនបានងាប់។ ចំពោះខ្លាឈ្មោលវិញអាចបង្កាត់ពូជជាមួយញីបានក្នុងពេលវាមានអាយុតិចជាង២ឆ្នាំក៏ប៉ុន្តែមានពេលខ្លះវាអាចពន្យាការបន្តពូជ បើខ្លាញីមិនអនុញ្ញាតឲ្យវាចូលក្នុងដែនជម្រករបស់ខ្លាញី(ខ្លាញី និងខ្លាឈ្មោលរស់នៅក្នុងដែនផ្សេងគ្នា)។ ខ្លាញីឈ្មោលពេលវាបង្កកំណើតម្ដងរួចហើយ វានឹងជួបគ្នារយៈពេលពី ៣ ទៅ ៥ដងទៀតក្នុង១ថ្ងៃ ហើយបន្តជួបរយៈពេលពី២ ទៅ៣ថ្ងៃទៀត ទើបពួកវាចាកចេញទៅកន្លែងរស់នៅរបស់វារៀងៗខ្លួនវិញ។ តាមការសិក្សាបង្ហាញថា ខ្លាញីខ្លះឆាប់មានកូនតែកូនកើតមកក៏ឆាប់ងាប់វិញដែរ។ ក្រោយមានផ្ទៃពោះជិត៣ខែ ខ្លាញីមួយអាចមានកូនពី១ ទៅ ៨ក្បាល តែជាទូទៅមានត្រឹមតែពី៣ ទៅ ៤ក្បាល ប៉ុណ្ណោះ។

កូនខ្លាអាជីតាសកើតមករយៈពេលតែ៣ ទៅ៤សប្ដាហ៍ពួកវាមានចរិតកាចសាហាវដូចសត្វស៊ីសាច់ជាអាហារដែរ។ ម្ដាយវាតែងមានការប្រុងប្រយ័ត្នខ្លាំងខ្លាចមានសត្រូវមកលួចខាំកូនវា ដូច្នេះវាតែងយកកូនវាទៅលាក់ទុកនៅក្នុងគុម្ពោតព្រៃរយៈពេល២ខែក្រោយពីកើតមក។ ម្ដាយវាមិនសូវចេញទៅណាឆ្ងាយពីពួកវាទេ វាចេញយ៉ាងច្រើនត្រឹម១គីឡូម៉ែត្រដើម្បីងាយស្រួលការពារកូនវា។ មេវាតែងយកកូនទៅលាក់កន្លែងផ្សេងរយៈពេលពី៥ ទៅ ៦ថ្ងៃម្ដង ដោយធ្វើនៅពេលយប់។ កូនខ្លាអាជីតាសអាចងាប់ប្រសិនបើមេវាបោះបង់ចោល ឬដោយសារភ្លើងឆេះព្រៃ ឬអាកាសធាតុអាក្រក់ណាមួយកើតឡើងនៅក្នុងដែនជម្រករបស់ពួកវា។ ពួកវាចាកចេញពីជម្រកនូវអាយុបាន២ខែ ហើយដើរតាមម្ដាយវានៅពេលនោះម្ដាយវាផ្ដល់ចំណីឲ្យវាតិចជាងមុន។





មេខ្លាជីតាស និងកូនៗរបស់វា

ពីដំបូងកូនវាមិនហ៊ានស៊ីសត្វងាប់ជាចំណីទេដោយសារវាខ្លាច តែក្រោយមកបានវាហ៊ានស៊ី។ កូនខ្លាអាយុ៦ខែចាប់ផ្ដើមចាប់សត្វតូចៗធ្វើជាចំណី ប៉ុន្តែការចាប់សត្វទាំងនោះមិនទទួលបានជោគជ័យទេ រហូតដល់ពួកវាអាយុបាន ១៥ខែ បានមានសមត្ថភាពចាប់សត្វព្រៃបាន។ ពួកវាមានអាយុ ២០ខែ អាចគ្រប់គ្រងខ្លួនឯងបាន ហើយម្ដាយវាបន្តមានកូនសំបុកផ្សេងទៀត។ ជាទូទៅកូនខ្លាញីតែងរស់នៅជិតម្ដាយរបស់វា រីឯកូនខ្លាឈ្មោលវិញចាកចេញទៅឆ្ងាយពីម្ដាយ។

ខ្លាជីតាសអាចមានអាយុពី១៤ ទៅ១៥ឆ្នាំ ចំពោះខ្លាញី ហើយអាចបង្កកំណើតត្រឹមអាយុតែ១២ឆ្នាំប៉ុណ្ណោះ រីឯខ្លាឈ្មោលវិញមានអាយុវែងជាងខ្លាញី រហូតដល់១០ឆ្នាំឯណោះ។

**ការគំរាមកំហែង** (Threats)

មានបញ្ហាប្រឈមជាច្រើនចំពោះអាយុជីវិតរបស់ខ្លាអាជីតាស ដោយសារកត្តាផ្សេងៗ រួមមាន ការបំប្លែងដីព្រៃសម្រាប់គោលបំណងពាណិជ្ជកម្ម ការធ្វើកសិកម្ម ឧស្សាហកម្ម និងការកាប់ទន្ទ្រានដីព្រៃល្មើសច្បាប់ ដែលកត្តាទាំងនេះធ្វើឲ្យបាត់បង់ប្រព័ន្ធអេកូឡូស៊ី ជាពិសេសបាត់បង់ជម្រករបស់ពួកវា ហើយបញ្ហានេះច្រើនកើតឡើងនៅតំបន់ភូមិភាគខាងត្បូងនៃទ្វីបអាហ្វ្រិក។ កត្តាមួយទៀត គឺខ្លាជីតាសពុំមានចំណីអាហារគ្រប់គ្រាន់ ដោយសារត្រូវប្រឈមជាមួយសត្វមួយចំនួនចាប់សត្វជាចំណីអាហារដូចគ្នា ហើយត្រូវប្រឈមដណ្តើមចំណីជាមួយសត្វទាំងនោះ និងមានកត្តាផ្សេងៗទៀត។ រហូតមកដល់ពេលនេះ គេឃើញវត្តមានខ្លាអាជីតាសមានចំនួនតិចជាងខ្លារខិន។ តាមការសិក្សាមានផ្ទៃដីប្រមាណ ៧៦%នៅក្នុងប្រទេស Namibia ដែលខ្លាអាជីតាសតែងរស់នៅ ត្រូវបានម្ចាស់ចម្ការ និងអ្នកគង្វាលសត្វពាហនៈដេញមិនឲ្យពួកវារស់នៅក្នុងតំបន់នោះ។ ម៉្យាងទៀតការជួញដូរសត្វព្រៃ និងការរត់ពន្ធសត្វព្រៃល្មើសច្បាប់ក៏ជាកត្តាប្រឈមចម្បងដែរនៅក្នុងតំបន់មួយចំនួន ដូចជានៅប្រទេស Ethiopia ជាដើម ជាពិសេសមានក្រុមកុលសម្ព័ន្ធ Maasai ក្នុងប្រទេស Tanzania បានយកស្បែកខ្លាជីតាសប្រើប្រាស់ក្នុងពិធីបុណ្យ ធ្វើឲ្យពួកវាបាត់បង់ជាបន្តបន្ទាប់ ហើយកត្តាមួយទៀតពួកវាងាប់ដោយសារជំងឺ។

**វិធានការនានាសម្រាប់ការអភិរក្ស**

(Conservation measures)

នៅទសវត្ស៧០ ខ្លាជីតាស និងសត្វមួយចំនួនត្រូវបានសម្លាប់ជាបន្តបន្ទាប់ពីក្រុមអ្នកឃ្វាលសត្វពាហនៈក្នុងតំបន់មួយចំនួននៃទ្វីបអាហ្វ្រិក ហើយពេលនោះចំនួនខ្លាបានថយចុះជាបន្តបន្ទាប់គួរឲ្យបារម្ភ។ ក្រោយមក នៅឆ្នាំ១៩៧១ មជ្ឈមណ្ឌលការពារសត្វព្រៃ និងខ្លាជីតាស (The De Wild Cheetah and Wildlife Centre) ត្រូវបានបង្កើតឡើងនៅភាគខាងត្បូងនៃទ្វីបអាហ្វ្រិក ដើម្បីការពារ និងសង្គ្រោះខ្លាជីតាសពីការចាប់អន្ទាក់ និងមានរបួសដែលប្រព្រឹត្តឡើងដោយកសិករនៅប្រទេស Namibia។ នៅឆ្នាំ១៩៨៧ គម្រោងស្រាវជ្រាវខ្លាជីតាសដ៏ធំមួយត្រូវបានបង្កើតឡើងដំបូង ដើម្បីរៀបចំយុទ្ធសាស្ត្រអភិរក្សខ្លាប្រភេទនេះ។ បន្ទាប់មកនៅឆ្នាំ១៩៩០ មូលនិធិអភិរក្សខ្លាជីតាស (Cheetah Conservation Fund) ត្រូវបានបង្កើតឡើងក្នុងប្រទេស Namibia ដើម្បីចុះទៅស្រាវជ្រាវខ្លាប្រភេទនេះនៅតាមទីវាល និងធ្វើការអប់រំផ្សព្វផ្សាយជាសាធារណៈអំពីសារសំខាន់នៃខ្លាជីតាសនេះ។

នៅឆ្នាំ២០០២ មានរៀបចំសិក្ខាសាលាដ៏ធំមួយ ដើម្បីសិក្សា និងធ្វើការអង្កេតទៅលើជម្រករស់នៅរបស់ខ្លាជីតាស រួចកំណត់ដែនដីរស់នៅរបស់ពួកវា ដើម្បីធ្វើការអភិរក្ស។ នៅឆ្នាំ២០០៧ អង្គការ The Range Wide Conservation Program for Cheetah and African Wild Dogs ដោយមានការផ្តួចផ្តើមពីអង្គការ IUCN Cat និង Canid Specialist Groups, WCS and Zoological Society of London បានរួមគ្នារៀបចំជាផែនការអភិរក្សថ្នាក់ជាតិមួយសម្រាប់អនុវត្តនៅក្នុងប្រទេសមួយចំនួនដែលមានវត្តមានខ្លាជីតាសនៅក្នុងទ្វីបអាហ្វ្រិក។ នៅឆ្នាំ២០១៤ CITES Standing Committee បានទទួលស្គាល់ខ្លាជីតាស ដោយចាត់ទុកពួកវាថា ជាប្រភេទសត្វសំខាន់ (species of priority) សម្រាប់ផែនការយុទ្ធសាស្ត្រមួយចំនួននៅក្នុងភូមិភាគខាងជើងឈៀងខាងកើតនៃទ្វីបអាហ្វ្រិក ដែលជាតំបន់ត្រូវរងគ្រោះដោយសារការជួញដូរសត្វព្រៃ។ បន្ទាប់មកនៅខែធ្នូ ឆ្នាំ២០១៦ ក្រោយពីទទួលបានលទ្ធផលចុះអង្កេតស្រាវជ្រាវ និងបានកំណត់តំបន់រស់នៅរបស់ខ្លាជីតាសរួចហើយ ក្រុមការងារបានចងក្រងជាឯកសារ ហើយបានបោះពុម្ពឡើង។ ពេលនោះអ្នកស្រាវជ្រាវបានកំណត់ខ្លាជីតាសថាជាប្រភេទសត្វងាយរងគ្រោះថ្នាក់ (Endangered Species)ដោយដាក់បញ្ចូលទៅក្នុងសៀវភៅក្រហមរបស់អង្គការ IUCN។

អត្ថបទប្រែសម្រួលដោយលោកៈ **សេខ ស៊ីនណារុន**

(ដកស្រង់ពីវេបសាយ https//en.wikipedia.org/wiki/cheetah)

# កំប្លែង!




ដោយ ឃឿង អឿងតិច ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ

## មានឆ្កែជាគំរូ

មានប្តីប្រពន្ធគំរូមួយគូ ល្បីល្បាញណាស់ គឺតាំងពីរៀបការរួមរស់ជាមួយគ្នារយៈពេលជាង៤០ឆ្នាំមកនេះ មិនដែលឈ្លោះប្រកែកគ្នាសូម្បីតែមួយម៉ាត់។ ភាពល្បីនេះបានទាក់ទាញអ្នកកាសែតមកដល់ផ្ទះពួកគាត់ ដើម្បីសម្ភាសន៍ពីចំណុចពិសេសៗ ដែលអាចថែរក្សាស្នេហាដ៏អស្ចារ្យមួយនេះ។ **អ្នកកាសែត៖** តើអ្នកទាំងពីរមានវិធីសាស្ត្រអ្វីដែលអាចធ្វើឱ្យអ្នកទាំងពីរមិនដែលឈ្លោះគ្នាអស់រយៈពេលជាង ៤០ឆ្នាំកន្លងទៅនេះ? **ប្តី៖** គឺថាថ្ងៃទីមួយក្រោយពីរៀបការរួច ខ្ញុំបាននាំនាងមកផ្ទះខ្ញុំ ដើម្បីរស់នៅជាមួយគ្រួសារខ្ញុំ។ ពេលដើរចូលផ្ទះ ឆ្កែរបស់ខ្ញុំក៏ចេញមកព្រុស ថែមទាំងរកខាំនាងទៀត តែនាងមិនបានធ្វើស្អីវាទេ គ្រាន់តែនាងរាប់ថា "លើកទីមួយ"។ ស្អែកឡើងនាងក៏បានទៅធ្វើការ ហើយដល់ល្ងាចមកវិញ ឆ្កែក៏រត់មកព្រុសចង់ខាំនាងម្តងទៀត។ នាងក៏មិនបានធ្វើស្អីវាដដែល គ្រាន់តែរាប់ថា "លើកទីពីរ"។ ថ្ងៃទីបីជាថ្ងៃអាទិត្យ ព្រឹកនោះនាងបានទៅផ្សារទិញម្ហូប ពេលត្រលប់មកវិញ ឆ្កែក៏លោតទៅចង់ខាំនាងម្តងទៀត។ លើកនេះនាងមិនបាននិយាយអ្វីទាំងអស់ តែនាងបានដកកាំភ្លើងចេញពីកាបូប **រួចក៏បាញ់ឆ្កែហ្នឹងងាប់ទៅ។** ពេលនោះខ្ញុំក៏រត់ចេញមកស្តីឱ្យនាងថា មនុស្សស្អីក៏កាចសាហាវខ្លាំងម្ល៉េះ! សូម្បីតែសត្វឆ្កែក្នុងផ្ទះក៏នាងសម្លាប់ដែរ! មិនគួរណាខ្ញុំយកនាងធ្វើប្រពន្ធសោះ។

ពេលនោះនាងមិនបានធ្វើអ្វីទាំងអស់ នាងគ្រាន់តែរាប់ថា "លើកទីមួយ" ហើយខ្ញុំស្តាប់មិនទាន់ច្បាស់ ក៏បន្តសួរម្តងទៀតថា ហេតុអ្វីធ្វើបែបហ្នឹង? នាងក៏និយាយបន្តថា "លើកទីពីរ"។ ពេលនេះខ្ញុំស្តាប់បានច្បាស់ ហើយក៏យល់ច្បាស់បំផុតថា គ្មានទេលើកទីបី! ដូច្នេះចាប់តាំងពីពេលនោះមកពួកយើងទាំងពីររស់នៅជាមួយគ្នាមិនដែលឈ្លោះគ្នាទេ។

## មហាសំណាង

ថ្ងៃនេះប្រពន្ធមកដល់ផ្ទះលឿនជាងធម្មតា ស្រាប់តែឮសំឡេងព្រួសប្រាសៗក្នុងបន្ទប់គេង! ប្រពន្ធក៏ស្ទុះច្រានទ្វារចូលទៅ ស្រាប់តែឃើញប្តីនៅខ្លួនទទេ បែកញើសជោក...

**ប្រពន្ធ៖** បងកើតអីហ្នឹង ?

**ប្តី** ៖ *(ឆ្លើយទាំងញ័រមាត់)* អើ... អើ...មិញ បងឡើងឈាមខ្លាំង ចង់ស្ត្រូក (stroke)

**ប្រពន្ធ៖** យី! មិនបានទេ ចាំខ្ញុំទៅហៅពេទ្យសិន!

*នៅពេលដែលប្រពន្ធហៀបចេញទៅហៅពេទ្យនោះ ស្រាប់តែអាចក់កូនប្រុស អាយុ ៥ឆ្នាំ រត់មកប្រាប់ម្តាយវា...*

**ចក់** ៖ម៉ាក់! ម៉ាក់ ! មីង ញ៉ាញ់ នៅពួនក្នុងទូរនោះ !

*ពុក្លាមប្រពន្ធស្ទុះរឹងទៅបើកទូរខោអាវ ក៏ឃើញនាងញ៉ាញ់ ដែលជាក្មួយស្រីក្មេងស្រស់ស្អាត ស្លៀកចងពុងនៅពួនកំប្រោនៗ ក្នុងនោះ។ គាត់ខឹងស្រែកស្ទើរភ្លាត់សំឡេង...*

**ប្រពន្ធ៖** យី! មីបំបង់បាយ!!! ប្តីអញលើសឈាមជិតស្លាប់ វាគិតតែមកលេងបិទពួនជាមួយកូនក្មេងទៅវិញហាស៎!?

## ស្អប់អ្នកមើលងាយ

*មានស្ត្រីចំណាស់ម្នាក់បីកូនឡើងជិះរថយន្តក្រុង នៅពេលឡើងដល់ភ្លាមអ្នកបើកបររថយន្តក្រុងនិយាយថា* ឱ! អ្នកអើយអ្នក តាំងពីខ្ញុំកើតមកមិនដែលឃើញកូនអ្នកណាអាក្រក់ដូចកូនរបស់អ្នកឡើយ មើលទៅដូចស្វាម៉េចទេ។ *ស្ត្រីជាម្តាយខឹងខ្លាំងណាស់ មិនមាត់អ្វីមួយម៉ាត់ក៏បានដើរទៅកន្លែងអង្គុយនៅខាងក្រោយ។ នៅពេលនោះក៏បានជួបនឹងបុរសម្នាក់ទៀត ហើយបុរសម្នាក់នោះ ក៏បានសួរទៅស្ត្រីនោះថា៖* តើអ្នកស្រីមានរឿងអ្វីបានជាមានទឹកមុខស្រងូតស្រងាត់ខ្លាំងម្ល៉េះ អាចប្រាប់ខ្ញុំផងបានទេ? *ស្ត្រីនោះក៏ឆ្លើយប្រាប់ថា៖* លោកជួយគិតមើល! នៅពេលដែលខ្ញុំឡើងជិះរថយន្តក្រុងរបស់គាត់ គាត់បានប្រមាថមើលងាយរូបខ្ញុំខ្លាំងណាស់... *បុរសម្នាក់នោះក៏និយាយថា៖* ពិតមែនឬអ្នកស្រី? ខ្ញុំមិនចូលចិត្តទាល់តែសោះមនុស្សដែលមើលងាយគេ ជាពិសេសមើលងាយស្ត្រីដូចរូបអ្នកតែម្តង... អ្នកទៅទះកំផ្លៀងអាគាត់នោះទៅ **ចាំខ្ញុំបីស្វាឲ្យ!**

*ស្ត្រីនោះ៖* អុញ!!!???!!!




# រួមគ្នាស្តាយស្រណោះ

**បទកាកគតិ** ដោយលោកៈ លិ ឧុឡី

រួមស្តាយស្រណោះ យើងខ្មែរទាំងអស់ ជនរួមសញ្ជាតិ
សត្វព្រៃទ្រព្យខ្មែរ សម្បត្តិធម្មជាតិ ទោះតូចធំមាឌ
សំខាន់ដូចគ្នា ។

សត្វមួយចំនួន ដែលបានបាត់ខ្លួន រយៈតាមគ្រា
រមាសមុនគេ ផុតពូជផទនា កាលនៅឆ្នាំជា
ដប់(ប្រាំ)បួនសាមសិប (១៩៣០) ។

តាមឈ្មោះកត់ត្រា រមាសអាត្មា នៅពាសរដិប
ពាសពេញស្រុកខ្មែរ ហូរហៃរាប់សិប ច្រើនខេត្តរញ្ជិប
មានឈ្មោះដូចជា ។

ស្តុកអាចម៍រមាស រាល់ប្រជារាស្ត្រ បានស្គាល់គ្រប់គ្នា
ខេត្តកំពង់ឆ្នាំង ឈ្មោះត្មមិឃុំវ៉ា ធ្លាប់មានច្រើនគ្រា
ធ្លាប់មានរមាស ។

ឃុំមួយច្បាស់ចែស នៅខេត្តក្រចេះ ឃុំក្បាលរមាស
ជាប់មកតែឈ្មោះ ក្នុងខេត្តពេញពាស និងក្បាលរមាស
នៅក្នុងខេត្តកែប ។

នៅខេត្តស្វាយរៀង ស្រុកមួយឈ្មោះទៀង ឈ្មោះរមាសបែប
ស្រុករមាសហែក ពីយូរដូចថែប រមាសធ្លាប់អែប
ឆ្អើសហែកមនុស្ស ។

ឈ្មោះសត្វទីពីរ បានបាត់ពីទី ស្រុកខ្មែរយើងនោះ
គឺសត្វគោព្រៃ កាលមិនយូរលុះ គឺកាលឆ្នាំនោះ
ដប់(ប្រាំ)បួនប៉ែតសិប (១៩៨០)។



បុរសជនជាតិបារាំងបានបាញ់សត្វរមាស ១ក្បាល ដែលនេះត្រូវបានគេចាត់ទុកថា ជាការសម្លាប់លើកចុងក្រោយនៅខេត្តកំពង់ចាម ក្នុងអំឡុងឆ្នាំ១៩៣០



សត្វរមាសខ្មែរ ជារមាសកុយមួយ ជាសត្វដែលកម្រ បំផុតនៅក្នុងគ្រួសាររមាសទាំងអស់នៅលើពិភពលោក វាជាសត្វដែលចូលចិត្តរស់នៅដោយឯកឯង ពុំដើរជាហ្វូងទេ លើកលែងតែពេលវាត្រូវការបន្តពូជ

(នៅមានត)

( សម្គាល់៖ សូមអានកញ្ជក់លើពាក្យក្នុងវង់ក្រចក )


